ស្ថចនាករទី១២៖ អង្គការ ម.ព.ជ. តែងជួយឧបត្ថម្ភ ដល់មិត្តអប់រំមិត្តចំនួន៥០%នៃការចំណាយលើឱសថបង្ខិល ទុនជាប្រចាំខែ។ សរុបមក ក្នុងរយៈពេល១២ខែឆ្នាំ២០២៥នេះ អង្គការបានជួយឧបត្ថម្ភ៥០%ជាប្រចាំខែលើសេវាឱសថ បង្ខិលទុនដល់មិត្តអប់រំមិត្តមានចំនួន ២៧៧១ករណី សម្រាប់ មិត្តអប់រំមិត្តទូទាំងប្រទេសដែលបាននឹងកំពុងបំពេញការងារ ស្ម័គ្រចិត្តរបស់ខ្លួន។

Indicator 12: Every year, MoPoTsyo supports 50% refund for monthly routine medication of every peer educator. During 12 months in 2025, this refund is calculated and added to their monthly fixed-fee (in total 2771 times).

ស្ថចនាករទី១៣៖ ដោយអនុវត្តតាមគោលការណ៍លើក លែងបង់ថ្លៃសេវារបស់មន្ទីរពេទ្យបង្អែក/មណ្ឌលសុខភាពជា ដៃគូ។ ចំពោះសមាជិកអ្នកជំងឺដែលមកទទួលសេវាពិគ្រោះ ហើយមានប័ណ្ណក្រីក្រ និងករណីសមាជិកបសសមួយចំនួន (តាមមន្ទីរពេទ្យ/មណ្ឌលសុខភាពខ្លះ) គឺត្រូវបានទទួលការ លើកលែងសេវាពិគ្រោះ ឬស្មើនឹងតម្លៃភាគទានសេវា ១២.០០០រៀលក្នុងមួយលើក។ ក្នុងឆ្នាំ២០២៥ សរុបករណី លើកលែងសេវាពិគ្រោះមានចំនួន ៣៣៣៧ករណី។

Indicator 13: ID poor card holders and some fee exemption cases who are registered as members were exempted from the free (12,000 riels per time) if they want to use the medical consultation services regularly organized by peer educator networks in the public HFs. There were 3,337 cases of exemptions in 2025.

ស្ថចនាករទី១៤៖ ក្នុងឆ្នាំ២០២៥នេះដែរ សមាជិកដែល បានទទួលសេវាបូមឈាមធ្វើតេស្តមន្ទីរពិសោធន៍សរុបមាន ចំនួន ១៨១៥៧ករណី។ សេវាបូមឈាមនេះ គឺធ្វើឡើងនៅ តាមមណ្ឌលសុខភាព ឬមន្ទីរពេទ្យបង្អែក ដោយមានក្រុមមិត្ត អប់រំមិត្តជាអ្នករៀបចំសម្របសម្រួលជាមួយបុគ្គលិកសុខាភិ បាលក្នុងការប្រមូលសំណាកគឈាមនិងទឹកនោម សម្រាប់ តេស្តមន្ទីរពិសោធន៍នៅការិយាល័យអង្គការម.ព.ជ. នៅរាជ ធានីភ្នំពេញ។

Indicator 14: In 2025, 18,157 blood samples were collected from member patients at the public HFs to be tested by our laboratory at MoPoTsyo's office. Everywhere, RH's or HC's staff drew blood samples, and peer educator lab team packed the samples and sent to MoPoTsyo Lab section in Phnom Penh.

ស្ថចនាករទី១៥៖ ចុងក្រោយគឺចំនួនសមាជិកដែល បានមកទទួលយកសេវាពិគ្រោះជំងឺជាមួយវេជ្ជបណ្ឌិតដែល បានទទួលការបណ្តុះបណ្តាលរួចហើយ។ យោងតាមប្រព័ន្ធ ទិន្នន័យ ក្នុងឆ្នាំ២០២៥ មានករណីសរុបបញ្ចូលគ្នាទាំងករណី ជំងឺទឹកនោមផ្អែម និងករណីជំងឺលើសសម្ពាធឈាម បានមក ទទួលយកសេវាពិគ្រោះជំងឺប្រមាណ ៥៥០៣៣ករណី។ ករណីពិគ្រោះមួយចំនួនតូច មិនត្រូវបានកត់ត្រាក្នុងប្រព័ន្ធ ទិន្នន័យឡើយ ដោយសារគ្រូពេទ្យមិនបានចម្លងវេជ្ជបញ្ជា បញ្ជូនមកឱ្យអង្គការ ឬបានបាត់នៅពេលមិត្តអប់រំមិត្តប្រមូល របាយការណ៍។

Indicator 15: Lastly, the members received 55,033 times medical consultation by government doctors at the Referral Hospitals or Health Centers during sessions facilitated and organized by the peer educator network. Some cases were not counted because the doctors did not rewrite the prescription on the MoPoTsyo record paper or the prescriptions were lost during the collection by peer educator team.

ដំណើរការសមាហរណកម្ម INTEGRATION WITH THE PUBLIC HEALTH SYSTEM

នៅឆ្នាំ២០០៥ សេវាថែទាំសុខភាពសម្រាប់ជំងឺទឹកនោមផ្អែមនិងជំងឺលើសសម្ពាធឈាម មិនមាននៅក្នុងសេវារបស់មណ្ឌលសុខភាពនិងមន្ទីរពេទ្យបង្អែកនៅឡើយ។ ដោយមើលឃើញនូវភាពខ្វះចន្លោះនៃសេវាបែបនេះ ទើបឈានទៅដល់ការបង្កើតជាកម្មវិធីបណ្តាញមិត្តអប់រំមិត្តឡើងដោយអង្គការ ម.ព.ជ.។ បើយើងមើលត្រឡប់ទៅកាន់ឆ្នាំ ២០០៥ ជាពេលដែលបានបណ្តុះបណ្តាលអ្នកស្ម័គ្រចិត្ត២នាក់ដំបូង សម្រាប់ការអនុវត្តកម្មវិធី បណ្តាញមិត្តអប់រំមិត្តតាមតំបន់ក្រីក្រក្នុងទីក្រុងនោះ យើងអាចចង្អុលបង្ហាញឱ្យឃើញអំពីចំនុចគោលដៅនៃសមាហរណកម្មកម្មវិធី ក្នុងប្រព័ន្ធសុខាភិបាលសាធារណៈ។ ឆ្នាំ២០០៧ យើងបានបង្កើតបណ្តាញមិត្តអប់រំមិត្តនៅជនបទជាលើកដំបូង តាមរយៈការបង្កើតមិត្តអប់រំមិត្តម្នាក់ ទទួលខុសត្រូវក្នុងមណ្ឌលសុខភាពមួយ ហើយយើងបានជួលវេជ្ជបណ្ឌិតជំនាញមួយរូបពីទីក្រុងភ្នំពេញ ដើម្បីផ្តល់សេវាពិគ្រោះជំងឺនៅមន្ទីរពេទ្យបង្អែកស្រុកក្នុងមួយព្រឹក។ ការពិគ្រោះជំងឺនោះ ធ្វើឡើងក្នុងអគារពិគ្រោះផ្នែកជំងឺក្រៅ (អគារអេដស៍) របស់មន្ទីរពេទ្យបង្អែកអង្គរកា។

In 2005, chronic care for diabetes and hypertension patients was absent from the medical services provided by health centers and referral hospitals. This absence led to the creation of the peer educator networks for diabetes and hypertension by MoPoTsyo. If we look back to 2005, when we began to train the first two peer educators for their activities in poor urban areas, we can pinpoint several milestones on the road to integration with the public service. In 2007 the first rural peer educator network of one peer educator per health center coverage area, and the first Phnom Penh Doctor was hired to travel to a rural Referral Hospital to do a medical consultation session seeing around 30 patients during a session. This consultation session took place at the MMM building (HIV-AIDS) in Ang Roka.

បន្ទាប់មក នៅឆ្នាំ២០១០ សំណាកឈាម និងសំណាកទឹកនោមជាលើកដំបូង ដែលប្រមូលពីសមាជិកទាំង៣០នាក់ខាងលើ បានផ្ញើមកមន្ទីរពិសោធន៍វេជ្ជសាស្ត្រនៅភ្នំពេញ។ នៅឆ្នាំ២០១២ យើងបានដាក់ឱ្យដំណើរការចែកចាយឱសថនៃមូលនិធិ ឱសថបង្ខិលទុនសម្រាប់សមាជិក នៅក្នុងមន្ទីរពេទ្យបង្អែករបស់រដ្ឋជាលើកដំបូង ដែលផ្តល់លទ្ធភាពឱ្យសមាជិកអាចទិញថ្នាំ (នាំចូលដោយអង្គការ ម.ព.ជ.) សម្រាប់ព្យាបាលជាប្រចាំរបស់ពួកគេ ដោយពុំចាំបាច់ត្រូវទៅជួបពិគ្រោះជំងឺសារឡើងវិញ ជាមួយគ្រូពេទ្យជំនាញទៀតទេ។ នៅក្នុងឆ្នាំ២០១៣ ក្រសួងសុខាភិបាលបានអនុម័តនូវផែនការយុទ្ធសាស្ត្រ ដើម្បីការពារនិងគ្រប់គ្រងជំងឺមិនឆ្លង សម្រាប់ឆ្នាំ ២០១៣-២០២០។ ផែនការយុទ្ធសាស្ត្រត្រូវបានផ្សព្វផ្សាយទូលំទូលាយនាខែមេសា ឆ្នាំ២០១៤។ ចាប់ពីពេលនោះមក សំនួរប្រឈមសម្រាប់យើងមិនមែនថាតើ មិត្តអប់រំមិត្តគួរ ឬមិនគួរបញ្ចូលក្នុងប្រព័ន្ធសុខាភិបាលសាធារណៈទៀតទេ ប៉ុន្តែគឺជាបញ្ហាថាតើ គួរបញ្ចូលបណ្តាញមិត្តអប់រំមិត្ត ដោយរបៀបណា ទៅក្នុងប្រព័ន្ធសុខាភិបាលថ្នាក់មូលដ្ឋាន។

In 2010, we began the first blood serum and urine collections among a group of about 30 members at a Health Center and preparation for cool transport to the central laboratory in Phnom Penh for the biochemistry lab profile. In 2012: The first public referral hospital pharmacy began to sell routine medications (imported through MoPoTsyo's RDF) to patients who are network-members without requiring them to see their doctor every time. They just came for a refill of their prescription. In 2013, the MoH approved the National Strategic Plan for Prevention and Control of NCD 2013 – 2020, disseminated in 2014. From then onwards, the challenge shifted from the question "if" the peer educator networks must be integrated" to "how" they must be integrated with the public health system.

ផែនការយុទ្ធសាស្ត្រជាតិនេះ ត្រូវបានជំនួសដោយផែនការយុទ្ធសាស្ត្រជាតិថ្មីមួយទៀត គឺ ផែនការយុទ្ធសាស្ត្រជាតិសម្រាប់ការពារ និងប្រយុទ្ធនឹងជំងឺមិនឆ្លងឆ្នាំ ២០២២-២០៣០។

This MoH strategic plan was followed by the NSP for Prevention and Control of NCD 2022 – 2030.

ផែនការយុទ្ធសាស្ត្រនេះ នៅតែមានសារសំខាន់ ព្រោះវាបានបញ្ជាក់យ៉ាងច្បាស់ អំពីបណ្តាញមិត្តអប់រំមិត្ត សម្រាប់ជំងឺទឹកនោមផ្អែម និងជំងឺលើសសម្ពាធឈាម និង បញ្ជាក់ឱ្យបន្ត និងពង្រីកសកម្មភាពរបស់បណ្តាញនេះ។ ប៉ុន្តែ មិនមានកម្មវិធីណាជាក់លាក់ បានគាំទ្របណ្តាញមិត្តអប់រំមិត្ត នេះឡើយ។ គម្រោង លើកកម្ពស់សុខភាពនិងសមធម៌សុខា ភិបាល ដំណាក់កាលទី២ (HEQIP-II) បានផ្តល់ប្រាក់លើកទឹក ចិត្តដល់អ្នកស្ម័គ្រចិត្តសុខភាពតាមភូមិ (VHSGs)។ មានមិត្ត អប់រំមិត្តខ្លះ ក៏ជា VHSG ផងដែរ ដែលនេះជាឱកាសដែល អាចបញ្ចូលមិត្តអប់រំមិត្តផ្សេងទៀត ជាអ្នកស្ម័គ្រចិត្តតាមភូមិ។

It remains important because it explicitly mentions peer educator networks for diabetes and hypertension and calls for their continuation and expansion. but there is no concrete project other than MoPoTsyo that supports Peer Educators. However, the MoH HEQIP-II project provides financial incentives for screening activities by Village Health worker Support Group members (VHSG). Some of the peer educators are also VHSG. This opens a path to integration for other PEs.

សមាសភាពក្រុមការងារសុខភាពសហគមន៍ ដែល រៀបចំដោយក្រសួងសុខាភិបាល មានទ្រង់ទ្រាយខ្លី គឺការប ណ្តុះបណ្តាលអ្នកស្ម័គ្រចិត្តសុខភាពភូមិចំនួន២ថ្ងៃ ខណៈ ដែលអង្គការ ម.ព.ជ. ធ្វើការជាមួយមិត្តអប់រំមិត្តម្នាក់ ដើម្បី គ្រប់ដណ្តប់ភូមិទាំងអស់របស់មណ្ឌលសុខភាព។ ជាគោល គំនិត ប្រព័ន្ធទាំងពីរនេះ គឺរៀបចំឡើងដើម្បីអាចជួយបំពេញ ឱ្យគ្នាទៅវិញទៅមក ដើម្បីពង្រឹងការងារចុះសហគមន៍ និង អាចគ្របដណ្តប់លើប្រជាពលរដ្ឋបានច្រើនជាង។ មិត្តអប់រំ មិត្តម្នាក់ ធ្វើការសហការជាមួយមណ្ឌលសុខភាពមួយ និង មានបណ្តាញអ្នកស្ម័គ្រចិត្តសុខភាពភូមិ ដែលមានតួនាទីជាក់ លាក់ជាង (ខុសពីមិត្តអប់រំមិត្ត) និងផ្តោតលើសកម្មភាពជំងឺ លើសសម្ពាធឈាម។ ទាំងក្រុមអ្នកស្ម័គ្រចិត្តសុខភាពតាម ភូមិ និងអ្នកស្ម័គ្រចិត្តជាមិត្តអប់រំមិត្ត គឺអាស្រ័យលើការបង់ ប្រាក់លើកទឹកចិត្តបន្តិចបន្តួច និងបង់សងលើការចំណាយ សកម្មភាពរបស់ពួកគេជាទៀងទាត់។

The community component designed by MoH only has a “lite” 2-day NCD training of Village Health Workers, whereas MoPoTsyo works with one Peer Educator who is supposed to cover all villages in the Health Center area. Ideally both systems are made to work complementarily, which would strengthen the coverage and outreach: one peer educator with a counterpart at the Health Center and a network of Village based volunteers who have more restricted roles than the peer educator but with more activities on non-diabetic hypertension patients. Both systems (VHSG and PE) depend on regular payment of “cost reimbursements” and small “incentives”.

ក្នុងឆ្នាំ២០២២ ក្រសួងសុខាភិបាលបានចាប់ផ្តើម គម្រោង HEQIP ដំណាក់កាល២ ក្របខណ្ឌទូទាំងប្រទេស។ គោលបំណងមួយ ក្នុងចំណោមគោលបំណងនៃគម្រោងនេះ គឺរៀបចំប្រព័ន្ធថែទាំបន្ត សម្រាប់អ្នកជំងឺរ៉ាំរ៉ៃមិនឆ្លង ដូចជា ករណីទឹកនោមផ្អែម និងលើសសម្ពាធឈាមជាដើម។ ប្រព័ន្ធ ថ្មីនេះ គួរផ្តល់នូវតួនាទីសមស្របដល់មន្ទីរពេទ្យបង្អែក និង មណ្ឌលសុខភាព ក្នុងការផ្តល់សេវាដល់ករណីជំងឺរ៉ាំរ៉ៃដែល មកដល់ពេលនេះ មិនទាន់ទទួលបានសេវាសមស្រប នៅ កម្រិតព្យាបាលបឋមនៅកម្ពុជា រយៈកាលជាង៣ទស្សវត្សមក នេះ។ គម្រោងដំណាក់កាលទី២នេះគឺ ផ្តោតលើការងារ ស្រាវជ្រាវរក និងចុះឈ្មោះករណីថ្មី។ ប៉ុន្តែបញ្ហាប្រឈមដែល នៅសេសសល់ គឺការមិនអាចផ្តល់នូវបរិមាណឱសថឱ្យបាន គ្រប់គ្រាន់ ជាប្រចាំសម្រាប់ការមកពិគ្រោះ ជាប្រក្រតីដែល នៅតំបន់គម្រោងមិនគ្របដណ្តប់។

During 2022, the Ministry of Health launched the national scale HEQIP-II project. Among others, it aims to create a system for a continuum-of-care for patients with chronic Non-communicable Diseases such as Diabetes Mellitus and High Blood Pressure. The new system will give a more appropriate role to the Referral Hospitals and Health Centers with regards to these chronic conditions that remained unserviced in Cambodia’s primary care system for more than 3 decades. In the project the focus is on screening and registering new patients, leaving the challenge of the provision of adequate amounts of affordable routine (daily) medications between regular control visits outside the scope of the project.

វានឹងក្លាយជាបញ្ហាប្រឈមផងដែរ សម្រាប់អង្គការ ម.ព.ជ. ក្នុងការកំណត់តួនាទីរបស់ខ្លួន និងរបស់មិត្តអប់រំមិត្ត ដើម្បីឱ្យពួកគេមានការលើកទឹកចិត្តនៅក្នុងប្រព័ន្ធថ្មី នេះ។ វា ក៏ជាការប្រឈមរបស់អ្នកធ្វើគោលនយោបាយសុខាភិបាល ក្នុងការរៀបចំគ្រោងតួនាទីថ្មីនិងការដឹកនាំគាំទ្រ ដើម្បីឱ្យការងារដំណើរការបានស្របគ្នា និងបំពេញគ្នាបានជាមួយអ្នកស្ម័គ្រចិត្តសុខភាពតាមភូមិ។ វាអាចនឹងមានអ្នកទទួលខុសត្រូវច្បាស់លាស់ម្នាក់ សម្រាប់បញ្ហាជំងឺមិនឆ្លងនៅថ្នាក់ស្រុកប្រតិបត្តិ ដើម្បីទទួលខុសត្រូវលើការអនុវត្តគោលនយោបាយ។

លក្ខណៈចាំបាច់ពិសេសនៃការថែទាំជំងឺរ៉ាំរ៉ៃ បង្ហាញខាងក្រោម បានដាក់ក្នុងគម្រោង HEQIP ដំណាក់កាលទី២ ៖

១. រៀបចំកូដអត្តសញ្ញាណកម្មអ្នកជំងឺម្នាក់ៗ សម្រាប់កត់ត្រារាល់ព័ត៌មានទាក់ទងនឹងសេវាជំងឺមិនឆ្លង របស់អ្នកជំងឺ ដែលនឹងផ្តល់ភាពងាយស្រួលក្នុងការគ្រប់គ្រង និងវិភាគការព្យាបាលប្រកបដោយប្រសិទ្ធភាព ជាពិសេសការពិគ្រោះជំងឺ និងការផ្តល់ឱសថ (កំពុងរៀបចំនៅឡើយ)។

២. លុបបំបាត់ឧបសគ្គមិនគួរកើតមួយចំនួន ក្នុងការផ្តល់សេវាដូចជា បញ្ហាអ្នកជំងឺត្រូវពិគ្រោះជំងឺមុនពេលផ្តល់ថ្នាំម្តងៗ ហើយអនុញ្ញាតឱ្យអ្នកជំងឺប្រើវេជ្ជបញ្ជាចាស់ដើម្បីទទួលឱសថក្នុងរយៈពេលសមស្របណាមួយ។

៣. ផ្តោតលើការបង្កើតឱ្យភ្ជាប់បណ្តាញទំនាក់ទំនង ថែទាំបឋមនៅកន្លែងដែល ត្រូវការជាមួយកម្មវិធីសុខភាពសម្រាប់ជំងឺផ្សេងៗដូចជា របេង អេដស៍ និងរលាកថ្លើម C ជាដើម។

៤. ធ្វើវិមជ្ឈការសេវាថែទាំ ដោយធ្វើឱ្យមានសេវាសុខភាពនៅជិតអ្នកជំងឺ៖ បង្កើតតួនាទីមណ្ឌលសុខភាពដែលនៅឆ្ងាយពីមន្ទីរពេទ្យបង្អែក ក្នុងការផ្តល់សេវាថែទាំបន្តលើជំងឺ សម្រាប់អ្នកជំងឺដែលរស់នៅជិតមណ្ឌលសុខភាពទាំងនោះ ហើយឆ្ងាយពីមន្ទីរពេទ្យបង្អែក។

៥. ឯកភាពលើសូចនាករសុខភាពមួយចំនួន និងលទ្ធផលសម្រាប់ជំងឺរ៉ាំរ៉ៃ ដែលអាចរាយការណ៍អំពីប្រសិទ្ធភាពនៃសេវា សម្រាប់ក្រុមគោលដៅ (ត្រូវបានដាក់ក្នុងនិយាមថ្មី)។

It will be a challenge for MoPoTsyo to adapt its role and the peer educators, so they remain motivated and useful in new ways. Likewise, it will be a challenge for policy makers to frame their new role and the supportive supervision required to make it work complementary with the VHSG. There will be 1 focus person for NCD in the OD who will be important to implement such policies.

Key features of chronic care mentioned below are now being introduced in the HEQIP II such as:

1. Make that a unique Patient ID records all relevant chronic care data in such a way that they can be easily accessed for management and analysis of treatment effectiveness, including prescription and dispensing of medication; (in process)
2. Abolishing unnecessary barriers to care, such as the requirement that patients must first personally see the doctor "every time they only need a refill of their prescription medication;
3. Focus on creating functional linkages at primary care level, where useful, with other disease-programs, such as TB and HIV-AIDS, and Hep C.
4. Decentralizing care, by bringing care closer to people:

   Creating a role for health centers, located away from the referral hospital, for delivery of "maintenance chronic care" to patients who live closer to the health center than the referral hospital;
5. Including outcome data and indicators that reveal whether care is effective and to what extent it works for the target group (in new S.O.P.)

៦. លើកទឹកចិត្ត និងបង្ករឱកាសឱ្យអ្នកជំងឺ និងសហគមន៍របស់ពួកគេ អាចគ្រប់គ្រងជំងឺខ្លួនឯង បន្ថែមលើការពឹងផ្អែកលើគ្រូពេទ្យព្យាបាល និងសេវាព្យាបាល។

៧. រៀបចំឱ្យមានសកម្មភាព របស់ក្រុមទ្រទ្រង់សុខភាព៖ ពិពណ៌នាច្បាស់លាស់ អំពីតួនាទីរបស់ក្រុមទ្រទ្រង់សុខភាពស្ម័គ្រចិត្ត តួយ៉ាងដូចជាមិត្តអប់រំមិត្តជាដើម ដែលត្រូវការគាំទ្រដោយស្រុកប្រតិបត្តិសុខាភិបាល។ ពិពណ៌នាអំពីទំនាក់ទំនងផ្លូវការរវាងមិត្តអប់រំមិត្ត និងមណ្ឌលសុខភាពជាដើម។

6. Encouraging and enabling patients and communities of patients to self-manage instead of professionalising and medicalising simple services;

7. Framing lay-health worker activities: Officializing a clearly described lay-health worker role for specialized volunteers such as peer educators which will be supervised by the OD; formalize the relationship between the PE and the Health Center.

ការរួមបញ្ចូលមូលនិធិឱសថបង្វិលទុនក្នុងប្រព័ន្ធសុខាភិបាល

ផែនទីបង្ហាញផ្លូវ ឆ្ពោះទៅកាន់ការគ្របដណ្តប់សុខភាពជា សកលនៅកម្ពុជា (២០២៥-២០៣៥) បានលើកឡើងពីលទ្ធភាពនិងសក្តានុពលសម្រាប់មូលនិធិឱសថបង្វិលទុន (RDF)។ គំរូ RDF មានពីរនៅប្រទេសកម្ពុជា៖ ទីមួយផ្តល់មូលនិធិដោយ KOFIH (ប៉ៃលិន បាត់ដំបង និងពោធិ៍សាត់) និងគំរូ RDF របស់អង្គការ ម.ព.ជ.។ ធនាគារពិភពលោក និងដៃគូអភិវឌ្ឍន៍បានគាំទ្រការសិក្សាអំពីបទពិសោធន៍នៃគំរូ RDF ទាំងពីរនេះ ដើម្បីរៀបចំគំរូសមស្របមួយ។

បញ្ហាប្រឈមចំពោះគំរូ RDF អង្គការ ម.ព.ជ.៖ នៅពេលដែលយន្តការគាំពារសុខភាពសង្គមនៅកម្ពុជា បាននឹងកំពុងមានភាពប្រសើរឡើង បញ្ហាប្រឈមនៃប្រព័ន្ធឱសថបង្វិលទុនរបស់គំរូ RDF បានលេចឡើង ដែលទាមទារឱ្យមានការផ្លាស់ប្តូររបៀបនៃការបង្វិលទុនរបស់ RDF ម.ព.ជ.៖

- មិនមានទំនាក់ទំនងប្រតិបត្តិការរវាងប្រព័ន្ធបង្វិលទុនរបស់ RDF ម.ព.ជ. និងគម្រោងគាំពារសុខភាពសង្គមទេ។
- កម្មវិធីរបស់ ម.ព.ជ. គ្របដណ្តប់តិចតួច ដោយមានអ្នកជំងឺទឹកនោមផ្អែមនិងអ្នកជំងឺលើសសម្ពាធឈាមមួយភាគតូចដែលបានទទួលសេវាពីគំរូ RDF របស់ខ្លួន។

ក្រសួងសុខាភិបាល បាននឹងកំពុងផ្តល់អាទិភាពដល់ការថែទាំជំងឺទឹកនោមផ្អែម និងជំងឺលើសសម្ពាធឈាម ដោយវិនិយោគលើការបង្កើតការថែទាំបឋមសម្រាប់លក្ខខណ្ឌជំងឺទាំងនេះសម្រាប់ឆ្នាំ២០២៥៖

1. ការផ្គត់ផ្គង់ឱសថ៖

- ក្រសួងនឹងផ្គត់ផ្គង់ឱសថជាមូលដ្ឋាន ស្របពេលជាមួយគ្នាអង្គការ ម.ព.ជ. នឹងផ្តល់ឱសថ RDF ក្នុងលក្ខខណ្ឌបំពេញបន្ថែម។

Revolving Drug Funds Integration

Cambodia's Universal Health Coverage Plan (2024-2035) mentions a potential role for Revolving Drug Funds (RDFs). There are two RDFs in Cambodia: one funded by KOFIH (covering Pailin, Battambang, and Pursat) and MoPoTsyo's RDF. The World Bank and development partners supported a study on the experiences with these RDFs to design a suitable model.

Challenges to MoPoTsyo's model: as Cambodia's Social Health Protection mechanisms developing, structural challenges have emerged that require our intervention to change:

- No operational links exist between the MoPoTsyo system and social health protection schemes.
- MoPoTsyo has relatively low coverage, with only a fraction of diabetes and hypertension patients having access to care.

The Ministry of Health (MoH) is prioritizing diabetes and hypertension care, investing in the creation of primary care for these conditions for 2025;

1. Medicine Supply:

- MoH will supply basic medicines, while MoPoTsyo will provide complementary RDF medicines.

- មន្ទីរពេទ្យបង្អែកនិងមណ្ឌលសុខភាពនឹងប្រើប្រាស់ប្រព័ន្ធ EMR ជំនួស Database របស់ ម.ព.ជ.។

2. ការផ្លាស់ប្តូរផ្នែកហិរញ្ញវត្ថុ៖

- ម.ព.ជ.នឹងឈប់ប្រមូលភាគទានពីអ្នកជំងឺដោយផ្ទាល់លើសេវាឱសថ និងផ្គត់ផ្គង់ឱសថ RDF ដល់មូលដ្ឋានសុខាភិបាលសាធារណៈដោយផ្ទាល់វិញ។
- មន្ទីរពេទ្យបង្អែកនិងមណ្ឌលសុខភាព នឹងផ្តល់ហិរញ្ញប្បទាន សម្រាប់ការផ្គត់ផ្គង់ឱសថដោយ ម.ព.ជ. តាមរយៈប្រភពថវិកាពីថ្លៃសេវាហិរញ្ញប្បទាន (រហូតដល់ ៣៩%) និងកញ្ចប់ថវិកាទម្លាក់ពីរាជរដ្ឋាភិបាល។

3. គុណសម្បត្តិ៖

- លទ្ធភាពទទួលបានថ្នាំសម្រាប់គ្រប់អ្នកជំងឺទាំងអស់ មកប្រើសេវានៅមូលដ្ឋានសុខាភិបាលសាធារណៈ។
- គម្រោងគាំពារសុខភាពសង្គម នឹងសងថ្លៃសេវាមន្ទីរពេទ្យវិញ សម្រាប់អ្នកជំងឺដែលជាអ្នកទទួលផលពីគម្រោងទាំងនោះ។
- គ្មានអាករលើតម្លៃបន្ថែម ១០% លើការផ្គត់ផ្គង់ពី ម.ព.ជ. ចំពោះមន្ទីរពេទ្យណាមានវិញ្ញាបនបត្រលើកលែង។
- អ្នកជំងឺអាចទទួលបានឱសថ នៅជិតកន្លែងរស់នៅ។

ក្រសួងចង់ផ្គត់ផ្គង់ឱសថទឹកនោមផ្អែម និងលើសសម្ពាធឈាមទៅមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាពនៅទូទាំងប្រទេស ដើម្បីកាត់បន្ថយតម្រូវការឱសថពីមូលនិធិបង្វិលទុនរបស់ ម.ព.ជ.។ ជាក់ស្តែង កំឡុងឆ្នាំ២០២៥ ការផ្គត់ផ្គង់ឱសថពីក្រសួងសុខាភិបាលបានកើនឡើងខ្ពស់ ប៉ុន្តែមិនទាន់ទៀងទាត់និងមិនគ្រប់មុខឱសថតាមតម្រូវការ ដែលតម្រូវឱ្យមានការបំពេញបន្ថែមពីមូលនិធិបង្វិលទុនឱសថសម្រាប់រយៈពេល៣ត្រីមាសខាងដើមនៃឆ្នាំ២០២៥។ ប្រព័ន្ធផ្គត់ផ្គត់ទាំងពីរបានកើតឡើងជាដំណាក់ៗ ប៉ុន្តែមិនបានបញ្ចូលគ្នាឡើយ។ មូលដ្ឋានសុខាភិបាលជាដៃគូកត់ត្រាករណីប្រើសេវា និងរាយការណ៍ដោយឡែកពីគ្នាយ៉ាងច្បាស់លាស់។ ពួកគេមិន បានរាប់បញ្ចូលករណីប្រើសេវាគាំទ្រដោយ ម.ព.ជ. ក្នុងទម្រង់របាយការណ៍ផ្លូវការរបស់ក្រសួងឡើយ។ វាអាចយល់បានថាជួយការពារពីបញ្ហាកែប្រែឱសថមូលនិធិបង្វិលទុន ទៅជាការផ្គត់ផ្គង់ដោយក្រសួង ខណៈដែលការផ្គត់ផ្គង់មិនទាន់គ្រប់និងមិនទៀងទាត់នៅឡើយ និងការរាំងស្ទះដោយសារថ្លៃសេវាហិរញ្ញប្បទាននិងការបង់ជូសនៅទាប មិនអាចទូទាត់ថ្លៃដើមរបស់ ឱសថដែលខ្វះ។

- Hospitals and health centers will use Electronic Medical Records (EMR) to replace MoPoTsyo's database.

2. Financing Changes:

- MoPoTsyo will stop charging patients directly for medication and will sell RDF medicines to public primary care facilities directly.
- Hospitals and health centers must finance any MoPoTsyo's supplies through a combination of user fees (up to 39%) and government budget funds.

3. Advantages

- Access to medicines for all patients with prescriptions from the facility.
- Social health protection systems will reimburse hospitals for services provided to entitled patients.
- No 10% VAT on the sale of these medicines if public facilities have exemption certificate.
- Patients may receive medicines closer to their place of residence.

MoH aimed to supply medicines nationally through hospitals and health centers, reducing the need for MoPoTsyo's Revolving Drug Fund. In reality, during 2025 the MoH drug supply indeed increased in numbers but remained irregular and incomplete, leaving still an important role for MoPoTsyo's RDF, in particular during the first 3 quarters of 2025. The 2 systems existed side by side, but were NOT integrated. The counterpart Hospitals kept the case-recording and case reporting strictly separated: They did not report to MoH on the standard forms about the MoPoTsyo patient cases using the RDF, understandably to prevent the switch to MoH supply as long as that supply was incomplete and irregular AND because the levels of userfees and reimbursements were too low to cover the costs of the medicines that were still lacking.

ការបន្តនិងការពង្រីកបណ្តាញមិត្តអប់រំមិត្ត CONTINUATION & EXPANSION OF THE NETWORKS

កិច្ចប្រជុំនៅទីស្តីការក្រសួងសុខាភិបាល រវាងក្រុមការងារបង្កើតគោលនយោបាយនិងអង្គការ ម.ព.ជ. នាថ្ងៃទី២៨ វិច្ឆិកា ២០២៤ ជាចំណុចចាប់ផ្តើមរបត់ថ្មីនៃកម្មវិធីបណ្តាញមិត្តអប់រំមិត្ត។ បណ្តាញមិត្តអប់រំមិត្តគឺមិនទទួលបានការគាំទ្របន្តទៀតឡើយ។ មិត្តអប់រំមិត្តចូលរួមសកម្មភាពពិគ្រោះ តាមវេន និងប្រមូលភាគទានសេវាតាមរយៈគូប៉ុង ការរៀបចំអ្នកជំងឺប្រមូលសំណាកឈាមបង់បង្កាន់ដៃសេវា និងការចែកចាយឱសថមូលនិធិបង្វិលទុននៅក្នុងមូលដ្ឋានសុខាភិបាលសាធារណៈ គឺជាសកម្មភាពបីសំខាន់ៗ ដែលត្រូវតែបញ្ឈប់។ រយៈពេលពេញមួយឆ្នាំ២០២៥ អង្គការ ម.ព.ជ. ព្យាយាមជួបពិគ្រោះយោបល់គ្រប់មូលដ្ឋានសុខាភិបាលសាធារណៈ ការិយាល័យស្រុកប្រតិបត្តិ និងមន្ទីរសុខាភិបាលទាំង១២ ដើម្បីរកដំណោះស្រាយបញ្ចូលសកម្មភាពមិត្តអប់រំមិត្តក្នុងសេវាសាធារណៈ តាមរយៈគំរូដែលអង្គការ ម.ព.ជ. ផ្គត់ផ្គង់ឱសថបង្វិលទុនពេលណាការផ្គត់ផ្គង់ពីរដ្ឋមានខ្វះចន្លោះ និងគាំទ្រមូលដ្ឋានសុខាភិបាលផ្តល់សេវាដោយខ្លួនឯង។ ប៉ុន្តែមូលដ្ឋានសុខាភិបាលដៃគូទាំងអស់ មិនព្រមសាកល្បងប្រព័ន្ធថ្មីនេះឡើយ ដោយសារមិនមានលទ្ធភាពបង់ត្រឡប់។ ខ្វង់ចវិកាហិរញ្ញប្បទានសេវានិងបញ្ចប់គាំទ្រដោយចវិការដ្ឋ មិនគ្រប់គ្រាន់ឡើយ។

ការមិនអាចស្វែងរកមធ្យោបាយនៃការរួមបញ្ចូលសកម្មភាពមិត្តអប់រំមិត្តក្នុងសេវាសាធារណៈ ធ្វើឱ្យអង្គការ ម.ព.ជ. មិនអាចធ្វើការពង្រីកបណ្តាញមិត្តអប់រំមិត្ត ដូចមានក្នុងផែនការនៃកិច្ចព្រមព្រៀមឆ្នាំ២០២៤-២០២៦ បានឡើយ។ សកម្មភាពរបស់អង្គការត្រូវដើរថយក្រោយ នៅពេលដែលប្រព័ន្ធសុខាភិបាលរដ្ឋ ចាប់ផ្តើមបង្កើនកញ្ចប់សេវាដែលមិនមានកាលពីប្រមាណជាង ២០ឆ្នាំមុន។

គិតចាប់ពីឆ្នាំ២០២៤ រហូតដល់ដំណាច់ឆ្នាំ២០២៥ អង្គការ ម.ព.ជ. បានពង្រីកបណ្តាញមិត្តអប់រំមិត្តនៅស្រុកប្រតិបត្តិថ្មីតែមួយគត់ គឺស្រុកប្រតិបត្តិបរិបូណ៌ា ខេត្តកំពង់ឆ្នាំង។ អង្គការ មិនអាចពង្រីកបណ្តាញទៅកាន់ខេត្តទី១៣ ដូចមានចែងក្នុងកិច្ចព្រមព្រៀងជាមួយក្រសួង។

ជាលទ្ធផលមក តំបន់គ្របដណ្តប់បណ្តាញមិត្តអប់រំមិត្តបានថយចុះពី ២៩ស្រុកប្រតិបត្តិក្នុងរាជធានី/ខេត្តចំនួន១២ មកនៅត្រឹម ២៥ស្រុកប្រតិបត្តិក្នុង១១រាជធានី/ខេត្ត នៅត្រឹមដំណាច់ឆ្នាំ២០២៥។ ស្រុកប្រតិបត្តិទាំងនោះមាន៖ ភ្នំពេញ (សែនសុខ មេគង្គ ពោធិ៍សែនជ័យ)

The meeting at MoH between MoH policy markers and MoPoTsyo on 28 November 2024 was a turning point of PE network program. The existing model of PE program was no longer acceptable. PEs involved in consultation by charging a fee through the coupon, paid laboratory samples collection, and paid revolving drug fund medicines were the three activities that had to stop somehow. During 2025, MoPoTsyo tried to meet with all health counterparts from local to provincial levels in 12 provinces to find a possible solution for integration PE activities into the public health service by MoPoTsyo supplying RDF medicines to HFs while letting the HFs run the services by themselves. HFs pay for complementary RDF medicines when the CMS's medicines supply is not enough. However, non of HFs agreed to pilot this idea because HFs could not finnace the cost of RDF medicines. User fee income plus government budget is not enough to pay for the shortages.

The consequence of the lack of integration (see previous paragraph), meant that we did not expand the peer educator networks as had been planned in our MoU 2024-2026. An NGO has to step back when the national health system – by its 20 years late – starts to develop the service package that was previously non-existent.

Since 2024 until the end of 2025, MoPoTsyo had expanded the PE program to only one new operational district – Boribo, Kampong Chhnang province. We did not expand to the 13th province as in MoU.

As a result, the program overage ODs was decreased from 29 ODs in 12 provinces in 2024 to 25 ODs in 11 provinces by the end of 2025. Those 11 provinces are; Phnom Penh (Sen Sok, Mekong & Por Senchey),

តាកែវ (ស្រុកប្រតិបត្តិដូនកែវ ព្រៃកប្បាស អង្គរកោ និងកោះអណ្តែត) បន្ទាយមានជ័យ (ស្រុកប្រតិបត្តិថ្មពូក) កំពង់ស្ពឺ (គ្រប់ស្រុកប្រតិបត្តិទាំង៤) កំពង់ធំ (ស្រុកប្រតិបត្តិបារាយណ៍-សន្ទុក និងស្ទោង) កំពត (ស្រុកប្រតិបត្តិអង្គរជ័យ) កំពង់ចាម (ស្រុកប្រតិបត្តិចំការលើ កងមាស ជើងព្រៃ) ស្វាយរៀង (គ្រប់ស្រុកប្រតិបត្តិទាំង៤) កំពង់ឆ្នាំង (ស្រុកប្រតិបត្តិបរិបូណ៌) កណ្តាល (ស្រុកប្រតិបត្តិខ្សាច់កណ្តាល) និងត្បូងឃ្មុំ (ស្រុកប្រតិបត្តិក្រូចឆ្មារ)។

បណ្តាញចាស់ៗខេត្តតាកែវ គឺមានការប្រែប្រួល។ បណ្តាញ២ស្រុកប្រតិបត្តិក្នុងចំនោម៦ស្រុកប្រតិបត្តិ ត្រូវបានបញ្ចប់ការគាំទ្រទាំងស្រុង គឺស្រុកប្រតិបត្តិបាទី និងគិរីវង់។ ចំណែកស្រុកប្រតិបត្តិកំពង់ត្រឡាចខេត្តកំពង់ឆ្នាំង ក៏ត្រូវបានបញ្ចប់ការគាំទ្រទាំងស្រុងផងដែរ។ ចំណែក បណ្តាញមិត្តអប់រំមិត្តនៅក្នុងស្រុកប្រតិបត្តិឆ្លូង ខេត្តក្រចេះ បានបញ្ចប់សកម្មភាពតាំងពីថ្ងៃទី១២ ឧសភា ២០២៥ មកម្ល៉ះ។

Takeo (Ang Roka, Daun Keo, Prey Kabas, and Koh Andaet), Banteay Meanchey (Thmar Pouk), Kampong Speu (all 4 ODs), Kampong Thom (Baray-Santuk&Stoung), Kampot (Angkor Chey), Kampong Cham (Chamkar Leu, Cheung Prey & Kang Meas), Svay Rieng (all 4 ODs), Kampong Chhnang (Boribou), Kandal (Ksach Kandal), and Tboung Khmum (Krouch Chhmar).

The old model PE networks in Takeo had been stopped in two ODs – Bati and Kirivong. In Kampong Chhnang, PE network in Kampong Tralach didn't get new contract since 2024. The agreement with this OD ended since 2023. Kratie provincial health department decided not to renew contract for PE program in Chhlong and the PE program in Chhlong had to end by 12 April 2025.

រូបភាពទី 1៖ ទីតាំងបណ្តាញមិត្តអប់រំមិត្តនៅកម្ពុជាឆ្នាំ២០២៥ Locations of Peer Educator Networks in Cambodia in 2025

បណ្តាញមិត្តអប់រំមិត្តនៅក្នុងក្រុងភ្នំពេញ ត្រូវបានគិតថា មានតែ៣ស្រុកប្រតិបត្តិ គឺពោធិ៍សែនជ័យ សែនសុខ និងមេគង្គ ដោយសារ យើងមិនមានកិច្ចព្រមព្រៀងជាមួយស្រុកប្រតិបត្តិផ្សេងទៀតឡើយ។ មិត្តអប់រំមិត្តចំនួន៥ នាក់ដែលមិនស្ថិតក្នុងស្រុកប្រតិបត្តិទាំង៣ខាងលើ ក្នុងនោះមិត្តអប់រំមិត្ត៣នាក់នៅក្នុងស្រុកប្រតិបត្តិចតុមុខ ១នាក់នៅក្នុងស្រុកប្រតិបត្តិបាសាក់ និង១នាក់ទៀតនៅក្នុងស្រុកប្រតិបត្តិព្រែកព្នៅ។ ចំណែកស្រុកប្រតិបត្តិពាមរ៉ក្នុងខេត្តព្រៃវែង គឺនៅតែស្ថិតក្នុងផែនការពង្រីកបណ្តាញ ទោះបីជាការពង្រីកបណ្តាញទៅកាន់ទីនោះ មិនអាចធ្វើបានតាមផែនការក៏ដោយ។

The Peer Educator Network in Phnom Penh is counted for the moment as 3 ODs: Por Senchey, Sen Sok, and Mekong because we did not yet have MoA with other ODs. There are 5 active peers reside outside these 3 contracted ODs; 1 peer from Chaktomuk, 1 peer from Bassac, and 1 peer from Praek Pnov. Moreover, Peam Ror OD, in Prey Veng province is unlikely to be realized under this MoU.

ការចំណាយ និងថ្លៃចំណាយ EXPENSES AND COSTS

ចាប់ពីឆ្នាំ២០១៦មក អង្គការ ម.ព.ជ. បានប្រើប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ Modified Cash សម្រាប់ប្រព័ន្ធគណនេយ្យ ដោយផ្អែកលើក្រុមសវនកម្ម CAM Accounting & Taxation ដែលជាសមាជិកនៃ Kreston International។ តម្រូវតាមស្ថានភាពគម្រោងកម្មវិធី ការគ្រប់គ្រងហិរញ្ញវត្ថុរបស់អង្គការ ត្រូវបានកែលម្អបន្ថែម។ ចាប់ពីឆ្នាំ២០២៣ អង្គការបានផ្លាស់ប្តូរប្រព័ន្ធគណនេយ្យពីគណនេយ្យសាច់ប្រាក់ (Modified cash) ទៅជាមូលដ្ឋានគណនេយ្យបង្គរ (Accrual bases) និងបានបន្តប្រើប្រព័ន្ធនេះ រហូតឆ្នាំ២០២៥ សម្រាប់សកម្មភាពដែលមានចំណូលចូលអង្គការពីភាគទានសេវា។ គណនេយ្យសាច់ប្រាក់នៅបន្តប្រើ សម្រាប់សកម្មភាពដែលប្រើប្រភពចំណូលពីជំនួយសប្បុរសធម៌។ ប្រព័ន្ធគណនេយ្យទាំងពីរនេះ ត្រូវដាក់រួមគ្នាសម្រាប់ការធ្វើសវនកម្មប្រចាំឆ្នាំ ដោយក្រុមហ៊ុនសវនកម្ម KPMG។

From 2016 onward we have been using “modified cash” basis for accounting as agreed with the auditor at that time, CAM Accounting & Taxation, the Cambodian member of Kreston International, website https://kreston.com/. In order to improve the financial management, MoPoTsyo had changed the accounting system from Modified Cash to Accrual Basis from the start of 2023 and the accrual basis continued to be used in 2025 for the income generating activities of our NGO whereas cash-base accounting is used for donor funded activities. The NGO and Social enterprise accounts are consolidated and audited every year. For the period 2024-2026 KPMG was selected as our yearly auditor.

យោងតាមរបាយការណ៍ផ្ទៃកហិរញ្ញវត្ថុ ដូចបានបង្ហាញក្នុងតារាងខាងក្រោមនេះ បានឱ្យឃើញថា នៅក្នុងឆ្នាំ២០២៥ យើងទទួលបានចំណូលសរុបពីប្រភពទាំងអស់ ប្រមាណជាង ៥.៥៥២លានរៀល និងបានចំណាយអស់ប្រមាណជាង ៥.៦៨០លានរៀល ដូចបានលំអិតជូនក្នុងតារាងខាងក្រោមនេះស្រាប់។

As shown in the table below, in 2025 MoPoTsyo received fund from all sources about 5,552 million riels. In the same period, we had spent for all expenses about 5,680 million riels. The following table is a detailed breakdown of MoPoTsyo’s total Profit & Loss accounts.

តារាងទី 2៖ របាយការណ៍ចំណូលចំណាយសម្រាប់ឆ្នាំ២០២៥ ***Report on revenues and expenditures in 2025***

<u>របាយការណ៍ចំណូលចំណាយ សំរាប់ឆ្នាំ២០២៥ (ថ្ងៃទី ១ខែមករា ដល់ថ្ងៃទី ៣១ធ្នូ)</u>

អត្រាប្តូរប្រាក់ ថ្ងៃទី ៣១ធ្នូ ២០២៥ ១ដុល្លា: **4,013**

ចំណូល	ទូរទាំងឆ្នាំទី១ (២០២៥)		ចំណូល (រៀល) ០១មករា ដល់ ៣០ មិថុនា	ចំណូល (រៀល) ០១កក្កដា ដល់ ៣១ ធ្នូ	សរុបចំណូល (រៀល) ក្នុងឆ្នាំ២០២៥	
	USD	KHR				
ចំណូលទទួលបានពីម្ចាស់ជំនួយ			383,585,280	-	383,585,280	
ចំណូលទទួលបានពីភាគទានរបស់សមាជិកអ្នកជំងឺ			2,614,496,372	2,553,944,143	5,168,440,515	
សរុបចំណូល			**2,998,081,652**	**2,553,944,143**	**5,552,025,795**	
			ចំណាយ (រៀល) ១មករាដល់៣០មិថុនា	**ចំណាយ (រៀល) ០១កក្កដា ដល់ ៣១ ធ្នូ**	**សរុបចំណាយ (រៀល) ក្នុងឆ្នាំ២០២៥**	**Variance**
១.ចំណាយលើបុគ្គលិកក្នុងស្រុក	$ 395,021	1,585,219,273	857,988,968	848,663,058	1,706,652,026	-8%
២.ចំណាយលើបុគ្គលិកបរទេស	$ -	-	-	-	-	
៣.ចំណាយលើការិយាល័យ	$ 58,853	236,177,089	66,261,680	60,795,295	127,056,975	46%
៤.តាំទ្រដល់កិច្ចការផ្សេងៗ	$ -	-	-	-	-	
៥.ចំណាយលើការបណ្តុះបណ្តាល	$ 224,265	899,975,445	38,912,000	37,736,000	76,648,000	91%
៦.ចំណាយលើការសង្គ្រោះបន្ទាន់	$ -	-	-	-	-	
៧.ចំណាយលើការសាងសង់ជួសជុល	$ 13,653	54,789,489	5,402,865	-	5,402,865	90%
៨.ទំនិញ-សម្ភារៈ (ឱសថ-ការិយាល័យ)	$ 802,421	3,220,115,473	969,434,355	975,333,429	1,944,767,784	40%
៩.ទំនិញ-បរិក្ខារ(ជដ្ឋសាស្ត្រ ឱសថ សំភារៈ ផ្សេងៗ)	$ 20,000	80,260,000	53,452,315	64,699,170	118,151,485	-47%
១០.ទំនិញ-មធ្យោបាយដឹកជញ្ជូន (រថយន្ត ម៉ូតូ រថយន្តគិលានសង្គ្រោះ)	$ -	-	31,045,626	29,566,556	60,612,182	
១១.ចំណាយលើការប្រតិបត្តិការ	$ 612,174	2,456,654,262	494,665,003	1,082,513,161	1,577,178,163	36%
១២.ការតាមដាន វាយតម្លៃ	$ 24,667	98,988,671	23,341,903	32,978,340	56,320,243	43%
១៣.ចំណាយលើការផ្សព្វផ្សាយ	$ 9,895	39,708,635	2,228,817	5,656,667	7,885,484	80%
១៤.មូលនិធិបម្រុង	$ -	-	-	-	-	
សរុប	**$ 2,160,949**	**8,671,888,337**	**2,542,733,532**	**3,137,941,675**	**5,680,675,207**	**34%**
					(128,649,413)	
សមតុល្យដើមគ្រា ០១ មករា២០២៥					**3,440,159,257**	
បំណុលត្រូវសង					**223,952,927**	
សមតុល្យចុងគ្រា					**3,535,462,772**	

របាយការណ៍ខាងក្រោមនេះ គឺជាការគណនានៃការចំណាយ និងថ្លៃដើមសេវានីមួយៗ។ តួរលេខនៃការចំណាយបង្ហាញថាសេដ្ឋកិច្ចមាត្រដ្ឋាន រក្សាបាននូវការចំណាយទាបសម្រាប់មនុស្សពេញវ័យម្នាក់។

The following report presents calculations of both expenses and costs per service unit. The expense figures show that economies of scale keep the expenses per covered adult stable.

មនុស្សពេញវ័យម្នាក់ដែលបានគ្របដណ្តប់ ត្រូវបានកំណត់ជាមនុស្សម្នាក់ ដែលធ្លាប់បានស្គាល់ជាមួយបណ្តាញតាមរយៈការចូលរួមរបស់គាត់ទៅក្នុងការធ្វើតេស្តស្ករក្នុងទឹកនោម និងរស់នៅក្នុងតំបន់ដែលគ្របដណ្តប់ដោយបណ្តាញមិត្តអប់រំមិត្តមួយ។

A covered adult is defined as a person who is familiar with the network through his/her participation in the diabetes raising awareness activities and who lives in an area covered by a PE network.

មនុស្សពេញវ័យដែលគ្របដណ្តប់ គឺជាអ្នកដែលសមាជិកភាពរបស់ពួកគេគឺអាចចុះឈ្មោះបាន ពេលណាគាត់កើតជំងឺទឹកនោមផ្អែម ហើយមិនចាំបាច់ជាសមាជិក ពីព្រោះអ្នកដែលទទួលបានផលប្រយោជន៍គឺ អ្នករាល់គ្នាដែលបានស្រាវជ្រាវសម្រាប់ជំងឺទឹកនោមផ្អែម។ ហេតុផលសម្រាប់ការប្រើប្រាស់នូវអត្ថន័យនេះ គឺផ្អែកលើទ្រឹស្តី រាល់មនុស្សពេញវ័យដែលទទួលស្ទ្រីបទឹកនោម សម្រាប់ការធ្វើតេស្តទឹកនោមដោយខ្លួនឯង គឺបានដឹងថា មានបណ្តាញមិត្តអប់រំមិត្តរស់នៅក្នុងតំបន់របស់គាត់ដោយអាចជួបបានគ្រប់ពេលវេលា ដើម្បីធ្វើតេស្តម្តងទៀត ឬអាចផ្តល់ព័ត៌មាន។ បើល្អបំផុត តាមភូមិនីមួយៗគួរតែមានក្រុមលើសសម្ពាធឈាម ប៉ុន្តែជាក់ស្តែងក្រុមនេះមិនត្រូវបានបង្កើត និងគ្មានធនធានដើម្បីបន្តដំណើរការឡើយ។

A covered adult is someone for whom membership is open, so not necessarily yet a member, because the beneficiaries are everyone who has been screened for diabetes. The rationale for using this definition is as following: Theoretically, every adult who has received a urine glucose strip for self-testing for diabetes, is aware that the peer educator is living in her/his area and available any time to do a blood glucose test or provide information. Ideally, there is High-Blood Pressure Group in this village, but in reality, it is not always been set up and there is not enough continuous input to keep them functional.

អង្គការ ម.ព.ជ. បានបង្កើតក្រុមលើសសម្ពាធឈាមតាមភូមិខ្លះៗរួចមកហើយ ប៉ុន្តែយើងមិនបានពង្រីកវាបន្ថែមឡើយ ពីព្រោះតែការចំណាយខ្ពស់។ យន្តការគាំទ្រនិងលើកទឹកចិត្តក្រុមនេះ ត្រូវការពិនិត្យឡើងវិញ និងត្រូវចូលរួមគាំទ្រដោយមណ្ឌលសុខភាព។

MoPoTsyo had set up some of this kind of HBPG in some villages but we did not expand this project because of high cost. The procedure to support and motivate the groups needs to be revised to involve a link with the Health Center.

ការចូលរួមអន្តរាគមន៍កាន់តែច្រើន គឺវាបានធ្វើឱ្យកាន់តែមានប្រសិទ្ធភាពជាមួយចំនួនដ៏ច្រើននៃអ្នកទទួលបានផលប្រយោជន៍ គឺទទួលបានសេវាជាមួយនឹងចំណាយទាបជាង។ ការចំណាយសម្រាប់មនុស្សពេញវ័យម្នាក់ ដែលធ្វើការស្រាវជ្រាវត្រូវបានបំបែកជាអត្ថប្រយោជន៍ផ្សេងៗគ្នា ដែលមនុស្សពេញវ័យទាំងនេះអាចទទួលបាន អាស្រ័យទៅលើស្ថានភាពរៀងខ្លួនរបស់ពួកគេ ដូចបានឃើញនៅក្នុងតារាងខាងលើ។ ការផ្តល់នូវអត្ថប្រយោជន៍ គឺវាអាស្រ័យទៅលើតម្រូវការបុគ្គលម្នាក់ៗដោយតម្រូវការទាំងនេះមិនដូចគ្នាទេ។

With growth, the intervention is becoming more efficient, as larger numbers of beneficiaries are being served for less money. The expenses per screened adult have been broken down in different types of benefits that these adults can receive, depending on their individual situation as can be seen in the table above. The provision of benefits depends on the needs of the individual as these needs are not the same for everyone.

តារាងទី ៣៖ ការចំណាយសម្រាប់អ្នកទទួលបានផលប្រយោជន៍ឆ្នាំ២០០៧_២០២៥ Expenses per Beneficiary 2007 – 2025

Beneficiaries/expenses trend from 2007 to 2025 [in adults covered through the Peer Educator Networks in USD]																			
Years **End of month December**	**2007**	**2008**	**2009**	**2010**	**2011**	**2012**	**2013**	**2014**	**2015**	**2016**	**2017**	**2018**	**2019**	**2020**	**2021**	**2022**	**2023**	**2024**	**2025**
Beneficiaries Annual growth %		143%	40%	57%	53%	91%	22%	27%	12%	18%	10%	0%	5%	4%	1%	1%	2%	14%	14%
Beneficiaries																			
Number of total population in OD's with PE	1,109,287	1,109,287	1,466,213	2,322,262	2,322,262	2806790	3,067,517	3,067,517	3,067,517	3,067,517	3,067,517	3,067,517	3,067,517	3,446,369	3,641,635	4,037,776	4,533,859	4,650,140	4,650,140
Number population at NCD risk (=adults)	632,294	632,294	835,741	1,323,689	1,323,689	1,599,870	1,748,485	1,748,485	1,748,485	1,748,485	1,748,485	1,748,485	1,748,485	1,964,430	2,075,732	2,301,532	2,584,300	2,650,580	2,650,580
Nr of covered&screened adults	**29,335**	**71,329**	**99,839**	**156,860**	**240,550**	**460,514**	**560,276**	**712,550**	**795,356**	**941,455**	**1,035,227**	**1,035,227**	**1,085,798**	**1,133,416**	**1,140,481**	**1,155,328**	**1,178,729**	**1,318,796**	**1,345,429**
Coverage of Total Population	2.6%	6.4%	6.8%	6.8%	10.4%	16.4%	18.3%	23.2%	25.9%	30.7%	33.7%	33.7%	35.4%	32.9%	31.3%	28.6%	26.0%	28.4%	28.9%
Coverage of target population at risk	4.6%	11.3%	11.9%	11.9%	18.2%	28.8%	32.0%	40.8%	45.5%	53.8%	59.2%	59.2%	62.1%	57.7%	54.9%	50.2%	45.6%	49.8%	50.8%
Total Expenses Annual growth %		120%	44%	37%	63%	23%	25%	-3%	-6%	28%	19%	4%	4%	22%	2%	19%	17%	-9%	-9%
Total Annual Expenses [in USD]	$59,808	$131,725	$189,773	$260,446	$424,518	$521,013	$653,552	$635,385	$595,280	$763,952	$907,840	$945,220	$985,775	$1,206,995	$1,227,962	$1,455,253	$1,706,458	$1,557,929	$1,415,568
Accumulated expenses of whole intervention		$191,533	$381,307	$641,752	$1,066,270	$1,587,283	$2,240,835	$2,876,220	$3,471,500	$4,235,452	$5,143,292	$6,088,512	$7,074,287	$8,281,282	$9,509,244	$10,964,497	$12,670,955	$14,228,884	$15,644,452
Expenses per Unit per beneficiary [in USD]																			
per population	$0.05	$0.12	$0.13	$0.11	$0.18	$0.19	$0.21	$0.21	$0.19	$0.25	$0.30	0.30814	$0.32	$0.35	$0.34	$0.36	$0.38	$0.34	$0.30
per population at risk (all adults) of NCD	$0.09	$0.21	$0.23	$0.20	$0.32	$0.33	$0.37	$0.36	$0.34	$0.44	$0.52	$0.54	$0.56	$0.61	$0.59	$0.63	$0.66	$0.59	$0.53
per covered & screened adult	**$2.04**	**$1.85**	**$1.90**	**$1.66**	**$1.76**	**$1.13**	**$1.17**	**$0.89**	**$0.75**	**$0.81**	**$0.88**	**$0.91**	**$0.91**	**$1.06**	**$1.08**	**$1.26**	**$1.45**	**$1.18**	**$1.05**

បន្ទាប់ពីមានបណ្តាញមិត្តអប់រំមិត្តត្រូវបានបង្កើត និងបានធ្វើការស្រាវជ្រាវក្នុងភូមិមួយហើយ ជាក់ស្តែងប្រជាជនដែលបានទទួលផលពីកម្មវិធី គឺជាចំនួនប្រជាជននៃភូមិទាំងមូល រួមទាំងក្មេង មនុស្សពេញវ័យអ្នកទឹកនោមផ្អែម អ្នកអាចត្រៀមនឹងកើតជំងឺទឹកនោមផ្អែម និងអ្នកអាចត្រៀមនឹងកើតជំងឺលើសសម្ពាធឈាម។ ប្រព័ន្ធនៃបណ្តាញមិត្តអប់រំមិត្តគឺរៀបចំទុកដើម្បីទទួលពួកគេ នៅពេលដែលពួកគេក្លាយទៅជាអ្នកទឹកនោមផ្អែម ឬអ្នកលើសសម្ពាធឈាម។

Once the peer educator network is established and has distributed urine strips in a village, in fact the entire village population is covered, whether they are still a child, a healthy adult, a diabetic, pre-diabetic or pre-hypertensive. The system is ready to receive them when healthy adults become diabetic or hypertensive.

GIZ បានបញ្ឈប់ការគាំទ្រថវិកានៅត្រីមាសទីបួន ឆ្នាំ ២០១៤ មិត្តអប់រំមិត្តបានចាប់ផ្តើមគិតប្រាក់ពីអ្នកជំងឺថ្មី ដែលចង់ចុះឈ្មោះជាសមាជិកនៃបណ្តាញនេះ ចំនួន២០,០០០ រៀលសម្រាប់អ្នកជំងឺទឹកនោមផ្អែមម្នាក់ និង១៥,០០០រៀលសម្រាប់អ្នកជំងឺលើសសម្ពាធឈាមមិនមានទឹកនោមផ្អែម។

When GIZ stopped funding from 4th quarter of 2014, PEs started to charge new patients who want to register as member of the network, 20,000 Riel for a diabetic and 15,000 Riel to patients with hypertension without diabetes.

គិតត្រឹមដំណាច់ឆ្នាំ២០២៥ អង្គការ ម.ព.ជ. បានចំណាយសរុបប្រមាណ ១៥.៦៤៤.៤៥២ដុល្លារអាមេរិក គិតចាប់តាំងពីចាប់ដំណើរការកម្មវិធីក្នុងឆ្នាំ២០០៥ មក។ ថវិកាចំណាយទាំងអស់ក្នុងរយៈពេលជាង២០ឆ្នាំ បានផ្តល់អត្ថប្រយោជន៍ដល់ពលរដ្ឋកម្ពុជាជាច្រើននាក់ ជាពិសេសដល់មនុស្សពេញវ័យ តាមរយៈការយល់ដឹងអំពីកត្តាប្រឈមនិងរោគសញ្ញានៃជំងឺ។ ក្នុងចំណោមពួកគេ មានអ្នកជំងឺប្រមាណជាង ៨ម៉ឺននាក់ដែលបានចុះឈ្មោះក្នុងបណ្តាញមិត្តអប់រំមិត្ត។ បន្ទាប់ពីអង្គការ ម.ព.ជ. ចាប់ផ្តើមសកម្មភាពដែលត្រូវបង់ភាគទានសម្រាប់សេវា ហិរញ្ញវត្ថុមួយផ្នែកធំ គឺបានមកពីការចូលរួមចំណែកថវិការបស់សមាជិក។ ក្នុងឆ្នាំ២០២៥ អង្គការទទួលបានថវិកាគាំទ្រដោយម្ចាស់ជំនួយត្រឹមតែ ១២%ប៉ុណ្ណោះ។ បើយើងប្រមើលមើលពីការធ្លាក់ចុះនៃប្រភពថវិកាពីសមាជិកនាពេលខាងមុខ ចាប់ពីឆ្នាំ២០២៦តទៅ ភាគរយនៃថវិកាគាំទ្រដោយម្ចាស់ជំនួយត្រូវការបង្កើនឡើងវិញ ដើម្បីមាននិរន្តរភាពរបស់អង្គការ។ មានន័យថា អង្គការត្រូវការពឹងផ្អែកខ្លាំងលើថវិកាម្ចាស់ជំនួយជាថ្មីម្តងទៀត។

By the end of 2025, we have spent 15,644,452 USD dollars since we began operations in 2005. This total amount spent over 20 years benefitted many Cambodians, mainly adults through awareness of risk factors and symptoms and among them more than 80,000 patients who registered as members. Since 2014, when the NGO began to charge fees, most of the NGO's financing has been from patient contributions. In 2025, around 12% of what we spent on our NGO activities came from external donors. If we foresee a reduced role in paid medical service provision from 2026 onward, this % from donor funding must rise again in the coming years to sustain our NGO. In other words, we will become very much donor dependent again.

កំណើនសមាជិក ក្នុងបណ្តាញមិត្តអប់រំមិត្ត MEMBERSHIP GROWTH

រៀងរាល់ឆ្នាំ យើងបានធ្វើការបូកបញ្ចូលចំនួនករណីថ្មីដែលបានចុះឈ្មោះក្នុងឆ្នាំ បន្ថែមលើចំនួនចុះឈ្មោះដែលមានស្រាប់។ ក្រាហ្វខ្សែនីមួយៗ តំណាងឱ្យចំនួនសរុបបូកបន្តនៃសមាជិកជាអ្នកជំងឺពុំរ៉ៃមិនឆ្លង ដែលទទួលផលប្រយោជន៍ពីបណ្តាញមិត្តអប់រំមិត្តចាប់តាំងពីឆ្នាំ២០០៥។ បើពួកយើងចង់ដឹងថា មានអ្នកជំងឺប៉ុន្មាននាក់ ដែលបាននឹងកំពុងទទួលផលប្រយោជន៍ពីសេវាមិត្តអប់រំមិត្តក្នុងឆ្នាំ២០២៥ យើងត្រូវដកអ្នកគ្រប់គ្នាដែលបានដឹងថា ជាអ្នកជំងឺដែលបានស្លាប់ និងអ្នកជំងឺដែលមិនប្រើប្រាស់សេវា អំឡុងឆ្នាំ២០២៥។

Every year, we add the newly registered members to the existing members since the program started. The lines represent the accumulation of chronic patients who have benefited from the Peer Educator Networks since 2005. If we want to know how many individual patients were actually benefiting during the year 2025, we have to deduct everybody of whom we know that they have died and who did not use the peer educator networks during the year 2025.

រូបភាពទី 2៖ ការកើនឡើងសមាជិកភាព Growing membership



ជាលទ្ធផល គឺអ្នកជំងឺដែលបានចុះឈ្មោះប្រមាណ ២៧៦៥៥នាក់ កំពុងបន្តប្រើប្រាស់សេវាយ៉ាងសកម្មនៅក្នុងឆ្នាំ ២០២៥ ប៉ុន្តែចំនួននេះគឺមានការថយចុះជាងឆ្នាំ២០២៤ ទោះបីជាបានបន្ថែមចំនួនអ្នកជំងឺថ្មីប្រមាណ៤៩១៦នាក់ក៏ដោយ។ ក្នុងចំណោមពួកគេ មានអ្នកជំងឺទឹកនោមផ្អែមចំនួន ២៣១៥២នាក់ និងអ្នកជំងឺលើសសម្ពាធឈាមចំនួន៤៥០៣ នាក់។ តួរលេខទាំងនេះ ត្រូវបានគណនាជាស្វ័យប្រវត្តិដោយប្រព័ន្ធទិន្នន័យ បានប្រមូលកំណត់ត្រានៃការប្រើសេវារបស់អ្នកជំងឺម្នាក់ៗ ប៉ុន្តែវាផ្អែកលើទិន្នន័យដែលត្រូវបានបញ្ចូលនិងសម្អាតរួចក្នុងប្រព័ន្ធទិន្នន័យ។ ជាក់ស្តែង ភាពខ្សោយនៃរបាយការណ៍ បានធ្វើឱ្យតួរលេខនៃសមាជិកកំពុងប្រើសេវាជាក់ស្តែងអាចខ្ពស់ជាង។

The result is that 27,655 registered patients were actively using the services in 2025. Even if 4,916 newly registered patients are included, this figure is still lower than 2024. Among them there were 23,152 DM and 4,503 HBP. These figures are automatically calculated by the database, which collects the records of the individual patient service use, but of course only if the data are entered into the database. We know that recording does not always happen so the figures of active patients can be an underestimate of actual number of active patients.

យើងអាចប៉ាន់ប្រមាណអត្រាស្លាប់ពី ២%ទៅ ៣%ក្នុងមួយឆ្នាំ។ ប៉ុន្តែភាគច្រើនករណីស្លាប់ មិនត្រូវបានរាយការណ៍ហើយកត់ត្រានៅក្នុងប្រព័ន្ធទិន្នន័យឡើយ។ ក្នុងតារាងខាងក្រោម (ផ្អែកលើមូលដ្ឋានទិន្នន័យ) មិនបានបង្ហាញពីភាពត្រឹមត្រូវនៃអត្រាស្លាប់ ក្នុងចំនោមសមាជិកដែលបានចុះឈ្មោះឡើយ ដោយសារតែមិនមានរបាយការណ៍ច្បាស់លាស់។ បើគិតសមាជិកភាពតាំងពីឆ្នាំ២០០៥មក វាបានបង្ហាញនូវអត្រាស្លាប់តិចជាង១% ចំនួនសមាជិកបោះបង់បានបន្តកើនឡើងលើសពី៦៥% ក្នុងឆ្នាំ២០២៥នេះ។

We estimate a mortality rate of 2 to 3% yearly, but most cases remain unreported. In table below (part of database) shows that mortality rate among registered members is lower than the reality because more death cases were not reported. The rate of deaths reported was less than 1%. This has to be addressed more effectively. The problem is higher than 65% losses of patients in 2025.

តារាងទី 4៖ ការបាត់បង់ និងមរណៈភាព Lost and deaths

Beneficiaries During 2024		***Since 2005***				
	Active 2024	**Died**	**Lost**	**Total registered**	**Recorded deaths among registered**	**Patient Lost among registered**
Diabetics	*24047*	*371*	*31961*	*56379*	*0.66%*	*57%*
High Blood Pressure	*4824*	*73*	*14449*	*19346*	*0.38%*	*75%*
Total	***28871***	***444***	***46410***	***75725***	***0.59%***	***61.29%***
Beneficiaries During 2025		***Since 2005***				
	Active 2025	**Died**	**Lost**	**Total registered**	**Recorded deaths among registered**	**Patient Lost among registered**
Diabetics	*23152*	*369*	*36792*	*60313*	*0.61%*	*61%*
High Blood Pressure	*4503*	*74*	*15641*	*20218*	*0.37%*	*77%*
Total	***27655***	***443***	***52433***	***80531***	***0.55%***	***65.11%***

សកម្មភាពមិត្តអប់រំមិត្តរបស់អង្គការ ម.ព.ជ. បានចាប់ផ្តើមក្នុងតំបន់ក្រីក្រមួយចំនួនក្នុងទីក្រុង នៅពាក់កណ្តាលឆ្នាំ ២០០៥។ សកម្មភាពដំបូងរួមមាន សកម្មភាពចែកតេស្តជាតិស្ករក្នុងទឹកនោម និងការថែទាំសម្រាប់អ្នកជំងឺលើសសម្ពាធឈាមដែរ។ នៅពាក់កណ្តាលឆ្នាំ២០០៧ កម្មវិធីនេះត្រូវបានអនុវត្តដល់តំបន់ជនបទ នៅពេលមិត្តអប់រំមិត្តចាប់ផ្តើមទទួលការបង្រៀននៅស្រុកប្រតិបត្តិអង្គរកា ខេត្តតាកែវ ជាមួយនឹងការឧបត្ថម្ភតិចតួចពីមូលនិធិទឹកនោមផ្អែមពិភពលោក កាកបាទក្រហមប្រទេសស្វីស MSF ប្រទេសបែលហ្សិក និងម្ចាស់ជំនួយដទៃទៀត ដើម្បីអនុវត្តកម្មវិធីទូទាំងស្រុកប្រតិបត្តិអង្គរកាទាំងមូល។ កម្មវិធីបានបណ្តុះបណ្តាលមិត្តអប់រំមិត្តម្នាក់សម្រាប់មណ្ឌលសុខភាពមួយ។ គម្រោងនេះ គឺត្រូវបានបង្កើតឡើងតាមផែនការគ្រប់ដណ្តប់សុខភាព ថ្នាក់ជាតិដែលចំនួនប្រជាជននៅតាមទីតាំង មិនមែនតាមផ្នែករដ្ឋបាលថ្នាក់ខេត្តទៅរដ្ឋបាលថ្នាក់ឃុំ និងស្រុកឡើយ។

MoPoTsyo Peer Educator Network began in urban slums in mid 2005 with awareness raising for patients with diabetes (DM), including also care for diabetes patients with High Blood Pressure. In mid 2007 this intervention was piloted in a rural area, when peer educators began to be trained in Ang Roka OD in Takeo province with small amounts of funding from the World Diabetes Foundation, Swiss Red Cross, MSF Belgium and others to cover one entire operational district, with one peer educator per health center coverage area. The design was created to follow Cambodia's National Health Coverage plan which is population based and which does not follow the country's administrative division into communes and administrative districts.

ក្នុងឆ្នាំ២០២៥ ការចែកតេស្តទឹកនោមគឺត្រូវបានធ្វើបង្គ្រប់តាមផែនការសេសសល់នៅឆ្នាំ២០២៤ប៉ុណ្ណោះ។ ការចែកតេស្តនិងចែកខិតបណ្ណអប់រំអំពីជំងឺមិនឆ្លងនេះ គឺបានធ្វើនៅក្នុងស្រុកប្រតិបត្តិព្រៃកប្បាស (២៥ភូមិ) និងបរិបូណ៌ (១៦ភូមិ)។

In 2025, Urine Glucose strips distribution and leaflets to raise the awareness of NCD was done to complete the 2024 plan in two ODs – Prey Kabas for 25 villages and Boribo for 16 villages.

កម្មវិធីក្រុមលើសសម្ពាធឈាមតាមភូមិ៖ ក្រុមតូចដំបូងមួយនៃសមាជិកលើសសម្ពាធឈាមគ្មានទឹកនោមផ្អែមត្រូវបានជ្រើសរើសចូលកម្មវិធីនៅឆ្នាំ២០០៧។ តំបន់ក្រីក្រទីក្រុង យើងបានបង្កើតក្រុមលើសសម្ពាធឈាម ចំនួន៤ភូមិ។ បន្ទាប់ពីការខិតខំប្រឹងប្រែង២ដង យើងនៅតែមិនអាចរកមេក្រុម ឬសមាជិកក្រុមបានឡើយ។ បន្ទាប់មកវាត្រូវបានសាកល្បងក្នុងជនបទមានចំនួន ៦៣៤ក្រុម វាក៏មិនសូវដំណើរការល្អដងដែរ។ សកម្មភាពនេះមិនត្រូវបានបន្តឡើយ។

High Blood Pressure: An initial small group of members with High Blood Pressure, without diabetes, were recruited to the program in 2007 in urban slums. We created a Village High Blood Pressure group in 4 villages. After 2 attempts it did not catch on with the VHBP Group Leader nor the patients. Then it was tried in rural area with 634 groups, which also did not work out well and discontinued.

ពួកយើងបានបន្ថែម យុទ្ធនាការបង្ការបឋមអំពីជំងឺពុំរ៉ៃសម្រាប់អាជ្ញាធរមូលដ្ឋាន និងសាលារៀនដល់គ្រូបង្រៀន។ យុទ្ធនាការនេះ បានធានានូវការគាំទ្របានយ៉ាងល្អសម្រាប់ការអន្តរាគមន៍ ប៉ុន្តែវាមិនអាចអនុវត្តបាននៅមជ្ឈដ្ឋានទីក្រុងដែលសំបូរដោយអ្នកចេះដឹង។ សម្រាប់ស្រុកប្រតិបត្តិថ្មីៗ យុទ្ធនាការបង្ការបឋមអំពីជំងឺពុំរ៉ៃសម្រាប់អាជ្ញាធរមូលដ្ឋានគឺមានលទ្ធផលប្រសើរជាង។ ក្នុងឆ្នាំ២០២៥ យុទ្ធនាការនេះ គឺមិនត្រូវបានធ្វើឡើយ។

There we added a primary prevention campaign for commune leaders and for school teachers. This campaign helped to ensure wider support for the intervention, but it couldnot be implemented in the high educated urban environment. In the new ODs, a primary prevetion for commune leaders showed better results. In 2025, the primary prevention on diabetes and hypertension among the local authorities was not done.

រូបភាពទី ៣៖ ចំនួនសមាជិកសកម្មប្រើប្រាស់សេវាប្រចាំឆ្នាំ Yearly Active membership



ចំនួនសមាជិកសកម្មដែលកំពុងប្រើប្រាស់សេវាប្រចាំឆ្នាំ បានបង្ហាញនូវសញ្ញាធ្លាក់ចុះតាំងពីឆ្នាំ២០២៤ និងបានបន្តធ្លាក់ចុះនៅឆ្នាំ២០២៥នេះ។ អង្គការ ម.ព.ជ. យល់ថា ការធ្លាក់ចុះនៃការប្រើប្រាស់សេវានេះ បណ្តាលមកពីមណ្ឌលសុខភាពមានឱសថ Amlodipine (ឱសថព្យាបាលបញ្ហាឡើងសម្ពាធឈាម) តាមរយៈកម្មវិធីជាតិគាំទ្រដោយការទទួលសេវាដោយឥតបង់ប្រាក់សម្រាប់អ្នកជំងឺដែលមានប័ណ្ណមូលនិធិគាំពារសង្គមដូចជា មូលនិធិសមធម៌និងរបបសន្តិសុខសង្គម។ យើងមិនមានហេតុផលផ្សេងឡើយ ដើម្បីពន្យល់ពីនិន្នាការធ្លាក់ចុះនេះ។

The numbers of active registered patients showed a decrease since 2024 until 2025. We speculate this is due to better availability of Amlodipine (anti-hypertensive medication) through the national program with free medication for patients with social security entitlements such as Health Equity Fund and National Social Security Fund, MoPoTsyo has no other reasons to show why the number of active patients decreased.

មិត្តអប់រំមិត្តជាធនធានសុខាភិបាល PEER EDUCATORS AS RESOURCES FOR HEALTH

តាំងពីឆ្នាំ២០០៥ អង្គការ ម.ព.ជ. បានបណ្តុះបណ្តាលមិត្តអប់រំមិត្តថ្មីៗ ដើម្បីបង្កើនកំលាំងការងារសុខាភិបាលនៅកម្ពុជា ជាកំលាំងពលកម្មបន្ថែមនិងបំពេញកន្លែងដែលបាត់បង់។ ការបង្រៀនពិសេសមួយ ជួយឱ្យពួកគេទទួលបានចំណេះដឹងនិងអនុវត្តបានជាក់ស្តែង។ នេះជាធនធានមានសមត្ថភាពខ្ពស់ និងចំណាយថវិកាតិច សម្រាប់កិច្ចការសុខភាពសាធារណៈ។ ប៉ុន្តែក្នុងឆ្នាំ២០២៥ អង្គការមិនបានបណ្តុះបណ្តាល មិត្តអប់រំមិត្តថ្មីបន្ថែមឡើយ ដោយសារភាពមិនច្បាស់លាស់របស់កម្មវិធីបណ្តាញមិត្តអប់រំមិត្ត និងការមិនពង្រីកបណ្តាញនៅកាន់ស្រុកប្រតិបត្តិថ្មី។ ចាប់ពីឆ្នាំ២០០៥ ដល់ឆ្នាំ២០២៥ អង្គការមានមិត្តអប់រំមិត្តសរុប ៣៤៨នាក់ ដែលបានបណ្តុះបណ្តាល។ ក្នុងចំនោមពួកគេទាំងអស់នេះ មាន១៩២នាក់ នៅតែបន្តធ្វើការជាមិត្តអប់រំមិត្ត នាដំណាច់ឆ្នាំ ២០២៥។

From 2005 onward MoPoTsyo has been training new Peer Educators (PEs) increasing Cambodia's health workforce with lay workers having received a special training in theory and in practice. This is a highly effective and low cost resource for public health duties. However, in 2025, training new PEs was not done due to uncertainty of program implementation affected by health policy changes. Since operations began, From 2005 to 2025 there were a total of 348 PEs trained by MoPoTsyo. Among them, there are 192 patients with diabetes still working as PEs at the end of 2025.

រូបភាពទី4៖ ចំនួនមិត្តអប់រំមិត្តបានបណ្តុះបណ្តាល និងមិត្តអប់រំមិត្តនៅធ្វើការ Total numbers of PEs trained and Active PEs



នៅចុងឆ្នាំ២០២៥ ភាគរយនៃមិត្តអប់រំមិត្តដែលនៅធ្វើការជាមួយអង្គការ ម.ព.ជ. នៅត្រឹម ៥៥% (១៩២នាក់នៃចំនួន ៣៤៨នាក់)។ សញ្ញានៃការធ្លាក់ចុះភាគរយរហូតមកដល់ពេលនេះ គឺស្របគ្នានឹងការមិនបណ្តុះបណ្តាលមិត្តអប់រំមិត្តថ្មីបន្ថែមក្នុងឆ្នាំនេះ រួមជាមួយនឹងមូលហេតុនៃការកើនឡើងនៃអាយុរបស់គេនេះ។ នេះជាការប្រឈមដ៏ធំ ជាពិសេសតំបន់នៅតាមជនបទដែលបានចាប់ផ្តើមបណ្តាញមិត្តអប់រំមិត្តដំបូងៗ គេ ជាពិសេសការបញ្ចប់កិច្ចសន្យាមិត្តអប់រំមិត្តចំនួន៤ស្រុក ប្រតិបត្តិនាដើមឆ្នាំ២០២៥នេះ។

At the end of 2025, the percentage of PEs still working with MoPoTsyo remains: 55% (192 out of 348). The rate of attrition until now follows along with climbing of their age. This is a big challenge for the program especially for the ODs where the PE network formed several years ago. Especially, peer network from 4 ODs (Bati, Kirivong, Kampong Tralach, and Chhlong) did not get new contract by the start of 2025.

រូបភាពទី5៖ ចំនួនមិត្តអប់រំមិត្តដែលបានបណ្តុះបណ្តាលប្រចាំឆ្នាំ ***Yearly number of PEs trained***



រូបភាពទី6៖ ភាគរយនៃមិត្តអប់រំមិត្តបន្តនៅជាមួយអង្គការ ម.ព.ជ. ***Percentage of PEs still with MoPoTsyo***



ក្នុងឆ្នាំ២០១៥ ពួកយើងបានធ្វើការបង្រៀនសារជាថ្មីឱ្យមិត្តអប់រំមិត្តនូវបញ្ហាដូចជា ជំងឺទឹកដក់បាតភ្នែក បញ្ហាសុខភាពប្រអប់ជើង បញ្ហាលើសសម្ពាធឈាម និងជំងឺដាច់សរសៃឈាមក្នុងខួរក្បាល ដោយសម្ភារសិក្សាមានលក្ខណៈពិសេសនៅក្នុងទម្រង់ជាវីដេអូគំនូរជីវចល។ ដូចគ្នាផងដែរ មិត្តអប់រំមិត្តបានទទួលការបង្រៀនពិសេស អំពីរបៀបពន្យល់ពីលទ្ធផលជីវគីមីសាស្ត្ររបស់គេស្តមន្ទីរពិសោធន៍ទៅអ្នកជំងឺ។

In 2015 we did refresher training of the peer educators in issues such as Diabetic Retinopathy foot-wound and High Blood Pressure and Stroke by special educational materials in the form of an animated video. Also the peer educators have received special training in how to explain the biochemistry laboratory results to the patients.

ឆ្នាំ២០២៤ អង្គការ ម.ព.ជ. បានរៀបចំសិក្ខាសាលាពង្រឹងសមត្ថភាពបណ្តាញមិត្តអប់រំមិត្តរយៈពេល២ថ្ងៃ រៀបចំនៅសណ្ឋាគារភ្នំពេញ រាជធានីភ្នំពេញ។ អ្នកគ្រប់គ្រងបណ្តាញមិត្តអប់រំមិត្ត និងមិត្តអប់រំមិត្តសរុបចំនួន ៧៣នាក់ បានចូលរួមវគ្គសិក្ខាសាលានេះ។ ដោយឡែកនៅក្នុងឆ្នាំ២០២៥ យើងមិនបានរៀបចំវគ្គសិក្ខាសាលាណាមួយ សម្រាប់ពង្រឹងសមត្ថភាពរបស់មិត្តអប់រំមិត្តឡើយ។

In 2024, a 2-day seminar was held in Phnom Penh hotel in Phnom Penh to strengthen the capacity of the peer educator networks. 73 peers including ODPMs attended the seminar. However, there was no such activity done in 2025.

ប្រសិនបើពួកយើងមើលលើហេតុផល ថាតើហេតុអ្វីពួកយើងបាត់បង់មិត្តអប់រំមិត្ត រូបភាពខាងក្រោមចាប់ផ្តើមលេចឡើង។ យើងឃើញថា មានមូលហេតុសំខាន់២ គឺ ការបោះបង់ និងស្លាប់។ ជាក់ស្តែងឆ្នាំ២០២៥ គឺជាឆ្នាំដែលយើងបានបាត់បង់មិត្តអប់រំមិត្តច្រើនបំផុតមិនធ្លាប់មាន ដោយសារអង្គការ ម.ព.ជ. បានសម្រេចចិត្តបញ្ចប់ការគាំទ្រទាំងអស់ដល់មិត្តអប់រំមិត្តនៅតាមតំបន់មួយចំនួនដូចជា កំពង់ត្រឡាច ឆ្លងបាទី គិរីវង់ និងកោះអណ្តែត (១នាក់) សរុបចំនួន២៦នាក់ និងមានមិត្តអប់រំមិត្តទទួលមរណភាពចំនួន៣នាក់ផ្សេងទៀត។

If we look at the reasons why we lose PEs, the following picture begins to emerge. We saw 2 main reasons: resignation and death. 2025 was the hardest year ever, we faced losing most peer educators because MoPoTsyo decided to stop the contract with 26 peers from Bati (8 peers), Kirivong (6 peers), and Koh Andaet (1 peer), Kampong Tralach (5 peers) and Chhlong (6 peers). Moreover, there were 3 peers who passed away.

រូបភាពទី7៖ ហេតុផលសម្រាប់ការបាត់បង់មិត្តអប់រំមិត្ត Reasons for losing PEs



ទន្ទឹមនឹងមានមិត្តអប់រំមិត្តភាគច្រើន ដែលបានទទួលការបណ្តុះបណ្តាល នៅបន្តធ្វើការជាមិត្តអប់រំមិត្តដដែល ក៏មានមិត្តអប់រំមិត្តមួយចំនួនតូច បានផ្លាស់ប្តូរមុខនាទីរបស់ពួកគេ ពីមិត្តអប់រំមិត្តស្ម័គ្រចិត្ត ទៅជាបុគ្គលិកទទួលប្រាក់ខែពីអង្គការ ម.ព.ជ.។ នៅពេលពួកគេក្លាយទៅបុគ្គលិកទទួលប្រាក់ខែ មិត្តអប់រំមិត្តថ្មីត្រូវបានបណ្តុះបណ្តាលបន្ថែម ដើម្បីជំនួសមិត្តអប់រំមិត្តចាស់ និងត្រូវបន្តជាអ្នកស្ម័គ្រចិត្តក្នុងសហគមន៍។

Many trained PEs remain in role as PE over time, some have changed their status from being a volunteer Peer Educator to salaried staff members. When they become salaried staff members, a new PE must be trained so he/she can replace the “ex”-PE who continues to live inside the community.

ការផ្លាស់ប្តូរនេះ បានកើតឡើងច្រើនដងមកហើយ ជាពិសេសនៅក្នុងតំបន់ក្រីក្រទីក្រុង កន្លែងដែលអ្នកជំងឺជាច្រើនផ្លាស់តួនាទីពួកគេ ទៅជាបុគ្គលិកទទួលប្រាក់ខែរបស់ ម.ព.ជ. ជំនួសដោយអ្នកជំងឺចាស់របស់ពួកគាត់។ រហូតមកដល់ចុងឆ្នាំ២០២៥ ការិយាល័យអង្គការ នៅសល់អតីតមិត្តអប់រំមិត្តចំនួន ២នាក់ ដែលបន្តធ្វើការជាបុគ្គលិកមានប្រាក់ខែ។

ពួកគាត់បានចូលរួមក្នុងការគ្រប់គ្រង ដំណើរការត្រួតពិនិត្យ និងចាត់ចែងកិច្ចការនៅក្នុងផ្នែកអនុវត្តកម្មវិធីគ្រប់គ្រងបណ្តាញមិត្តអប់រំមិត្តរបស់អង្គការ ម.ព.ជ.។ ពួកគេជួយពង្រឹងសមត្ថភាពរបស់បណ្តាញមិត្តអប់រំមិត្តនៅស្រុកប្រតិបត្តិ។ នៅក្នុងភូមិសាស្ត្រ គ្របដណ្តប់ដោយមណ្ឌលសុខភាពនីមួយៗ ដែលគ្របដណ្តប់ភូមិជាច្រើន និងមានចំនួនប្រជាជនរស់នៅចន្លោះពី៨០០០នាក់ ទៅចំនួន១៥០០០នាក់ គឺមានមិត្តអប់រំមិត្តម្នាក់។

This has happened several times, particularly in the urban slums, where several patients worked themselves into MoPoTsyo's salaried positions, being replaced by their former patients. Until the end of 2025 MoPoTsyo HQ has 2 former Peer Educators working as salaried staff.

They are involved in management, supervision and have organisational tasks in the Program Dpt of MoPoTsyo where the Peer Educator Networks are being managed. They help strengthen the capacity of the Peer Educator Network at the OD level. There is only one PE for all villages covered by each health center area with numbers of residents between 8,000 to 15,000 people.

តារាងទី ៥៖ មិត្តអប់រំមិត្ត និង អ្នកគ្រប់គ្រងមានប្រាក់ខែ PEs & salaried supervisors

នៅចុងឆ្នាំ២០២៥ At the end of the year 2025			
ខេត្ត/ក្រុង Provinces/Municipalities	មណ្ឌលសុខភាពមានមិត្តអប់រំមិត្ត HC areas with PEs	អ្នកគ្រប់គ្រងទទួលប្រាក់ខែ Salaried supervisors	សរុប Total
ភ្នំពេញ Phnom Penh	13	2	15
តាកែវ Takeo	27	0	27
បន្ទាយមានជ័យ Banteay Meanchey	7	0	7
កំពង់ស្ពឺ Kampong Speu	35	0	35
កំពង់ធំ Kampong Thom	26	0	26
កំពត Kampot	8	0	8
កំពង់ចាម Kampong Cham	28	0	28
ស្វាយរៀង Svay Rieng	27	0	27
កំពង់ឆ្នាំង Kampong Chhnang	7	0	7
កណ្តាល Kandal	8	0	8
ក្រចេះ Kratie	0	0	0
ត្បូងឃ្មុំ Tboung Khmum	6	0	6
សរុប Total	**192**	**2**	**194**

បុគ្គលិកទទួលបានប្រាក់ខែ ចំនួន៤០នាក់ បន្ថែមលើអ្នកបំពេញការងារស្ម័គ្រចិត្តតាមសហគមន៍ ជាមិត្តអប់រំមិត្តចំនួន១៩២នាក់។ កំលាំងការងារសរុបនៅសល់ត្រឹម ២៣២នាក់ នៅដំណាច់ឆ្នាំ២០២៥។ ចាប់តាំងពីឆ្នាំ២០១៧ ទំហំបុគ្គលិកធៀបនឹងទំហំការងារកាន់តែកើនឡើង ពីអ្នកជំងឺសកម្ម៩៩នាក់ក្នុងមិត្តអប់រំមិត្តម្នាក់ ទៅអ្នកជំងឺសកម្ម ១៤៤ នាក់ក្នុងមិត្តអប់រំមិត្តម្នាក់ក្នុងឆ្នាំ២០២៥ ដោយសារតែចំនួនមិត្តអប់រំមិត្តត្រូវបានកាត់បន្ថយយ៉ាងច្រើន។

With 40 salaried staff plus the 192 field workers working for MoPoTsyo the workforce is 232 persons in total in 2025. The workload per PE increased since 2017 from 99 active patients per PE to 144 active patients per PE during 2025.

តារាងទី ៦៖ ចំនួនមិត្តអប់រំមិត្តតាមខេត្តនីមួយៗ ***Numbers of PE by province***

ឆ្នាំ Year	តាកែវ Takeo	ភ្នំពេញ P.Penh	ប.មានជ័យ B.M.Chey	កំពង់ស្ពឺ K.Speu	កំពង់ធំ K.Thom	កំពត Kampot	កំពង់ចាម K.Cham	ស្វាយរៀង S.Rieng	កំពង់ឆ្នាំង K.Chhng	កណ្តាល Kandal	ក្រចេះ Kratie	ត្បូងឃ្មុំ Tb. Khmum	សរុប Total
2010	41	5	6	11									**63**
2011	46	5	7	16									**74**
2012	56	5	11	24	18								**114**
2013	57	6	11	40	27								**141**
2014	52	5	9	40	28	9	9						**152**
2015	52	5	9	40	29	9	11	5					**160**
2016	48	5	9	46	29	9	10	15					**171**
2017	47	5	9	44	27	9	10	20					**171**
2018	46	6	9	54	28	9	10	20					**182**
2019	44	12	9	57	27	9	10	19					**187**
2020	42	13	8	53	30	10	10	30					**196**
2021	41	13	8	47	28	9	10	27	6				**189**
2022	41	11	8	42	28	9	18	26	6	5	4		**198**
2023	39	13	8	42	28	9	25	29	6	6	7	5	**217**
2024	42	13	7	37	26	8	28	28	13	8	6	6	**222**
2025	27	13	7	35	26	8	28	27	7	8	0	6	**192**

ឧបសគ្គនៃតុល្យភាពភេទ CHALLENGES TO GENDER BALANCE

យើងបាននឹងកំពុងជួបការលំបាក ដើម្បីធ្វើឱ្យមានតុល្យភាពយែនឌ័រដ៏សមរម្យមួយ សម្រាប់ការជ្រើសរើសមិត្តអប់រំមិត្ត។ ស្វាមីជាច្រើនមិនចង់ឱ្យភរិយារបស់ពួកគេស្ម័គ្រចិត្ត ជាមិត្តអប់រំមិត្ត ហើយការស្វែងរកស្ត្រីមានសមត្ថភាពគ្រប់គ្រាន់ដែលមានបំណងធ្វើការជាមិត្តអប់រំមិត្ត ក៏ជាការលំបាកផងដែរ។ ផលប្រយោជន៍ទទួលបានពីការងារស្ម័គ្រចិត្តគឺ តិចតួច ធ្វើឱ្យការងារមិត្តអប់រំមិត្តគឺ ភាគច្រើនធ្វើដើម្បីតែកិត្តិយស។ រង្វាន់អរូបី មានតម្លៃច្រើនជាងរង្វាន់ជារូបី។ សមាជិកគ្រួសារ អាចនឹងមិនសប្បាយចិត្ត នៅពេលម្តាយមិនសូវយកចិត្តទុក ដាក់ទៅលើពួកគេ ហើយរវល់ដើរគ្រប់ទីកន្លែង ដើម្បីធ្វើការថែទាំសម្រាប់អ្នកដទៃ។ សម្ពាធបែបនេះ អាចមកពីកូនៗរបស់ពួកគាត់ ឬស្វាមីរបស់ពួកគាត់។ នៅឆ្នាំ២០២៥ ភាគរយមិត្តអប់រំមិត្តជាស្ត្រីមានត្រឹម ៣៩% ចំណែកបុរសមានចំនួន ៦១%។ វាក៏បានបង្ហាញនូវអតុល្យភាពភេទនៃអ្នកជំងឺ។ ប៉ុន្តែវាគឺ មានការផ្ទុយគ្នា សមាមាត្រ១/៣ជាបុរស ធៀបនឹង២/៣នៃស្ត្រី វាមិនបានប្រែប្រួលតាំងពីឆ្នាំ២០០៥។ ក្នុងឆ្នាំ២០២៥ ពួកយើងរកឃើញភាពមិនស៊ីគ្នាដូចខាងក្រោម មាន៣៧%នៃអ្នកជំងឺដែលកំពុងប្រើសេវាគឺជាបុរស ខណៈ៦៣%ផ្សេងទៀតគឺជាស្ត្រី។

It is difficult to reach an appropriate gender balance in both PEs and patients. Many husbands do not want their spouse to become a PE. It is also difficult to find women with sufficient capacity who are willing to work as PEs. The indemnity is minimal, making the job of PEs something that you do mostly for honor. The immaterial rewards weigh probably more than the material rewards. Members in the household can be unhappy when the mother is not paying as much attention to them, and is busy going around the area in order to care for other people. This type of pressure can come from their children and from their husbands. They demand her to be available all the time for them. Comparing to 2024, the proportion of female PEs in 2025 has changed from 38% to 39%. There is also an imbalance in the gender of patients, but this is the opposite! The proportion of 1/3 male versus 2/3 female in patients has not changed since 2005. In 2025, we find the following mismatch: only 37% of the active registered patients are male while 63% are female.

រូបភាពទី៖ មិត្តអប់រំមិត្តតាមភេទក្នុងឆ្នាំ២០២៤និង២០២៥ *PEs by sex in 2024 and 2025*



ប្រព័ន្ធថែទាំជំងឺមិនឆ្លង CHRONIC CARE SYSTEM

ភាពចន្លោះប្រហោងព័ត៌មាន រវាងគ្រូពេទ្យផ្តល់សេវា និងអ្នកជំងឺ គឺត្រូវបានចងក្រងក្នុងឯកសារស្រាវជ្រាវអន្តរជាតិ ជាច្រើនទសវត្សមកហើយ។ នៅក្នុងបរិបទនៃប្រទេសកម្ពុជា បណ្តាញមិត្តអប់រំមិត្តសម្រាប់អ្នកជំងឺទឹកនោមផ្អែម និងអ្នកជំងឺលើសសម្ពាធឈាមត្រូវបានបង្កើតឡើង ដើម្បីជួយបង្កើតដំណោះស្រាយជាក់ស្តែង និងបន្តយន្តការនៃការថែទាំប្រកបដោយប្រសិទ្ធភាព។ មិត្តអប់រំមិត្តមានតួនាទីជាអ្នកកណ្តាលរវាងអ្នកជំងឺ និងប្រព័ន្ធថែទាំសុខភាពសាធារណៈ។ ពួកគេបានយល់ពីភាគីទាំងពីរ និងជួយជាស្ពាននៃទំនាក់ទំនងរវាងភាគីទាំងពីរ ដើម្បីឱ្យមានភាពប្រសើរឡើង។

The information gap between health care providers and patients is well documented in international literature since many decades. In the Cambodian context, so called peer educator networks for diabetes and hypertension are the innovation that helps to create this reality and maintain it. Peer Educators stand as intermediaries between the population and the health care system. They understand both sides and help bridge the poor communication between the two sides.

រូបភាពទី១៖ ប្រព័ន្ធគាំទ្រថែទាំជំងឺរ៉ាំរ៉ៃ របស់បណ្តាញមិត្តអប់រំមិត្ត Supporting Chronic Care system of PE Network



ដោយសារមើលឃើញ ពីភាពចាំបាច់នៃបណ្តាញមិត្តអប់រំមិត្ត ក្រសួងសុខាភិបាល នៅតែរក្សាទុក មិត្តអប់រំមិត្ត និងបណ្តាញមិត្តអប់រំមិត្តនេះ នៅក្នុងផែនការយុទ្ធសាស្ត្រជាតិប្រយុទ្ធ និងការពារជំងឺមិនឆ្លងឆ្នាំ២០២២-២០៣០។ ឯកសារគោលនយោបាយនេះ គឺជាដំណាក់កាលថ្មីបន្តពីផែនការយុទ្ធសាស្ត្រជាតិប្រយុទ្ធ និងការពារជំងឺមិនឆ្លងឆ្នាំ២០១៣-២០២០ ដែលបានចេញផ្សាយជាសាធារណៈ នាខែមេសា ឆ្នាំ២០១៤ មកម្លេះ។ ឯកសារទាំងនេះ បានផ្តល់នូវគ្រោងផែនការដ៏សំខាន់សម្រាប់ការអនុវត្តសកម្មភាពទាក់ទងនឹងជំងឺមិនឆ្លង។

បន្ថែមលើនេះ ឯកសារផែនទីបង្ហាញផ្លូវឆ្ពោះទៅការគ្របដណ្តប់សុខភាពជាសកលនៅកម្ពុជា ឆ្នាំ២០២៤-២០៣៥ រៀបចំដោយក្រុមប្រឹក្សាជាតិគាំពារសង្គមនៅឆ្នាំ២០២៤ បានពន្លឿនទូវយុទ្ធសាស្ត្រមូលនិធិឱសថបង្វិលទុន (ចំណុច ២.១០.៥) ជាការគាំទ្របន្ថែមដល់ឃ្លាំងឱសថកណ្តាលក្នុងករណីចាំបាច់ណាមួយ ដើម្បីពង្រឹងយន្តការគ្រប់គ្រងនិងបែងចែកឱសថ។

For this reason, the Ministry of Health adopted PE Networks as part of its National Strategic Plan for Prevention and Control of Noncommunicable Diseases 2022-2030. It was a new updated phase of former National Strategic Plan from 2013 to 2020 which was officially disseminated in early April 2014. It provides an important framework for implementation of activities related to Chronic Noncommunicable Diseases.

Moreover, the document of road map towards Universal Health Coverage in Cambodia from 2024-2035 prepared by the National Social Protection Council released in 2024 has stated the Revolving Drug Fund as a stategy to support Central Medicine Stock (CMS) in case of need in order to strenghen the managment and distibution of medicines.

រូបភាពទី10៖ តួនាទី និងការទទួលខុសត្រូវរបស់បណ្តាញមិត្តអប់រំមិត្ត ***Roles and Responsibilities of PE Network***



សេវាសុខភាព សម្រួលដោយមិត្តអប់រំមិត្ត HEALTH SERVICES FACILITATED BY PEs

សកម្មភាពចែកតេស្តទឹកនោម DISTRIBUTING URINE GLUCOSE STRIPS

ការចែកតេស្តទឹកនោមឥតគិតថ្លៃ ទៅមនុស្សពេញវ័យចាប់ពីអាយុ ១៨ឆ្នាំឡើងទៅ គឺជាទូទៅត្រូវបានធ្វើឡើងនៅតំបន់ស្រុកប្រតិបត្តិ នៅពេលអង្គការ ម.ព.ជ. បង្កើតបណ្តាញមិត្តអប់រំមិត្ត។ ការស្រាវជ្រាវនេះធ្វើឡើងជាពីរដំណាក់កាល៖ ទី១ មិត្តអប់រំមិត្ត ផ្តល់មនុស្សម្នាក់ៗនូវស្ទ្រីបទឹកនោមមួយដើម និងក្រដាសចង្អុលពណ៌ ដោយមានពន្យល់ជាភាសាខ្មែរអំពីរបៀបប្រើ ២ ទៅ៣ ម៉ោងក្រោយហូបអាហារ។ ទី២ ប្រសិនបើអ្នកឃើញថា ពណ៌ស្ទ្រីបប្រែប្រួល ឬមានចំងល់អំពីតេស្ត អាចស្នើសុំមិត្តអប់រំមិត្តធ្វើតេស្តជាតិស្ករចុងដៃដោយម៉ាស៊ីនស្វ័យប្រវត្តិ ដើម្បីផ្ទៀងផ្ទាត់លទ្ធផលជាតិស្ករ អំពីវត្តមាននៃជំងឺទឹកនោមផ្អែម។ នៅក្នុងកិច្ចព្រមព្រៀងថ្មី ការចែកតេស្តធ្វើឡើងនៅតាមភូមិ ដោយមានតំណាងគ្រួសារ មកទទួលយកស្ទ្រីបតេស្តទឹកនោម ទៅតាមចំនួនសមាជិកពេញ វ័យរបស់គ្រួសារនីមួយៗ។ នៅក្នុងឆ្នាំ២០២៥ យើងបានបន្ថែមការចែកតេស្តទឹកនោមបង្គ្រប់ចំនួន ២៦៦៣៣តេស្ត នៅតាមភូមិចំនួន ៤១ ក្នុងស្រុកប្រតិបត្តិចំនួន២ រួមមាន៖ ស្រុកប្រតិបត្តិបរិបូណ៌ ១៦ភូមិ និងស្រុកប្រតិបត្តិព្រៃកប្បាសចំនួន ២៥ភូមិ។ យើងបានរៀបចំនូវខិត្តប័ណ្ណអប់រំអំពីជំងឺទឹកនោមផ្អែម និងអំពីជំងឺលើសសម្ពាធឈាម បន្ថែមលើការចែកតេស្តទឹកនោម ពិនិត្យរកវត្តមានជាតិស្ករដោយខ្លួនឯង នៅពេលចុះចែកតេស្តនៅតាមភូមិផងដែរ។

A free distribution of urine glucose strips among adults from 18 years old normally is done in every new OD when MoPoTsyo sets up the peer educator network. It is done in two stages. First, PE distribute one urine glucose strip per adult with color chart and explanation in khmer on how to use it 2 to 3 hours after lunch. Secondly, anyone who observes a change in color of urine test strip or wonders if they are diabetic can contact or ask the PE for letting him do a blood glucose test to find out or confirm whether they really are diabetic or not. In the new MoU, the urine strip distributed to a representative of each household by village. In 2025, there were 26,633 urine glucose strips were distributed in the 41 villages covered by 2 different Operational Districts namely Prey Kabas 25 villages and Boribo 16 villages. To raise awareness of diabetes, hypertension, special leaflets distributed along with the urine glucose strip.

រូបភាពទី11៖ ការធ្វើតេស្តជាតិស្ករក្នុងទឹកនោមដោយខ្លួនឯង Yearly self-urine glucose testing



មិត្តអប់រំមិត្តតាមមូលដ្ឋាន បានចែកស្ទ្រីបទឹកនោមទៅឱ្យមនុស្សពេញវ័យដើម្បីធ្វើតេស្តខ្លួនឯង។ រូបភាពខាងលើនិងខាងក្រោមមានទំនាក់ទំនងជាមួយ ចំនួនមនុស្សពេញវ័យថ្មីដែលបានធ្វើតេស្តស្ករក្នុងទឹកនោម ដោយខ្លួនពួកគេ។ ពួកគេ ត្រូវបានណែនាំឱ្យធ្វើតេស្តនៅពេលប្រមាណ ២ម៉ោងក្រោយហូបអាហារ។

The community-based PE distributes urine glucose strips to adults for self-testing. The figures above and below relate to number of adults who learn how to use the strip to test themselves. They were advised to do the urine glucose test about 2 hours after meal.

វាបានបង្ហាញនូវតួរលេខរួមបញ្ចូល នៃមនុស្សពេញវ័យដែលបានធ្វើតេស្តទឹកនោម ជាមួយបណ្តាញមិត្តអប់រំមិត្ត តាមរយៈការប្រើស្ទ្រីបទឹកនោមនាឆ្នាំកន្លងមក។ មនុស្សពេញវ័យប្រមាណ ១.៣៤៥.៤២៩នាក់ ក្នុងប្រទេសកម្ពុជា ឥឡូវកំពុងរស់នៅក្នុងតំបន់មានមិត្តអប់រំមិត្ត។ ជាក់ស្តែង ទោះបីជាលទ្ធផលតេស្តជាតិស្ករតាមរយៈស្ទ្រីបទឹកនោម អាចទទួលយកបាន ប៉ុន្តែមានភាពសុក្រិតទាបជាង ធៀបនឹងតេស្តជាតិស្ករចុងម្រាមដៃដោយសារថា ស្ទ្រីបទឹកនោមមិនប្រែពណ៌ ទោះករណីខ្លះលើសជាតិស្ករក៏ដោយ (false negative) ខណៈតម្លៃស្ទ្រីបទឹកនោម គឺថោកជាងប្រហែល១០ ទៅ ១៥ដង។ យើងមិនមានលទ្ធភាពក្នុងការផ្តល់តេស្តជាតិស្ករចុងម្រាមដៃ ដើម្បីស្រាវជ្រាវរកករណីជំងឺទឹកនោមផ្អែម ចំណោមមនុស្សពេញវ័យទូទៅឡើយ ដោយសារវាត្រូវចំណាយខ្ពស់។ ហេតុនេះយើងនៅបន្តប្រើស្ទ្រីបទឹកនោម ក្នុងការស្រាវជ្រាវនេះ ក្នុងការលើកទឹកចិត្តឱ្យប្រជាពលរដ្ឋធ្វើតេស្តដោយខ្លួនឯង និងលើកកម្ពស់ការយល់ដឹង របស់ពួកគេអំពីបញ្ហាជំងឺ។ ទោះបែបនេះក្តី ការធ្វើរោគវិនិច្ឆ័យ គឺផ្អែកលើតេស្តជាតិស្ករចុងម្រាមដៃដោយម៉ាស៊ីនស្ងួយប្រវត្តិ មិនមែនស្ទ្រីបទឹកនោមឡើយ។

The Figure below indicates the accumulated number of adults who have been made familiar with the Peer Educator Network, through use of urine glucose strips over the years. More than 1,345,429 Cambodian adults are now living in an area with peer educator networks. In fact the urine glucose strip is not sensitive giving false negative results but it is 10 to 15 times cheaper than the blood glucose test. We can not afford to distribute free blood glucose test to the whole population because it is too expensive. That is why we continue to distribute free urine glucose test strips to encourage population to self-test and raise their awareness. The diagnosis of diabetes is only made on the basis of blood glucose and never on the basis of urine glucose.

រូបភាពទី12៖ កំណើននៃការគ្រប់ដណ្តប់លើមនុស្សពេញវ័យ Adult population covered by PE networks



សេវាសុខាភិបាល MEDICAL SERVICES

ជាដំបូង យើងនឹងពិនិត្យមើលទៅលើសេវាតេស្តមន្ទីរពិសោធន៍វេជ្ជសាស្ត្រ ការប្រើប្រាស់និងថ្លៃចំណាយលើសេវា។ បន្ទាប់មកមើលទៅលើការពិគ្រោះជំងឺ ការប្រើប្រាស់សេវា (ដូចជាការទទួលបាននូវវេជ្ជបញ្ជាពីព្រោះរាល់ការពិគ្រោះជំងឺ គ្រូពេទ្យបានចេញវេជ្ជបញ្ជា ដែលអាចប្រើប្រាស់បានម្តងហើយម្តងទៀត ដើម្បីចំណាយលើថ្នាំនៅឱសថស្ថាន) ហើយបន្ទាប់មកទៀត យើងមើលអំពីការចំណាយសម្រាប់អ្នកជំងឺ លើការអនុវត្តការព្យាបាល និងការអនុវត្តតាមវេជ្ជបញ្ជា។ យើងក៏ធ្វើការពិនិត្យមើលដែរ ទៅលើការគ្រប់គ្រងមូលនិធិឱសថបង្វិលទុន ដែលមានកិច្ចសន្យាជាមួយទាំងឱសថស្ថានរដ្ឋ និងឯកជនក្នុងការចែកចាយឱសថដល់សមាជិករបស់អង្គការ ដោយប្រើប្រាស់បង្កាន់ដៃបោះពុម្ព នៅពេលដែលសមាជិកមកទទួលសេវាថ្នាំ។ អង្គការ ម.ព.ជ. បានចាប់ផ្តើមរៀបចំសេវាតេស្តមន្ទីរពិសោធន៍ វេជ្ជសាស្ត្រនៅឆ្នាំ២០០៩។

We review first the laboratory service, their utilization and cost, then the Medical Consultations, their utilization (discussed as access to prescription because every medical consultation results in a prescription that can be used repeatedly to spend for prescribed medicines at the pharmacy), and then the cost to the patient of adhering to the treatment and adherence. This is followed by a review of the Revolving Drug Fund that is managed through contracted some private and mostly public pharmacies that dispense the medicines using preprinted receipts, paid for by our members. MoPoTsyo began to organise laboratory service in 2009.

សេវាមន្ទីរពិសោធន៍វេជ្ជសាស្ត្រ LABORATORY SERVICE

សេវាមន្ទីរពិសោធន៍មានគុណប្រយោជន៍សំខាន់៣៖ Laboratory service is useful for 3 main reasons:

1) ផ្តល់ព័ត៌មាន និងជំរុញទឹកចិត្តអ្នកជំងឺដើម្បីស្វែងរកការថែទាំជំងឺ និងទទួលបានអត្ថប្រយោជន៍ពីការប្រើប្រាស់សេវាពិគ្រោះជំងឺ និងការអនុវត្តតាមវេជ្ជបញ្ជាលើឱសថដែលគ្រូពេទ្យផ្តល់ឱ្យ។ បើគ្មានលទ្ធផលមន្ទីរពិសោធន៍នោះទេ អ្នកជំងឺផ្អែកលើអារម្មណ៍ផ្ទាល់ខ្លួនរបស់គាត់ ដើម្បីដឹងពីសុខភាពតែប៉ុណ្ណោះ។ បញ្ហានេះអាចបង្កគ្រោះថ្នាក់ដល់អ្នកជំងឺ ដោយហេតុថាជំងឺមួយចំនួនគឺមានលក្ខណៈស្ងៀមស្ងាត់ និងមិនបង្ហាញរោគសញ្ញា។

1) It helps to inform and motivate patients to seek medical care and make use of the medical consultation service and adhere to their medication. Without a laboratory result, patients rely on their own feeling of their well-being. This can be treacherous as many conditions are “silent” and a-symptomatic.

2) វេជ្ជបណ្ឌិត ត្រូវការមើលលទ្ធផលតេស្តមន្ទីរពិសោធន៍ដែលមានបង្ហាញពីនិន្នាការលទ្ធផលច្រើនដង ដើម្បីផ្តល់នូវវេជ្ជបញ្ជាដែលសមស្របសម្រាប់អ្នកជំងឺ និងដើម្បីកែតម្រូវវេជ្ជបញ្ជា ឬធ្វើការបញ្ជូនអ្នកជំងឺបន្ត។

2) The Doctor needs the trends over time in laboratory the results for prescribing an appropriate medication for the patient and for adaptation of the prescription or referral.

3) មន្ត្រីសុខភាពសាធារណៈត្រូវការមើលទៅលើលទ្ធផលទាំងនេះដើម្បីអាចធ្វើការវិភាគ ថាតម្រូវការក្នុងការព្យាបាលកំពុងត្រូវបានបំពេញតាមយ៉ាងសមស្របឬទេ តាមរយៈគ្រូពេទ្យចេញវេជ្ជបញ្ជា និងត្រួតពិនិត្យអំពីប្រសិទ្ធភាពនៃការព្យាបាលនៃវេជ្ជបញ្ជា។

3) Public Health authorities need access to these results to be able to analyse whether people’s therapeutic needs are being adequately met by prescribing physicians and monitor the effectiveness of prescription therapy.

មានអ្នកជំងឺចំនួន ១១.៩៧១នាក់ ដែលបានប្រើសេវាមន្ទីរពិសោធន៍យ៉ាងតិចម្តងក្នុងឆ្នាំ២០២៥ ខណៈដែលក្នុងឆ្នាំ ២០២៤ មានចំនួន ១២.០១៩នាក់។ យើងបានរក្សាចំនួនអ្នកបច្ចេកទេសមន្ទីរពិសោធន៍ ដោយមានអ្នកធ្វើការពេញពេលចំនួន ៩នាក់។ សមាមាត្រនៃមនុស្សវ័យចំណាស់ (អាយុ៦៥ឆ្នាំឬចាស់ជាង) ប្រើប្រាស់សេវាមន្ទីរពិសោធន៍មានការកើនឡើងបន្តិចពី ២៧% ក្នុងចំណោមអ្នកប្រើប្រាស់ចំនួន ១២.០១៩នាក់ ក្នុងឆ្នាំ២០២៤ ទៅ ២៨% ក្នុងចំណោមអ្នកប្រើប្រាស់ចំនួន ១១.៩៧១នាក់ ក្នុងឆ្នាំ២០២៥។ មានអ្នកជំងឺចំនួន ៥២% ដែលបានប្រើប្រាស់សេវាមន្ទីរពិសោធន៍ច្រើនជាងមួយដងក្នុងមួយឆ្នាំ។ រូបភាពខាងក្រោម ពិតជាមានសារៈសំខាន់ដែលអាចឱ្យយើងដឹង ពីអ្នកដែលបានប្រើប្រាស់សេវាមន្ទីរពិសោធន៍ ធៀបទៅអ្នកក្នុងក្រុមអាយុពួកគេ ដែលបានចុះឈ្មោះក្នុងប្រព័ន្ធទិន្នន័យ។ វិធីនេះអាចឱ្យយើងឃើញថា តើក្រុមអាយុមួយណា មានចំនួនអ្នកដែលប្រើប្រាស់សេវាច្រើនជាងក្រុមផ្សេងៗទៀត។ យើងឃើញថា ការប្រើប្រាស់សេវាសម្រាប់មនុស្សអាយុច្រើនជាង ៦៥ឆ្នាំមានចំនួនតិចតួច។

There were 11,971 patients who used the laboratory service at least once during 2025, compared to 12,019 in 2024. We keep the number of laboratory technicians to 9 Full Timers. The proportion of elderly people (65 years old or older) using the laboratory slightly increased from 27% among 12,019 users in 2024 to 28% among 11,971 users in 2025. 52% of the members used the lab service more than once a year. The figure below is now more meaningful as it indicates those who have access compared to how many patients there are in their own age groups in the assessment data. This way we can keep an eye on which age group is more crowding out than others. We can see that access for the elderly is an issue among those who are over 65 years of age, unsurprisingly.

រូបភាពទី13៖ ឱកាសប្រើប្រាស់សេវាមន្ទីរពិសោធន៍តាមឆ្នាំនីមួយៗ ***Access to lab-service by year***



រូបភាពទី14៖ ឱកាសប្រើប្រាស់សេវាមន្ទីរពិសោធន៍តាមក្រុមអាយុ ***Access to lab-service by different age groups***



រូបភាពទី15៖ ឱកាសប្រើប្រាស់សេវាមន្ទីរពិសោធន៍សម្រាប់មនុស្សចាស់ Access to the lab-services for elderly



មួយវិញទៀត បើយោងទៅតាមសមាមាត្រ សមាជិកជាស្ត្រីភាគច្រើនបានប្រើសេវាផ្សេងៗ របស់អង្គការ ម.ព.ជ. ហើយ ចំនួនស្ត្រីក៏បានធ្វើការប្រើប្រាស់សេវាមន្ទីរពិសោធន៍ច្រើនជាងបុរសដែរ។ ក្នុងន័យនេះ ឱកាសប្រើសេវាមន្ទីរពិសោធន៍សម្រាប់ស្ត្រី និងបុរសគឺមិនស្មើគ្នានោះទេ។ ប្រព័ន្ធទិន្នន័យ បានបង្ហាញឱ្យឃើញថា សមាជិកដែលបានចុះឈ្មោះជាមួយអង្គការ ម.ព.ជ. មានស្ត្រី ២/៣ និងបុរស ១/៣ នៃចំនួនសមាជិកសរុបក្នុងឆ្នាំ២០២៤ ហើយវាមិនមានការប្រែប្រួលឡើយក្នុងឆ្នាំ២០២៥។

Moreover, as proportionally more women use different services of MoPoTsyo, they also make more use of the lab service. In that sense, the access for women and men to the laboratory service is not equal. Data system showed that members registered in MoPoTsyo with women 2/3 and men 1/3 of the total in 2024. This figure still remains mostly unchanged in 2025.

តារាងទី 7៖ សមភាពតាមយេនឌ័រក្នុងការទទួលសេវាមន្ទីរពិសោធន៍ Equal access to the lab-services by gender

ភេទ	ចំនួន	ភាគរយ
ស្ត្រី	7,414	62%
បុរស	4,557	38%
សរុប (ឆ្នាំ2025)	***11,971***	***100%***

យើងព្យាយាម បង្កើនសមាមាត្រអ្នកប្រើសេវាមន្ទីរពិសោធន៍ យ៉ាងហោចណាស់ឱ្យបានម្តងក្នុងមួយឆ្នាំ ក្នុងចំណោមសមាជិកសកម្ម។ នៅក្នុងកិច្ចប្រជុំប្រចាំឆ្នាំ២០១៩ អង្គការ ម.ព.ជ. បានសម្រេចអនុវត្តឱ្យមានការបញ្ចុះភាគទានតេស្ត HbA1c ពី២០០០០រៀល មកត្រឹម១៥០០០រៀល ក្នុងមួយតេស្តចាប់ពីឆ្នាំ២០២០ និងរក្សាតម្លៃនេះ រហូតមកដល់បច្ចុប្បន្ននេះ។

We are succeeding in increasing the proportion of patients using lab service at least one time per year among the active members. At the end of 2019, we decided to lower the price of HbA1c from 2020 onwards from USD5.00 to USD3.75 per test. That price has remained unchanged so far.

សេវាមន្ទីរពិសោធន៍វេជ្ជសាស្ត្ររបស់យើង មានប្រព័ន្ធត្រួតពិនិត្យគុណភាពខាងក្នុង (IQC) ជាប្រចាំ និងទទួលបានការត្រួតពិនិត្យគុណភាពខាងក្រៅ តាមរយៈការចូលរួមជាសមាជិក ONE WORLD ACCURACY ដែលជាក្រុមហ៊ុនជំនាញត្រួតពិនិត្យគុណភាពនៃប្រទេសកាណាដា (EQAS)។ មានមន្ទីរពិសោធន៍វេជ្ជសាស្ត្រមួយចំនួន នៅកម្ពុជាដែលបានចូលរួមក្នុងកម្មវិធីនេះ ដោយមានការសម្របសម្រួលដោយមន្ទីរពិសោធន៍ជាតិនៃវិទ្យាស្ថានសុខភាពសាធារណៈ។ EQAS បានបង្ហាញថា គុណភាពនៃលទ្ធផលតេស្តរបស់យើងស្ថិតក្នុងចន្លោះប្រក្រតីដែលជាលទ្ធផលទទួលយកបាន។

យើងពិតជាសប្បាយចិត្តដែលឃើញថា សមាជិកដែលបានចុះឈ្មោះជាមួយមិត្តអប់រំមិត្ត ប្រើសេវាមន្ទីរពិសោធន៍ មានការកើនឡើងស្ទើរគ្រាល់ឆ្នាំ។ ប៉ុន្តែជាក់ស្តែងចំនួនអ្នកប្រើប្រាស់សេវាមន្ទីរពិសោធន៍ក្នុងឆ្នាំ២០២៥ មានការធ្លាក់ចុះបន្តិចបន្តួច។ ទោះបីការពិតនោះថា សេវានេះត្រូវបានផ្តល់ស្ទើរតែនៅថ្លៃដើមក៏ដោយ វាពិតជាមានប្រយោជន៍សម្រាប់អ្នកជំងឺក្រីក្រ ក្នុងការទទួលបានបដិភាគ សម្រាប់ថ្លៃសេវាមន្ទីរពិសោធន៍ ដើម្បីពួកគាត់មានឱកាសប្រើប្រាស់សេវានេះផងដែរ។

We have, of course, the daily Internal Quality Control system, but also the quality of our lab is being externally monitored through our membership in One World Accuracy, a Canadian professional External Quality Assurance System (EQAS) that we pay for, jointly with other laboratories in Cambodia, and in cooperation with the National Institute of Public Health (NIPH) in Phnom Penh. EQAS shows that our lab tests are within the normal ranges. So, our lab test results are reliable.

The number of patients who use the laboratory service remained stable the last 3 years. In fact, in 2025 the number of lab users slightly decreased. Despite the fact that this service is provided almost at the cost price, it seems worthwhile to subsidize the service for the poorest patients, so they can access the service as well.

រូបភាពទី16៖ ការប្រើប្រាស់សេវាមន្ទីរពិសោធន៍ និងថ្លៃចំណាយ Lab-service usage and cost



តារាងទី ៩៖ ថ្លៃចំណាយលើបរិក្ខារមន្ទីរពិសោធន៍រយៈពេល៥ឆ្នាំ Laboratory costs based on 5-year life time of machines

Fixed Cost and Depreciation of Laboratory Machines		Year				
Machines	**Purchase Price**	**2021**	**2022**	**2023**	**2024**	**2025**
CombiLyzer	$1,500	$0	$0	$0	$0	$0
HumaScope	$950	$0	$0	$0	$0	$0
HumaLyte Plus3	$4,200	$0	$0	$0	$0	$0
HumaStar 200 (A)	$23,600	$4,720	$0	$0	$0	$0
Audicom AC6601	$4,950	$990	$990	$0	$0	$0
Yumizen H500	$11,000	$2,200	$2,200	$2,200	$2,200	$0
Respons 920	$19,000	$3,800	$3,800	$3,800	$3,800	$3,800
HumaStar 200 (B)	$19,900	$0	$3,980	$3,980	$3,980	$3,980
Total Fixed Cost depreciated by year		**$11,710**	**$10,970**	**$9,980**	**$9,980**	**$7,780**

Expenditure of Laboratory Activity	Year				
	2021	**2022**	**2023**	**2024**	**2025**
Total Expenditure on Fixed Cost	$11,710	$10,970	$9,980	$9,980	$7,780
Total Expenditure on Variable Cost	$110,394	$127,016	$178,595	$173,687	$244,738
Grand Total	$122,104	$137,986	$188,575	$183,667	$252,518
Number of Laboratory Profiles	10982	8921	14654	18275	18157
Cost Per Profile	$11.12	$15.47	$12.87	$10.05	$13.91
AVG. Cost Per Profile Paid by Member	$8.52	$10.42	$10.93	$10.85	$12.39

ឈ្មោះតេស្តនីមួយៗ ត្រូវបានសរសេរទាំងជាភាសាខ្មែរ និងភាសាអង់គ្លេស។ ការបង្ហាញលទ្ធផលមន្ទីរពិសោធន៍មានគោលបំណងជួយអ្នកជំងឺ អោយបានយល់អំពីលទ្ធផលតាមរយៈមិត្តអប់រំមិត្ត។ មូលដ្ឋានទិន្នន័យបច្ចុប្បន្ន អាចឱ្យយើងបោះពុម្ព (Print) លទ្ធផល ៣ដងចុងក្រោយរបស់អ្នកជំងឺលើក្រដាសតែមួយ។ ដូច្នេះគ្រប់គ្នាអាចមើលឃើញភ្លាម និងអាចប្រៀបធៀបពីនិន្នាការនៃលទ្ធផលដែលធ្លាប់មានកន្លងមក។ ទំរង់លទ្ធផលបែបនេះ អាចជួយសន្សំពេលវេលាដល់វេជ្ជបណ្ឌិតពេលពិគ្រោះជំងឺ។ ខាងក្រោមនេះ គឺជាគំរូលទ្ធផលតេស្តមន្ទីរពិសោធន៍ ឆ្នាំ២០២៥ ជាមួយលទ្ធផលតេស្ត៣៧មុខ។ ម្យ៉ាងទៀត នៅក្នុងឆ្នាំ២០២៥ យើងបានរៀបចំបន្ថែមតេស្តកាល់ស្យូម (Calcium) និងបានបន្ថែមលទ្ធផលតេស្តទឹកនោមបួនមុខបន្ថែមទៅលើលទ្ធផលតេស្តបួនមុខដែលមានស្រាប់ ដែលនាំឱ្យលទ្ធផលតេស្តកើនពី ៣២មុខទៅ ៣៧មុខនៅក្នុងឆ្នាំ២០២៥នេះ ដើម្បីជួយផ្តល់ព័ត៌មានបន្ថែមក្នុងការធ្វើរោគវិនិច្ឆ័យលើបញ្ហាសុខភាពផ្សេងៗទៀត។

The name of each test is written both in Khmer and English. The presentation of results is to help patients understand and peer educators explain the results to the patients. The database allows us to print the last three lab profiles of the same patient. This helps everyone to see in a glance of what is happening with the trend of each indicator. This lab profile saves the doctors time during the medical consultation. On the next page you will see the standard model of the laboratory profile used in 2025 with 37 indicators. From the beginning of 2025, we added one blood test which is Calcium and added four urine test results so that the indecators increased from 32 to 37 to help the doctor diagnose the complications.

មណ្ឌល ព័ត៌មាន ជំងឺ

Patient Information Centre
MoPoTsyo

ផ្ទះលេខ 9E ផ្លូវលេខ 3C
ភូមិទ្រា១ សង្កាត់ស្ទឹងមានជ័យ
ខណ្ឌមានជ័យ រាជធានីភ្នំពេញ
លេខទូរសព្ទ +855 12 602 553
គេហទំព័រ https://mopotsyo.org

ផ្តល់សេវាវេជ្ជសាស្ត្រមិនស្វែងរកប្រាក់ចំណេញ ផ្នែកមន្ទីរពិសោធន៍ (Not-For-Profit Medical Laboratory Unit)

លទ្ធផលតេស្តមន្ទីរពិសោធន៍ (Laboratory Test Result)

លេខកូដសមាជិក (Patient Code) :	កាលបរិច្ឆេទបូមឈាម (Sampling Date) :
ឈ្មោះសមាជិក (Patient Name) :	កាលបរិច្ឆេទលទ្ធផល (Result Date) :
ភេទ (Sex) :	លេខប័ណ្ណស្នើសុំ (Request No) :
អាយុ (Age) :	ផ្សេងៗ (Other) :

ល.រ No	បរិយាយតេស្ត Description	07-03-2024	05-09-2024	30-04-2025	ឯកតា Unit	គោលដៅកំណត់ធម្មតា Normal Range
I - លទ្ធផលតេស្តឈាម (Blood Biochemistry)						
1	អេចប៊ីអេវ័នស៊ី (HbA1c)	**9.5**	**6.9**	**6.7**	%	ចន្លោះពី 4.0 ទៅ 6.0% (សំរាប់អ្នកគ្មានជំងឺទឹកនោមផ្អែម) ចន្លោះពី 6.5 ទៅ 7.0% (សំរាប់អ្នកជំងឺប្រើថ្នាំទឹកនោមផ្អែម)
2	ស្ករក្នុងឈាមមុនហូបអាហារ (Fasting Blood Glucose)	**201**	**137**	95	mg/dl	ចន្លោះពី 60 ទៅ 109 mg/dl បង្ហាញថាដូចអ្នកគ្មានជំងឺទឹកនោមផ្អែម ចន្លោះពី 110 ទៅ 125 mg/dl បង្ហាញថាអ្នកត្រៀមមានជំងឺទឹកនោមផ្អែម ច្រើនជាងរឺស្មើ 126 mg/dl បង្ហាញថាអ្នកមានជំងឺទឹកនោមផ្អែម
3	ប៉ូតាស្យូម (Potassium)	4.2	3.9	4.0	mmol/l	ចន្លោះពី 3.5 ទៅ 5.0 មីលីមូលក្នុងមួយលីត្រ
4	សូដ្យូម (Sodium)	143	140	142	mmol/l	ចន្លោះពី 135 ទៅ 145 មីលីមូលក្នុងមួយលីត្រ
5	ក្លរ (Chloride)	101	101	103	mmol/l	ចន្លោះពី 98 ទៅ 108 មីលីមូលក្នុងមួយលីត្រ
6	កាល់ស្យូម (Calcium)			**8.1**	mg/dl	ចន្លោះពី 8.5 ទៅ 10.2 មីលីក្រាមក្នុងមួយដេស៊ីលីត្រ
7	ទ្រីគ្លីសឺរ៉ាយ (Triglycerides)	148	73	**151**	mg/dl	តិចជាង 150 មីលីក្រាមក្នុងមួយដេស៊ីលីត្រ
8	កូលេស្តេរ៉ុលសរុប (Total Cholesterol)	96	122	119	mg/dl	តិចជាង 200 មីលីក្រាមក្នុងមួយដេស៊ីលីត្រ
9	អេចឌីអិល (HDL Cholesterol)	43	50	43	mg/dl	ចន្លោះពី 40 ទៅ 70 មីលីក្រាមក្នុងមួយដេស៊ីលីត្រ
10	អិលឌីអិល (Estimated LDL Cholesterol)	23	57	45	mg/dl	ចន្លោះពី 62 ទៅ 99 mg/dl អត់មានបញ្ហាខ្លាញ់មិនល្អ ចន្លោះពី 100 ទៅ 159 mg/dl ត្រៀមមានបញ្ហាខ្លាញ់មិនល្អ ច្រើនជាងរឺស្មើ 160 mg/dl មានបញ្ហាខ្លាញ់មិនល្អ
11	ត្រង់សាមីនាស (ALT)	**62**	**97**	25	U/L	ចន្លោះពី 7 ទៅ 50 ឯកតាក្នុងមួយលីត្រ
12	ត្រង់សាមីនាស (AST)	**53**	**51**	22	U/L	ចន្លោះពី 10 ទៅ 40 ឯកតាក្នុងមួយលីត្រ
13	គ្រេអាទីនីន (Creatinine)	**1.4**	1.1	1.0	mg/dl	ពី 0.7 ទៅ 1.2 មីលីក្រាមក្នុងមួយដេស៊ីលីត្រសំរាប់បុរស
14	យូរ៉ៀ (Urea)	33	29	34	mg/dl	ពី 19 ទៅ 44 មីលីក្រាមក្នុងមួយដេស៊ីលីត្រសំរាប់បុរស
15	អ៊ី ជី អែរ អរ (eGFR)	**49**	>60	>60	mL/min	ធំជាង 60 មីលីលីត្រក្នុងមួយនាទី
16	អាស៊ីតយូរិក (Uric Acid)	6.4	5.7	7.1	mg/dl	ចន្លោះពី 3.4 ទៅ 7.2 មីលីក្រាមក្នុងមួយដេស៊ីលីត្រឈាម សំរាប់បុរស
II - លទ្ធផលវិភាគកោសិកាឈាម (Complete Blood Count)						
17	កោសិកាឈាមក្រហម (RBC)	**4.47**	4.51	**4.04**	x10¹²/l	ពី 4.50 ទៅ 5.80 សំរាប់បុរស
18	ហេម៉ូក្លូប៊ីន (HGB)	13.8	13.2	**12.5**	g/dl	ពី 13.0 ទៅ 17.0 សំរាប់បុរស
19	ហេម៉ាតូគ្រីត (HCT)	41	41	**36**	%	ពី 40 ទៅ 50 សំរាប់បុរស
20	ទំហំកោសិកាឈាមក្រហម (MCV)	92	91	90	fl	ពី 80 ទៅ 100 សំរាប់បុរស
21	ចំនុះហេម៉ូក្លូប៊ីន (MCH)	31	29	31	pg	ពី 25 ទៅ 35 សំរាប់ស្ត្រី និងបុរស

លេខកូដសមាជិក (Patient Code) :					ឈ្មោះសមាជិក (Patient Name) :	
ល.រ No	**បរិយាយតេស្ត Description**	**07-03-2024**	**05-09-2024**	**30-04-2025**	**ឯកតា Unit**	**តម្លៃដែលកំណត់ធម្មតា Normal Range**
22	កំហាប់ហេម៉ូក្លូប៊ីន (MCHC)	34	32	34	g/dl	ពី 32 ទៅ 36 សំរាប់ស្ត្រី និងបុរស
23	កោសិកាឈាមស (WBC)	6.90	5.9	6.39	$x10^9/l$	ពី 4.00 ទៅ 11.00 សំរាប់ស្ត្រី និងបុរស
24	ណឺត្រូហ្វីល (Neu)	**52**	**39**	**52**	%	ពី 55 ទៅ 65 សំរាប់ស្ត្រី និងបុរស
25	អ៊ីអូស៊ីណូហ្វីល (Eos)	02	02	02	%	ពី 01 ទៅ 03 សំរាប់ស្ត្រី និងបុរស
26	បាសូហ្វីល (Bas)	01	01	01	%	ពី 00 ទៅ 01 សំរាប់ស្ត្រី និងបុរស
27	លីមហ្វូសាយ (Lym)	38	49	37	%	ពី 25 ទៅ 55 សំរាប់ស្ត្រី និងបុរស
28	ម៉ូណូសាយ (Mon)	07	09	08	%	ពី 03 ទៅ 10 សំរាប់ស្ត្រី និងបុរស
29	ផ្លាកែត (Platelets)	221	215	196	$x10^9/l$	ពី 150 ទៅ 400 សំរាប់ស្ត្រី និងបុរស
III - លទ្ធផលតេស្តទឹកនោម (Urine Test Result)						
30	ប្រូតេអ៊ីនក្នុងទឹកនោម (Proteinuria)	-	-	-	សញ្ញា	- គ្មានប្រូតេអ៊ីនក្នុងទឹកនោម +- សង្ស័យមានប្រូតេអ៊ីនក្នុងទឹកនោម + មានប្រូតេអ៊ីនក្នុងទឹកនោម
31	អាល់ប៊ូមីនក្នុងទឹកនោម (Albuminuria)	**30**	10	10	mg/L	តិចជាង 20 មីលីក្រាមក្នុងមួយលីត្រ
32	គ្រេអាទីនីន (Creatinine)	200	200	100	mg/dl	ចន្លោះពី 10 ទៅ 300 មីលីក្រាមក្នុងមួយដេស៊ីលីត្រ
33	អនុបាតអាល់ប៊ូមីនទៅគ្រេអាទីនីន (Albumin-to-Creatinine Ratio)	<30	<30	<30	mg/g	តូចជាង 30 ធម្មតា ពី 30 ទៅ 300 mg មិនធម្មតាតិច ធំជាង 300 mg មិនធម្មតាច្រើន
34	កេតូន Ketones			-	សញ្ញា	- គ្មានកេតូនក្នុងទឹកនោម + មានកេតូនក្នុងទឹកនោម
35	នីត្រាយ (Nitrite)			-	សញ្ញា	- គ្មាននីត្រាយក្នុងទឹកនោម + មាននីត្រាយក្នុងទឹកនោម
36	កោសិកាឈាមស (Leukocytes)			-	សញ្ញា	- គ្មានកោសិកាឈាមសក្នុងទឹកនោម +- សង្ស័យមានកោសិកាឈាមសក្នុងទឹកនោម + មានកោសិកាឈាមសក្នុងទឹកនោម
37	ភាវិតជាតិទឹក (Specific Gravity)			1.010	.	ចន្លោះពី 1.010 ទៅ 1.030

យោបល់បន្ថែម/Additional Comments:

សំគាល់៖ សូមយកលទ្ធផលតេស្តនេះទៅជាមួយរាល់ពេលដែលអ្នកទៅត្រួតពិនិត្យ និងពិគ្រោះជំងឺជាមួយគ្រូពេទ្យព្យាបាល។

អ្នកបច្ចេកទេសមន្ទីរពិសោធន៍ (Laboratory Technician) Mey Sopheak 0977573911		គ្រប់គ្រងសេវាមន្ទីរពិសោធន៍ សុខ ផល្លី 012 820 865

សេវាពិគ្រោះជំងឺ CONSULTATION SESSIONS

នៅក្នុងឆ្នាំ២០២៥ ការពិគ្រោះជំងឺ ត្រូវបានរៀបចំដោយអង្គការ ម.ព.ជ. នៅមូលដ្ឋានសុខាភិបាលសាធារណៈ ៣៤ទីតាំង ក្នុងស្រុកប្រតិបត្តិចំនួន២៥។ ភាគច្រើន ជាមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាពតាមជនបទ (CPA1, CPA2 ឬ MPA) ក្នុងបន្ទប់នៅមន្ទីរពេទ្យដែលទុកទំនេរ ឬទុកសម្រាប់ការណាត់ជួបរាល់ ១ ឬ២សប្តាហ៍ម្តង។ វេជ្ជបណ្ឌិតរបស់មន្ទីរពេទ្យបង្អែក/មណ្ឌលសុខភាពផ្ទាល់ម្នាក់ឬច្រើន ជាអ្នកផ្តល់សេវាដោយមានមិត្តអប់រំមិត្តសម្របសម្រួលការណាត់ជួប។ ការណាត់គឺ អាចមានរយៈពេលកន្លះថ្ងៃ (ព្រឹក ឬរសៀល) ដែលមានអ្នកជំងឺចន្លោះ ៣០នាក់ ទៅ ៥0នាក់ មកទទួលសេវាពិគ្រោះ។ សម្រាប់ការពិគ្រោះជំងឺ គឺប្រមាណ ៥៥0៣៣ដង នៅឆ្នាំ២០២៥។ អង្គការ ម.ព.ជ. មានកិច្ចសន្យាជាមួយវេជ្ជបណ្ឌិតមូលដ្ឋាន ក្នុងការគាំទ្រថែរក្សាដើម្បីបំប៉នសមត្ថភាព មុនផ្តល់សេវាពិគ្រោះជំងឺជូនអ្នកជំងឺជាសមាជិក។ វេជ្ជបណ្ឌិតម្នាក់ក្នុងចំណោមពួកគេជួបម្តង ឬបួនដងក្នុង១ខែ សម្រាប់ការពិគ្រោះជំងឺរយៈពេល១ព្រឹក ឬ១រសៀល។

ផ្នែកគ្រប់គ្រងកម្មវិធីរបស់អង្គការ ម.ព.ជ. រៀបចំការណាត់ជួបសម្រាប់ការពិគ្រោះជំងឺទាំងនេះ អាស្រ័យទៅលើព័ត៌មានទទួលបាន តាមរយៈបណ្តាញមិត្តអប់រំមិត្តពីតម្រូវការក្នុងន័យផ្សេងទៀតគឺ បរិមាណតម្រូវការ ចាប់តាំងពីឆ្នាំ២0១៧មក កាលវិភាគនៃការពិគ្រោះជំងឺ គឺត្រូវបានរៀបចំ ដោយមានការសម្រេចចិត្តពីគ្រូពេទ្យរបស់មន្ទីរពេទ្យ/មណ្ឌលសុខភាព។ មិត្តអប់រំមិត្តធ្វើការងារដូចជា គ្រប់គ្រងក្រុមអ្នកជំងឺ ចុះឈ្មោះអ្នកជំងឺ រៀបចំបែបបទរដ្ឋបាល ។ល។ ជាកិច្ចការដែលក្នុងប្រទេសដទៃ ត្រូវធ្វើដោយគិលានុប្បដ្ឋាក និងបុគ្គលិកជំនាញរបស់មន្ទីរពេទ្យ។ កន្លែងខ្លះ ការណាត់ជួបនៅពេលព្រឹក និងកន្លែងខ្លះទៀត នៅពេល រសៀល។ ការណាត់ជួប អាចធ្វើនៅចុងសប្តាហ៍ប្រសិនបើ មន្ទីរពេទ្យបង្អែក/មណ្ឌលសុខភាព ចង់រៀបចំសេវា ដើម្បីសម្រួលដល់អ្នកជំងឺដែលត្រូវការអ្នកជូនដំណើរ។ វាមានអត្ថប្រយោជន៍ផ្សេងៗគ្នា ក្នុងការអនុញ្ញាតិឱ្យមិត្តអប់រំមិត្តចូលរួមការគ្រប់គ្រង លើការផ្តល់សេវាឱ្យសមាជិករួមមាន ប៉ុន្តែមិនកំណត់ចំពោះ៖

1) បន្ថយថ្លៃចំណាយសរុប ពីព្រោះពេលវេលារបស់គិលានុប្បដ្ឋាកគឺ ថ្លៃជាងពេលវេលារបស់មិត្តអប់រំមិត្ត។
2) អ្នកជំងឺជឿទុកចិត្ត និងស្និតស្នាលជាមួយមិត្តអប់រំមិត្ត ពីព្រោះពួកគាត់ស្គាល់អ្នកជំងឺច្បាស់ និងរស់នៅក្នុងសហគមន៍តែមួយ។

In 2025, medical consultations are organised in 34 public facilities in 25 Operational Districts, mostly at rural referral hospitals (CPA1 or CPA2) in a room at the hospital that is made available or kept available for these weekly or 2-weekly sessions. Only government staff, 1 or more doctors, are doing the medical consultations. Peer Educators help as process facilitiators. A session lasts half a day during which some 30 to 50 patients receive medical consultation. For 55,033 medical consultations in 2025, MoPoTsyo contracted with Doctors at the local health facilities to get refresher-training and to provide consultation to the patients. Every one of them consults once or a couple of times per month, during a half day (morning/afternoon).

MoPoTsyo's Program Department plans these sessions, based on information it receives through the representative of the peer educators in the OD about the size of need, in other words "the volume of the expected demand". Since mid 2017, the consultation schedules are agreed with the local government doctors at the Referral Hospitals. The PEs perform tasks such as crowd control, registration, preparation, administration etc., tasks that in other countries are done by nurses and other professional hospital staffs. Some places the session is in the morning, some other places in the afternoon, but never the whole day. If patients and doctors prefer, they can organize it at weekends. This can be more convenient for elderly patients who depend on children for transport. There are advantages in letting the PEs join in the management of the service delivery to the members such as:

1. Lower overall cost because nurse time is much more expensive than PE time.
2. Patients trust and feel close to the PEs because they know them personally and live in the same community.

3) មិត្តអប់រំមិត្តអាចស្គាល់ពីការព្យាបាល រឺការណែនាំរបស់គ្រូពេទ្យ ជារឿយៗ វាមានប្រយោជន៍ ប្រសិនបើមិត្តអប់រំមិត្តនិយាយម្តងហើយម្តងទៀតនូវដំបូន្មានរបស់គ្រូពេទ្យ ពេលត្រលប់ទៅសហគមន៍វិញ។

ដោយសារជាញឹកញាប់ អ្នកជំងឺមិនសូវចងចាំនូវអ្វីដែលគ្រូពេទ្យបានប្រាប់ពួកគេ កាលណាពួកគេនៅក្រៅ ឬត្រលប់ទៅផ្ទះវិញ ដូច្នេះតួនាទីមិត្តអប់រំមិត្តនៅតាមសហគមន៍ បានរួមចំណែកជាច្រើនសំរាប់អ្នកជំងឺ ដូចជា ៖

1. ឥទ្ធិពលការជំរុញលើកទឹកចិត្ត និងភាពម្ចាស់ការលើសេវាដោយមិត្តអប់រំមិត្ត។
2. មិត្តអប់រំមិត្តផ្តល់ការការពារ លើការបាត់បង់ភាពស៊ីចង្វាក់គ្នា រវាងការចេញវេជ្ជបញ្ជាដោយគ្រូពេទ្យ និងការចែកចាយថ្នាំតាមរយៈមូលនិធិ ឱសថបង្វិលទុន ធ្វើដោយប្រុងប្រយ័ត្ន និងការត្រួតពិនិត្យលើសេវា។
3. មិត្តអប់រំមិត្តមានពេលវេលា/ម៉ោងងាយស្រួលសម្រាប់ការពិគ្រោះគ្នា (ចុងសប្តាហ៍) ក្រៅម៉ោងធ្វើការ។
4. ការផ្តល់សេវាគឺមានលក្ខណៈសាមញ្ញច្រើន និងភាពសប្បាយច្រើនសម្រាប់គ្រប់ៗគ្នា។
5. មានមិត្តអប់រំមិត្តម្នាក់បង្កើតឱ្យមានបរិយាកាសការងារសមតាមបំណងសម្រាប់វេជ្ជបណ្ឌិត។

ក្នុងឆ្នាំ២០២៥ ចំនួននៃការពិគ្រោះបានបន្តថយចុះប្រមាណ ១.១% ឬបានបានថយពី ៥៥៦៣៣ដង (ឆ្នាំ២០២៤) មកត្រឹម៥៥០៣៣ដង (ឆ្នាំ២០២៥)។ ចំនួនវេននៃការពិគ្រោះជំងឺធ្វើដោយវេជ្ជបណ្ឌិតបានកើនពី១០៥៣វេន ដល់១០៩៩វេន ធៀបរយៈពេលដូចគ្នា។ ប៉ុន្តែ ចំនួនករណីពិគ្រោះជាមធ្យមប្រចាំវេននីមួយៗបានថយចុះពី៥៣នាក់/វេន នៅឆ្នាំ២០២៤ មកត្រឹម៥០នាក់/វេននៅឆ្នាំ២០២៥។ ពួកយើងបានធ្វើការជាមួយវេជ្ជបណ្ឌិតរបស់មន្ទីរពេទ្យបង្អែក/មណ្ឌលសុខភាព ដៃគូ ច្រើនជាង៧៣នាក់ ផ្តល់សេវាពិគ្រោះប្រមាណ៥៥ ០៣៣ ដង ទៅឱ្យសមាជិករបស់យើង។ វាជាគំរូសហការផ្តល់សេវារវាងអង្គការ ម.ព.ជ. និងមន្ទីរពេទ្យ/មណ្ឌលសុខភាព ក្រោយពីវេជ្ជបណ្ឌិតមកពីមូលដ្ឋានសុខាភិបាលទាំងនោះ បានបណ្តុះបណ្តាលបំប៉នបន្ថែមរយៈពេល២សប្តាហ៍។ ត្រឹមដំណាច់ឆ្នាំ ២០២២ ម.ព.ជ. បានសហការជាមួយមជ្ឈមណ្ឌលវេជ្ជសាស្ត្រសហគមន៍ (Hope Worldwide) និងចាប់ពីខែមករាឆ្នាំ២០២៣ អង្គការ ម.ព.ជ. បានបន្តកិច្ចសហការជាមួយ មន្ទីរពេទ្យព្រះសីហនុមណ្ឌលនៃក្តីសង្ឃឹម ដើម្បីបើកវគ្គបំប៉នវេជ្ជបណ្ឌិត។

3. PEs can hear the doctor's treatment or advice. Often it is helpful if PEs repeat and repeat again the advice of the doctor, later back in the community.

Because very often patients do not remember what the doctor told them once they are outside or back home again, so through their roles in community the peer educator help patients a lot:

1. Prestige, motivation, and ownership of the service by the PEs
2. PEs provide a safeguard against loss of coherence between prescription by doctors and dispensing of medication through the RDF, by being vigilant and monitoring services.
3. PEs offer convenient hours/time for consultation (weekends) outside working hours.
4. Service provision is more casual and more fun for everyone.
5. Having a PE creates a more satisfactory work environment for the Doctor.

During 2025, the number of consultations decreased about 1.1%. It decreased from 55,633 consultations (2024) to 55,033 consultations (2025). The number of consultation sessions increased from 1,053 times to 1,099 times. As results, the number of patients decreased from 53 patients per session in 2024 to 50 patients per session in 2025. We have been working with more than 73 local doctors and receiving 55,033 times consultation services. This is a cooperation model of service between MoPoTsyo and local health facilities after the local doctors received the refresher-training on medical consultation for diabetes and hypertension during 2 weeks at our training center's partner – Hope Worldwide and Preah Sihanuok Hospital.

តារាងទី ១៖ សេវាពិគ្រោះជាមួយវេជ្ជបណ្ឌិតក្នុងឆ្នាំ២០២៥ Medical consultations by doctors in 2025

ល.រ	គ្រូពេទ្យនៅតាមមន្ទីរពេទ្យបង្អែក/ មណ្ឌលសុខភាពមូលដ្ឋាន	ចំនួនពិគ្រោះជំងឺ	ភាគរយ
1	គ្រូពេទ្យ/Dr. 1	8442	15.3%
2	គ្រូពេទ្យ/Dr. 2	3342	6.1%
3	គ្រូពេទ្យ/Dr. 3	2918	5.3%
4	គ្រូពេទ្យ/Dr. 4	1549	2.8%
5	គ្រូពេទ្យ/Dr. 5	1464	2.7%
6	គ្រូពេទ្យ/Dr. 6	1373	2.5%
7	គ្រូពេទ្យ/Dr. 7	1317	2.4%
8	គ្រូពេទ្យ/Dr. 8	1304	2.4%
9	គ្រូពេទ្យ/Dr. 9	1183	2.1%
10	គ្រូពេទ្យ/Dr. 10	1148	2.1%
11	គ្រូពេទ្យ/Dr. 11	1136	2.1%
12	គ្រូពេទ្យ/Dr. 12	1130	2.1%
13	គ្រូពេទ្យ/Dr. 13	1100	2.0%
14	គ្រូពេទ្យ/Dr. 14	1058	1.9%
15	គ្រូពេទ្យ/Dr. 15	1040	1.9%
16	គ្រូពេទ្យ/Dr. 16	1037	1.9%
17	គ្រូពេទ្យ/Dr. 17	993	1.8%
18	គ្រូពេទ្យ/Dr. 18	934	1.7%
19	គ្រូពេទ្យ/Dr. 19	881	1.6%
20	គ្រូពេទ្យ/Dr. 20	841	1.5%
21	គ្រូពេទ្យ/Dr. 21	838	1.5%
22	គ្រូពេទ្យ/Dr. 22	837	1.5%
23	គ្រូពេទ្យ/Dr. 23	774	1.4%
24	គ្រូពេទ្យ/Dr. 24	741	1.3%
25	គ្រូពេទ្យ/Dr. 25	706	1.3%
26	គ្រូពេទ្យ/Dr. 26	688	1.3%
27	គ្រូពេទ្យ/Dr. 27	683	1.2%
28	គ្រូពេទ្យ/Dr. 28	659	1.2%
29	គ្រូពេទ្យ/Dr. 29	636	1.2%
30	គ្រូពេទ្យ/Dr. 30	632	1.1%
31	គ្រូពេទ្យ/Dr. 31	616	1.1%
32	គ្រូពេទ្យ/Dr. 32	566	1.0%
33	គ្រូពេទ្យ/Dr. 33	557	1.0%
34	គ្រូពេទ្យ/Dr. 34	540	1.0%
35	គ្រូពេទ្យ/Dr. 35	534	1.0%
36	គ្រូពេទ្យ/Dr. 36	532	1.0%
37	គ្រូពេទ្យ/Dr. 37	528	1.0%
38	គ្រូពេទ្យ/Dr. 38	516	0.9%
39	គ្រូពេទ្យ/Dr. 39	512	0.9%
40	គ្រូពេទ្យ/Dr. 40	504	0.9%

41	គ្រូពេទ្យ/Dr. 41	501	0.9%
42	គ្រូពេទ្យ/Dr. 42	441	0.8%
43	គ្រូពេទ្យ/Dr. 43	415	0.8%
44	គ្រូពេទ្យ/Dr. 44	406	0.7%
45	គ្រូពេទ្យ/Dr. 45	403	0.7%
46	គ្រូពេទ្យ/Dr. 46	387	0.7%
47	គ្រូពេទ្យ/Dr. 47	382	0.7%
48	គ្រូពេទ្យ/Dr. 48	378	0.7%
49	គ្រូពេទ្យ/Dr. 49	348	0.6%
50	គ្រូពេទ្យ/Dr. 50	344	0.6%
51	គ្រូពេទ្យ/Dr. 51	343	0.6%
52	គ្រូពេទ្យ/Dr. 52	336	0.6%
53	គ្រូពេទ្យ/Dr. 53	326	0.6%
54	គ្រូពេទ្យ/Dr. 54	322	0.6%
55	គ្រូពេទ្យ/Dr. 55	292	0.5%
56	គ្រូពេទ្យ/Dr. 56	244	0.4%
57	គ្រូពេទ្យ/Dr. 57	239	0.4%
58	គ្រូពេទ្យ/Dr. 58	234	0.4%
59	គ្រូពេទ្យ/Dr. 59	233	0.4%
60	គ្រូពេទ្យ/Dr. 60	205	0.4%
61	គ្រូពេទ្យ/Dr. 61	179	0.3%
62	គ្រូពេទ្យ/Dr. 62	175	0.3%
63	គ្រូពេទ្យ/Dr. 63	166	0.3%
64	គ្រូពេទ្យ/Dr. 64	155	0.3%
65	គ្រូពេទ្យ/Dr. 65	139	0.3%
66	គ្រូពេទ្យ/Dr. 66	113	0.2%
67	គ្រូពេទ្យ/Dr. 67	89	0.2%
68	គ្រូពេទ្យ/Dr. 68	78	0.1%
69	គ្រូពេទ្យ/Dr. 69	72	0.1%
70	គ្រូពេទ្យ/Dr. 70	60	0.1%
71	គ្រូពេទ្យ/Dr. 71	55	0.1%
72	គ្រូពេទ្យ/Dr. 72	42	0.1%
73	គ្រូពេទ្យ/Dr. 73	30	0.1%
74	គ្រូពេទ្យផ្សេងៗ	112	0.2%
	សរុប	55033	100.0%

វាគឺជា ប្រព័ន្ធណាត់ជួបពិគ្រោះដែលសម្របសម្រួលតាមរយៈបណ្តាញមិត្តអប់រំមិត្តសម្រាប់តែសមាជិក។ ការចំណាយរបស់អ្នកជំងឺគឺសម្រាប់សេវាហិរញ្ញប្បទាន ប្រាក់លើកទឹកចិត្តវេជ្ជបណ្ឌិត ប្រាក់លើកទឹកចិត្តក្រុមមិត្តអប់រំមិត្ត និងសម្ភារបម្រើឱ្យការងារពិគ្រោះជំងឺ មិនមែនបង់ទៅអង្គការ ម.ព.ជ. ឡើយ។ អង្គការ ម.ព.ជ. មានតួនាទីជួយសម្របសម្រួលសេវាពិគ្រោះ ឱ្យអាចដំណើរការទៅបាន។

ខាងក្រោម ជាការគណនាថ្លៃចំណាយក្នុងឆ្នាំ២០២៥ ដែលមានការណាត់ជួបសម្រាប់ពេលពាក់កណ្តាលព្រឹកចំនួន ១ ០៩៩ដង។

It is the special appointment between doctors and registered patients in the network through organizing by peer educators. Fund contribution is to contribute for User Fee, doctor's incentive, peer's incentive and materials with facilitation by MoPoTsyo.

Below is the calculation of the expenditure in 2025 during which there were 1,099 sessions.

តារាងទី 10៖ ការងារពិគ្រោះជំងឺក្នុងឆ្នាំ២០២៥ Medical consultations in 2025

ឆ្នាំ ២០២៥ Year 2025	សរុប Total	ម.ប្រចាំឆ្នាំ/ទីតាំង Annual AVG/Location	ម.ប្រចាំខែនៃចំនួនពិគ្រោះ Monthly AVG Num. of Consultations
1- ចំនួនដងនៃការពិគ្រោះ ជម្ងឺ Nr of consultation (ករណី)	**55,033**	**1,619**	**4,586**
2- ថ្លៃចំណាយសរុប (រៀល) Total cost (sum of Line3 to line12)	**588,075,000៛**	**17,296,324**	**49,006,250៛**
2a- ហិរញ្ញប្បទានមន្ទីរពេទ្យ និងប្រាក់លើកទឹកចិត្តវេជ្ជ.មូលដ្ឋាន User fee and Incentive for Local doctors	378,659,500៛	11,137,044៛	31,554,958៛
2b- សេវាមិត្តអប់រំមិត្ត Service for Peer Educator	55,033,000៛	1,618,618៛	4,586,083៛
2c- សេវាអ្នកគ្រប់គ្រងមិត្តអប់រំមិត្ត Service for ODPM	82,549,500៛	2,427,926៛	6,879,125៛
2d- សេវាលើកទឹកចិត្តក្រុមមិត្តអប់រំមិត្តចូលរួមវេនពិគ្រោះ Service for PE per session	32,970,000៛	969,706៛	2,747,500៛
2e- ថ្លៃចំណាយសំភារៈ Materials	23,477,813៛	690,524៛	1,956,484៛
2f- ថ្លៃផ្ញើរសំភារៈ/ឯកសារ Delivery of Materials and Documents	6,558,180៛	192,888៛	546,515៛
2g- ថ្លៃសេវាផ្ទេរប្រាក់តាមធនាគារ/វីង Bank/WING transaction Fee	488,000៛	14,353៛	40,667៛
2h- ថ្លៃចោះពុម្ព ថតចំលង Copy and Printing	8,339,007៛	245,265៛	694,917៛
2i-ថ្លៃចំណាយសម្រាប់វគ្គបណ្តុះបណ្តាលវេជ្ជបណ្ឌិត Refresher Training Local Doctors: 2 weeks (Cancelled)	0៛	0៛	0៛
2j-សិក្ខាសាលាបំប៉នសមត្ថភាពវេជ្ជបណ្ឌិត ២ថ្ងៃ 2-day-Seminar on Doctors' Capacilty Strengthening (cancelled)	0៛	0៛	0៛
2k-ថ្លៃចំណាយសម្រាប់រៀបចំទីតាំងពិគ្រោះថ្មី Setting up new consultation locations	0៛	0៛	0៛
3- ចំនួនដងនៃការពិគ្រោះ ជម្ងឺ (ដង) Nr of cons. Session	**1099**	**32**	**92**
4- ចំនួនពិគ្រោះ ជំងឺជាមធ្យមក្នុងមួយដង(ករណី) **AVG of Consultation per session**	**50**	**-**	**-**
5- ថ្លៃពិគ្រោះ ជម្ងឺម្នាក់(រៀល) Cost per consultation	**10,686៛**	-	-

រូបភាពទី17៖ ចំនួនការពិគ្រោះជំងឺតាមក្រុមអាយុ ដល់ឆ្នាំ២០២៥ Medical consultations by age groups 2025



រូបភាពទី18៖ ការប្រើសេវាពិគ្រោះធៀបនឹងចំនួនសមាជិកតាមក្រុមអាយុ Medical consultations by age groups (%)



តាមរបាយការណ៍ប្រើប្រាស់សេវា ជាភស្តុតាងបង្ហាញច្បាស់ថា អ្នកជំងឺលើសសម្ពាធឈាមគ្មានទឹកនោមផ្អែម ស្ទើតែគ្រប់តំបន់ អំពីចំនួនអ្នកជំងឺលើសសម្ពាធឈាមគ្មានទឹកនោមផ្អែមមកទទួលសេវា នៅមានកម្រិតទាបនៅឡើយ។

តារាងខាងក្រោម គឺចង់បង្ហាញថា ទោះបីជាមានការរីកចម្រើនខ្លះៗកន្លងមក ប៉ុន្តែយើងត្រូវបន្តយកចិត្តទុកដាក់ជំរុញឱ្យអ្នកជំងឺលើសសម្ពាធឈាម មកទទួលយកសេវាឱ្យបានកាន់តែច្រើនថែមទៀត។

Throughout the report the under-utilization of services by non-diabetic hypertension patients is evident. In almost all the areas, the number of patients who received service is still low.

The table below shows that cases number continued to decline and that we must continue to encourage more non-diabetic hypertension patients to receive medical consultation service.

តារាងទី 11៖ ការប្រើសេវាពិគ្រោះតាមប្រភេទជំងឺ តាមឆ្នាំនីមួយៗ Yearly use of medical consultation by type of diseases

ការពិគ្រោះជំងឺសម្របសម្រួលដោយបណ្តាញមិត្តអប់រំមិត្តនៅកន្លែងផ្តល់សេវាសាធារណៈ Medical consultations facilitated by the Peer educator networks in the public services				
ឆ្នាំ Year	អ្នកជំងឺទឹកនោមផ្អែម គ្មានលើសសម្ពាធឈាម Diabetes, no hypertension	អ្នកជំងឺទឹកនោមផ្អែម និងលើសសម្ពាធឈាម Diabetes & Hypertension	អ្នកជំងឺលើសសម្ពាធឈាម គ្មានទឹកនោមផ្អែម Hypertension no Diabetes	សរុប Total
2007	42	92	0	**134**
2008	180	511	8	**699**
2009	370	800	15	**1,185**
2010	664	1,093	295	**2,052**
2011	1,709	3,045	1,355	**6,109**
2012	3,030	5,080	2,330	**10,440**
2013	4,006	5,265	2,466	**11,737**
2014	5,955	6,834	3,161	**15,950**
2015	7,009	6,784	3,157	**16,950**
2016	9,141	7,910	3,876	**20,927**
2017	9,851	8,365	3,463	**21,679**
2018	12,507	10,767	3,050	**26,324**
2019	16,862	13,164	4,076	**34,102**
2020	20,606	16,140	5,124	**41870**
2021	17,944	14,380	4,898	**37,222**
2022	24,154	20,858	5,966	**50,978**
2023	28,655	28,318	7,233	**64,206**
2024	24,306	25,024	6,303	**55,633**
2025	23,260	25,488	6,285	**55,033**

ដូចឆ្នាំកន្លងៗទៅដែរ ក្នុងឆ្នាំ២០២៥ អ្នកជំងឺទឹកនោមផ្អែមភាគច្រើនដែលបានទៅជួបគ្រូពេទ្យ គឺមិនមែនជាការទៅជួបលើកទី១ទេ គឺពួកគេទៅជួបតាមការណាត់របស់គ្រូពេទ្យ។ ក្នុងប្រព័ន្ធទិន្នន័យបានបង្ហាញថា មានអ្នកជំងឺថ្មីត្រឹមតែ ៤២៧៩នាក់ បានមកជាលើកដំបូងក្នុងឆ្នាំ២០២៥។ មូលដ្ឋានទិន្នន័យរបស់អង្គការ ម.ព.ជ. បានកត់ត្រាឡើងវិញតាំងពីឆ្នាំ២០០៧ បន្តបន្ទាប់មក។ ការកត់ត្រាបានបង្ហាញថា ជាមធ្យមនៃការប្រើសេវានៃអ្នកជំងឺទឹកនោមផ្អែមទាំងនេះគឺ ១៧ដង គិតចាប់ពីពេលចុះឈ្មោះ ដល់ដំណាច់ឆ្នាំ២០២៥។

For most of the Diabetes patients in 2025 who went to see the doctor, it was not the first time they went for their doctor appoinments. MoPoTsyo database records showed that 4,279 DM patients came for the first time in 2025. We recorded the prescription since 2007; the average of these individual DM patients was 17 times since they registered until the end of 2025.

រូបភាពទី19៖ សមាមាត្រនៃការពិគ្រោះរបស់អ្នកជំងឺទឹកនោមផ្អែម Frequency proportions of medical consultations by DM patients



តារាងទី 12៖ ចំនួន និងភាគរយសមាជិកបានចុះឈ្មោះនៅបន្តប្រើសេវា Number and percentage of active members

សមាជិកបន្តប្រើសេវាបណ្តាញមិត្តអប់រំមិត្ត នាដំណាច់ឆ្នាំ២០២៥ Actively Using PE network services by the end of 2025	ចំនួនករណី	ភាគរយ
អ្នកជំងឺទឹកនោមផ្អែម	23,152	83.7%
អ្នកជំងឺលើសសម្ពាធឈាម	4,503	16.3%
សរុបសមាជិកទាំងអស់នៅបន្តប្រើសេវា	27,655	100.0%

និន្នាការបង្ហាញថា ការជឿទុកចិត្តលើសេវាវេជ្ជសាស្ត្រ គឺមានការរីកចំរើនជាបណ្តើរៗ ហើយអ្នកជំងឺទឹកនោមផ្អែមជាច្រើនបានត្រៀមខ្លួន ដើម្បីជួបជាមួយវេជ្ជបណ្ឌិត។

a) ក្នុងចំនោមអ្នកជំងឺទឹកនោមផ្អែម ភាគច្រើន ឥឡូវមានវេជ្ជបញ្ជា។

b) អ្នកជំងឺទឹកនោមផ្អែមទាំងនោះដែលមានវេជ្ជបញ្ជាទៅជួបគ្រូពេទ្យបានញឹកញាប់

ភាគបែងដែលសំខាន់បំផុត គឺជាចំនួនអ្នកជំងឺទឹកនោមផ្អែមដែលរស់នៅក្នុងតំបន់ (ទោះបីជាពួកគេបានចុះឈ្មោះ រឺក៏មិនបាន)។ ដូចនេះ ជាមូលដ្ឋានពួកយើងគួតែប្រើប្រាស់ប្រវ៉ាឡង់ប៉ាន់ស្មានអ្នកទឹកនោមផ្អែមជាភាគបែង។ បែបនេះអាចទៅរួចជាមួយការស្ទង់មតិម្តងហើយម្តងទៀតយ៉ាងទៀងទាត់ ដូចជាការស្ទង់មតិរបស់ STEP SURVEY ២០១០ ២០១៦ និង ២០២៣ ដែលសំណាកក្នុងការសិក្សាស្រាវជ្រាវនេះ ធំគ្រប់គ្រាន់ក្នុងការគណនារកនូវប្រវ៉ាឡង់ខុសគ្នា រវាងអ្នកទីក្រុង និងអ្នកនៅជនបទ។

The trend shows that, overall, the trust in the medical services is gradually improving and that more diabetics are ready to meet the doctor:

a) Among diabetics a larger proportion now has a prescription

b) Those diabetics who have a prescription go more often to the doctor

The most relevant denominator would be the number of diabetes patients who live in the area (whether they have been registered or not). So ultimately, we should use the estimated prevalence of diabetes as the denominator. This becomes possible with regularly repeated surveys such as the STEP Survey (2010, 2016, and 2023) provided that the sample is big enough to calculate a different prevalence rate in urban vs rural.

តាមការកត់ត្រា ក្នុងប្រព័ន្ធទិន្នន័យរបស់យើងបានបង្ហាញ មិនមែនគ្រប់សមាជិកទាំងអស់បានប្រើប្រាស់គ្រប់សេវាបណ្តាញមិត្តអប់រំមិត្តនោះទេ។ យើងបានធ្វើការវិភាគតាមការប្រើសេវានីមួយៗ ដូចរូបខាងក្រោម។

តាមរូបភាពបង្ហាញថា សេវាឱសថបង្ខិលទុនមានសមាជិកប្រើប្រាស់ច្រើនជាងគេគឺ ២០៤៨២នាក់ បន្តបន្ទាប់មកទៀត សេវាពិគ្រោះជំងឺមាន ១៧១៣០នាក់ និងសេវាតាមដានជាមួយមិត្តអប់រំមិត្ត ១៣១២៥នាក់។ សេវាដែលមានចំនួនអ្នកប្រើប្រាស់តិចជាងគេ គឺសេវាមន្ទីរពិសោធន៍វេជ្ជសាស្ត្រគឺត្រឹម ១១៩៧១នាក់។ អ្វីដែលគួរឱ្យចាប់អារម្មណ៍ចំនួនអ្នកប្រើសេវាបីរួមគ្នាគឺ តេស្តមន្ទីរពិសោធន៍ ពិគ្រោះជំងឺ និងសេវាឱសថបង្ខិលទុន មានចំនួនត្រឹមតែ ៩៨១៣នាក់ប៉ុណ្ណោះ។

Our database shows that not all the active members have been using PE services. We analysed the number of users by type of service, it shows as in the picture below.

There were 20,482 active members who used the RDF medication service followed by 17,130 active members having used the medical consultation service. And 13,125 active members have used the PE follow up service. Laboratory service had the smallest service utilization of 11,971 active members. Another interesting figure is that the number of users that used medical consultation as well as RDF medication and laboratory service together was only 9,813 cases.

រូបភាពទី20៖ ការប្រើប្រាស់តាមសេវារបស់សមាជិកបានចុះឈ្មោះ ***Services Usage by Registered patients***

Service used by members of MoPoTsyo in 2025

RDF Buyer	20,482
Follow-up with PE (PE-FU)	13,125
Medical Consultation	17,130
RDF & FU	7,424
RDF & MedCon	16,003
Lab & RDF & MedCon	9,813
Laboratory User	11,971



តារាងទី 13៖ %នៃការប្រើសេវាពិគ្រោះជំងឺនៃសមាជិកវ័យចាស់ឆ្នាំ២០១២-២០២៥ ***Access to medical consultation by elderly chronic patient members (DM+HBP) from 2012 to 2025***

ឆ្នាំ Year	2012	2013	2014	2015	2016	2017	2018	2019	2020	2021	2022	2023	2024	2025
ចំនួនដងការពិគ្រោះជំងឺ	10,303	11,738	15,950	16,950	20,927	21,679	26,324	34,102	41,870	37,210	50,978	64,206	55,633	55,033
>60ឆ្នាំ	3,694	4,365	6,214	6,890	8,918	9,905	12,017	14,257	17,978	16,344	27,853	27,657	27,618	27,766
>65ឆ្នាំ	2,068	2,331	3,429	3,688	5,307	5,866	6,408	8,360	10,467	9,625	13,557	16,286	16,743	17,498
ឆ្នាំ Year	**2012**	**2013**	**2014**	**2015**	**2016**	**2017**	**2018**	**2019**	**2020**	**2021**	**2022**	**2023**	**2024**	**2025**
ចំនួនដងការពិគ្រោះជំងឺ	10,303	11,738	15,950	16,950	20,927	21,679	26,324	34,102	41,870	37,210	50,978	64,206	55,633	55,033
(%)>60ឆ្នាំ	36%	37%	39%	41%	43%	46%	46%	42%	43%	44%	45%	43%	50%	50%
(%) >65ឆ្នាំ	20%	20%	22%	22%	25%	27%	24%	25%	25%	26%	27%	25%	30%	32%

បញ្ហាប្រើប្រាស់សេវាមន្ទីរពិសោធន៍ សម្រាប់វ័យចាស់នៅតែមានកម្រិតទាប។ ភាគរយនៃមនុស្សវ័យចាស់ ក៏មិនសូវរីកចម្រើនដែរ។ ជារួម ពួកយើងកំពុងធ្វើឱ្យកើនចំនួនអ្នកជំងឺប្រើប្រាស់សេវា ប៉ុន្តែពួកយើងនៅតែមិនអាចពង្រឹងការប្រើសេវាពិគ្រោះជំងឺសម្រាប់វ័យចាស់នៅឡើយ។ ឱកាសនៃការប្រើឱសថបង្ការទុនរបស់មនុស្សចាស់ គឺតាមរយៈការពិគ្រោះ។ ថវិកាចំណាយ មិនមែនជាបញ្ហាតែម្យ៉ាងនោះទេ អាចមានមូលហេតុផ្សេងៗទៀត ដូចជាការលំបាកក្នុងការធ្វើដំណើរ ភាពជរា និងត្រូវមានអ្នកជូន -ល- គឺសុទ្ធសឹងតែជាឧបសគ្គរាំងស្ទះ ដល់ឱកាសទទួលសេវាសម្រាប់វ័យចាស់។ ហើយបន្ទុកនេះ មិនអាចជាបន្ទុករបស់អ្នកជំងឺដែលងាយរងគ្រោះស្រាប់ទេ គឺទាមទារនូវអន្តរាគមន៍ជាក់លាក់។

We are not reducing the access problem to the laboratory services for elderly: percentage shows little or no improvement over the years in access for the elderly. We are increasing our numbers of patients in general, but we cannot improve access for the elderly to medical consultation. Old people's access to the RDF medicines is via medical consultation. Money is not their only problem: there can be other barriers such as travelling difficulty or lack of an elderly caretaker. And the burden cannot be left on the shoulders of patients who are already vulnerable, it is requiring an intervention.

ជាមួយវេជ្ជបញ្ជាពួកយើង មានន័យថា វេជ្ជបណ្ឌិតធ្វើការពិគ្រោះជំងឺ បានសរសេរក្នុងសៀវភៅតាមដានសុខភាពរបស់អ្នកជំងឺផ្ទាល់ខ្លួនម្នាក់ៗចេញដោយអង្គការ ម.ព.ជ.។ វេជ្ជបញ្ជាបានបង្ហាញ ថាតើថ្នាំមួយណាគួរតែត្រូវលេបរៀងរាល់ថ្ងៃ និងចំនួនគ្រាប់ថ្នាំ ដោយមានចុះហត្ថលេខា និងឈ្មោះរបស់វេជ្ជបណ្ឌិត។ ឧទាហរណ៍ ទៅយកសេវាថ្នាំរយៈពេល ៣០ថ្ងៃ ហើយអាចទទួលសេវាបានសម្រាប់ ៣ខែជាអតិប្បរមា។ នៅពេលថ្នាំអស់ អ្នកជំងឺអាចត្រលប់ទៅឱសថស្ថានវិញដោយកាន់វេជ្ជបញ្ជាដដែល ដើម្បីបង់បង្កាន់ដៃភាគទានសម្រាប់យកថ្នាំប្រើបន្ត។ មិត្តអប់រំមិត្ត ត្រូវតែតាមដានអ្នកជំងឺថាតើថ្នាំអ្នកជំងឺកំពុងប្រើនៅមានប្រសិទ្ធភាពត្រឹមត្រូវ ឬអត់។ ប្រសិន បើមិត្តអប់រំមិត្តឃើញថា ដល់ពេលវេលាត្រូវប្តូរវេជ្ជបញ្ជា ពួកគេត្រូវជំរុញអ្នកជំងឺឱ្យទៅពិគ្រោះជំងឺឡើងវិញ។ ជាមធ្យម អ្នកជំងឺគួរទៅជួបគ្រូពេទ្យម្តង ឬពីរដងក្នុង១ឆ្នាំ។

With prescription we mean that the Medical Doctor, consulted by the patient, writes in the MoPoTsyo self-management book of the patient which medicines must be taken every day and the quantity, and signed and dated by the doctor. With this prescription, the patient can go to one of the pharmacies contracted by MoPoTsyo and get for example 30 days of medication, with a maximum of 3 months. When the medication is finished, the patient can go back to the pharmacy with the same old prescription to pay for a refill. PEs are supposed to monitor if the medication is working adequately or not. If not, PE urged the patient to meet his/her doctor for medical consultation. On average, a patient meets doctor once or twice per year.

តាមរយៈបទពិសោធន៍របស់មិត្តអប់រំមិត្ត អ្នកជំងឺថ្មីនឹងដឹងថា តើវានឹងអស់ថវិកាប៉ុន្មានចំពោះពួកគេជារៀងរាល់ខែលើការចំណាយប្រើថ្នាំ ប្រសិនបើពួកគេទៅពិគ្រោះជាមួយគ្រូពេទ្យនៅមន្ទីរពេទ្យ ដែលបានរៀបចំដោយបណ្តាញមិត្តអប់រំមិត្តរបស់អង្គការ ម.ព.ជ.។

Through the peer educator's experience new patients will get a sense of how much it is going to cost them every month to spend for medication, if they go to consult the Doctor at the Hospital, in a session organized by MoPoTsyo's Peer Educator Network.

អ្នកជំងឺបង់បង្កាន់ដៃភាគទានសម្រាប់ពិគ្រោះជំងឺ ទៅឱ្យក្រុមមិត្តអប់រំមិត្តចំនួន ១២,០០០រៀល សម្រាប់ការពិគ្រោះម្តង។ ថវិកាត្រូវបានចាត់ចែង សម្រាប់ប្រាក់ហិរញ្ញប្បទាននៃមន្ទីរពេទ្យនីមួយៗ ប្រាក់ឧបត្ថម្ភវេជ្ជបណ្ឌិត ប្រាក់លើកទឹកចិត្តមិត្តអប់រំមិត្ត និងសម្ភារសម្រាប់បម្រើការពិគ្រោះជំងឺ។ សម្រាប់ការចំណាយជាក់លាក់របស់អង្គការ ម.ព.ជ. លើការពិគ្រោះនេះ អាចមើលបានតាមការវិភាគបន្ថែម។

The patient contributed 12,000 riels to the consultation team. This is shared as Hospital/Health Center's User Fee, the incentive for the local medical doctor, the incentive for peer team, and the consultation materials. For the detailed cost to MoPoTsyo of these consultations see the analysis further below for more detail.

អ្នកជំងឺ អាចនិយាយជាមួយមិត្តអប់រំមិត្តរបស់ពួកគេ និងអាចប៉ាន់ស្មានបានសមស្រប ថាតើជំងឺរបស់ពួកគេនឹងត្រូវអស់ថ្លៃប៉ុន្មាន។ នៅពេលដែលគេដឹងពីការចំណាយនេះហើយ គឺប្រហែលអាចបង្អាក់សម្រាប់អ្នកខ្លះ (ដូចជាអ្នកជំងឺថ្មី) និងជាការជំរុញអ្នកផ្សេងទៀត។ ក្នុងចំនោមអ្នកជំងឺដែលមិនមានវេជ្ជបញ្ជា មានច្រើនគ្មាណាស់ដែលមិនត្រូវការវេជ្ជបញ្ជា ព្រោះ ពួកគេបានអនុវត្តការផ្លាស់ប្តូររបៀបរស់នៅបានដោយជោគជ័យ។ មានអ្នកខ្លះទៀតដែលគួរតែមានវេជ្ជបញ្ជា ប៉ុន្តែពួកគេមិនចង់បាន ឬពួកគេគ្មានលទ្ធភាពបង់បង្គាន់ដៃភាគទានថ្នាំ ឬក៏ជួបឧបសគ្គផ្សេងទៀត។ ពួកយើងមិនបានដឹងពីឧបសគ្គ និងសមាមាត្រពិតប្រាកដឡើយ។

Patients can talk with their own PE, who can usually give them a fair estimation of what their disease is going to cost them. This knowledge is probably discouraging for some (new patients) and encouraging others. Among those who do not have a prescription, there are many who do not need a prescription, because they are successfully applying lifestyle changes. There are also many who should have a prescription but they do not want to or they are unable to afford the medication or meet other barriers. We do not know the barriers and proportions exactly.

តារាងទី 14៖ ការវិភាគនិន្នាការចំណាយ ២០១២-២០២៥ (តម្លៃបានយក) តាមរយៈវេជ្ជបញ្ជារបស់អ្នកជំងឺទឹកនោមផ្អែម Cost-trend-analysis for prices charged through prescriptions of patients with diabetes

សរុប/ឆ្នាំ **Total / Year**	**និន្នាការ១៤ឆ្នាំនៃតម្លៃវេជ្ជបញ្ជា** **14-year trend in prescription cost**		
ចំនួនវេជ្ជបញ្ជាបានវិភាគ **Nr of prescriptions analyzed**	**តម្លៃប្រចាំខែដែលអ្នកជំងឺទឹកនោមផ្អែមត្រូវចាយសំរាប់ឱសថ (1USD = ៤០០០រ)** **monthly cost to be paid by DM patients for their medication (1USD = 4000 riels)**		
	១៤ ឆ្នាំ/14-years	**មធ្យម/Average**	**មេដ្យាន/Median**
7,818	2012	$6.29	$4.50
9,271	2013	$5.66	$4.69
12,789	2014	$5.75	$4.50
13,793	2015	$5.91	$4.78
17,051	2016	$6.23	$5.06
18,216	2017	$6.55	$5.44
23,274	2018	$6.63	$5.63
30,026	2019	$6.20	$5.06
36,746	2020	$6.11	$5.15
32,324	2021	$5.79	$4.88
45,012	2022	$6.20	$5.25
56,747	2023	$8.23	$6.92
49,330	2024	$7.16	$6.14
48,748	2025	$6.56	$5.80

កម្រិតមធ្យមការចំណាយនៃ "វេជ្ជបញ្ជាដំបូង" ផ្តល់ទៅឱ្យអ្នកជំងឺទឹកនោមផ្អែមម្នាក់ក្នុងឆ្នាំបានផ្តល់ឱ្យ គឺជាក់ច្បាស់ណាស់ ទាបជាងកម្រិតការចំណាយជាមធ្យមសម្រាប់វេជ្ជបញ្ជាទាំងអស់ក្នុងឆ្នាំនោះ ពីព្រោះវេជ្ជបញ្ជាបន្ទាប់សម្រាប់អ្នកជំងឺដដែលតែងតែបន្ថែមនូវថ្នាំ ដូចអាចបានឃើញក្នុងតារាងខាងលើ។

The average level of cost of the “first prescription” given to a DM patient in a given year is of course lower than the average cost-level of all prescriptions given in that year, because later prescriptions for the same patients almost always add medication as can be seen.

ក្នុងឆ្នាំ២០២៥ ការចំណាយជាមធ្យមប្រចាំខែ និងតម្លៃមេដ្យានៃការចំណាយ គឺបានបន្តថយចុះវិញ បើធៀបនឹងឆ្នាំ ២០២៣-២០២៤កន្លងទៅ ដោយមូលហេតុចម្បងគឺការបញ្ចុះតម្លៃថ្មីរបស់មូលនិធិឱសថបង្វិលទុនមកវិញ នៅថ្ងៃទី០១ ខែសីហា ឆ្នាំ២០២៤។

In 2025, the average monthly cost of prescriptions and the median of expenditure have much decreased compared to last two years. The main reason was reduction the medicines price issued by 01 August 2024 onward.

នៅក្នុងឆ្នាំ២០២៥នេះ តម្លៃឱសថជាមធ្យមនៅក្នុងមួយវេជ្ជបញ្ជារបស់អ្នកជំងឺទឹកនោមផ្អែម គឺ ៨៧៥រៀល/ថ្ងៃ ឬប្រមាណ ២៦២៥៥រៀលក្នុងមួយខែ។ ប៉ុន្តែគម្លាតតម្លៃពីវេជ្ជបញ្ជាមួយទៅវេជ្ជបញ្ជាមួយ គឺធំ (ដូចបង្ហាញក្នុងតារាង ដែលបានបង្ហាញពីការចំណាយលើឱសថជាប្រចាំថ្ងៃ)។ ការចំណាយវាអាស្រ័យផងដែរលើតម្រូវការឱសថសម្រាប់ថែទាំសុខភាព និងលទ្ធភាពចំណាយរបស់សមាជិក។

The average cost of medicines that these doctors prescribed in 2025 for the DM patients is about 875 riels per day, which comes down to 26,255 Riels per month, but the variation is wide. The cost depends on whether the patient needs a lot of medicines and whether they can afford it.

វេជ្ជបណ្ឌិតពិគ្រោះជំងឺមិនធ្លាប់ទទួលបានការលើកទឹកចិត្តឱ្យចេញឱសថតិច ឬច្រើនឡើយ ដោយពួកគេមានអព្យាក្រឹតក្នុងការបំពេញតួនាទីតាមវិជ្ជាជីវៈរបស់ពួកគេ។ អ្នកជំងឺអាចស្នើបង់បង្កាន់ដៃថ្នាំសម្រាប់៣០ថ្ងៃ ឬលើសពី៣០ថ្ងៃ។

The doctors do not experience an incentive to prescribe a lot or a little. They can do their job professionally without financial pressure. Patients can decide to buy less than 30 days or more than 30 days of medication.

រូបភាពទី21៖ តម្លៃចំណាយលើឱសថប្រចាំខែតាមវេជ្ជបញ្ជា (រៀល) Total in Monthly prescription cost (KHR)



នៅពេលយើងធ្វើការវិភាគថ្លៃចំណាយឱសថ តាមវេជ្ជបញ្ជាសម្រាប់អ្នកជំងឺទឹកនោមផ្អែមថ្មីសម្រាប់១ខែ នៅពេលអ្នកជំងឺពិគ្រោះគ្រូពេទ្យនៅលើកដំបូង ក្នុងរយៈពេល១ឆ្នាំ ហើយយើងប្រៀបធៀប តើថាប្រភេទការចំណាយវិវត្តន៍១៤ឆ្នាំកន្លងមក យើងនឹងបានតារាងដូចខាងក្រោម។ ថ្លៃចំណាយសម្រាប់វេជ្ជបញ្ជាដំបូងគឺមិនប្រែប្រួលខ្លាំងទេ លើកលែងតែឆ្នាំ២០២៣ ដែលឱសថនៃមូលនិធិឱសថបង្វិលទុនត្រូវបានតម្លើងថ្លៃ។ ចាប់ពីខែសីហា ឆ្នាំ២០២៤ ថ្លៃចំណាយរបស់អ្នកជំងឺទឹកនោមផ្អែមលើឱសថពេលជួបពេទ្យលើកដំបូង គឺបានធ្លាក់ទាបវិញ បន្ទាប់ពីការបញ្ចុះតម្លៃភាគទានឱសថ។

When we analyse the cost of prescribed medication for a NEW diabetes patient, for one month, when this patient consults the Doctor for the first time within the year and we compare how that type of cost has evolved over the past 14 years then we get the following table. The cost of 1st prescription stays more or less the same for several years except in 2023 when price of RDF's medicines were changed for first time. However, in 2024, the prices were reduced. Thus the cost of 1st prescription became cheaper.

តារាងទី 15៖ តម្លៃថ្នាំតាមវេជ្ជបញ្ជាដំបូងរបស់អ្នកជំងឺទឹកនោមផ្អែម Monthly expense for 1st prescription of the DM patients

ចំនួនវេជ្ជបញ្ជាទី១ Nr of 1st Prescription	ឆ្នាំ Year	តម្លៃប្រចាំថ្ងៃ (រៀល) DM daily cost (KHR)	តម្លៃប្រចាំខែ (រៀល) DM monthly cost (KHR)
2,069	2012	487 ៛	14,610 ៛
4,335	2013	640 ៛	19,200 ៛
2,645	2014	460 ៛	13,800 ៛
2,050	2015	717 ៛	21,510 ៛
1,035	2016	537 ៛	16,110 ៛
981	2017	524 ៛	15,720 ៛
2,899	2018	534 ៛	16,020 ៛
3,651	2019	526 ៛	15,781 ៛
4,248	2020	522 ៛	15,661 ៛
3,717	2021	521 ៛	15,644 ៛
5,858	2022	626 ៛	18,781 ៛
5,756	2023	829 ៛	24,883 ៛
4,156	2024	684 ៛	20,542 ៛
3,531	2025	594 ៛	17,841 ៛

ថ្លៃចំណាយសម្រាប់វេជ្ជបញ្ជាដំបូង របស់អ្នកជំងឺទឹកនោមផ្អែម គឺបានកើនឡើង ខ្ពស់បំផុតមិនធ្លាប់មាននៅក្នុងឆ្នាំ ២០២៣ ដោយសារតែអង្គការម.ព.ជ.បានសម្រេចដាក់ថ្លៃថ្មីនៃឱសថរបស់មូលនិធិបង្វិលទុនកាលពីថ្ងៃទី១ មករា ឆ្នាំ ២០២៣ ដើម្បីទប់ទល់នឹងការចំណាយថ្លៃដើមខ្ពស់បណ្តាលមកពីការផ្លាស់ប្តូរការវេចខ្ចប់ឱសថពី១០០០គ្រាប់ក្នុង១កំប៉ុងទៅជា១០០គ្រាប់ក្នុង១កំប៉ុង។ ប៉ុន្តែ ចាប់តាំងពីតម្លៃថ្នាំបានកែប្រែបញ្ចុះមកវិញចាប់ពីខែសីហា ២០២៤ ដោយតែការអង្គការបានសម្រេចផ្លាស់ប្តូការវេចខ្ចប់ទៅជា១០០គ្រាប់ក្នុង១កំប៉ុងវិញរហូតមកដល់ដំណាច់ឆ្នាំ២០២៥នេះ គឺនាំឱ្យថ្លៃចំណាយសម្រាប់វេជ្ជបញ្ជាដំបូងប្រចាំខែ បានបន្តធ្លាក់ចុះពី២០៥៤២ រៀល/ខែ នៅក្នុងឆ្នាំ២០២៤ មកនៅត្រឹម១៧៨៤១រៀល/ខែ នៅក្នុងឆ្នាំ២០២៥។

The cost of 1st prescription was highly increased as first time in the history because MoPoTsyo introduced the new prices nationwide on 1 January 2023 in order to cover the higher cost of the medicines, which had been caused by changing the packaging from 1000 tabletes to 100 tablets per pot. But the price of the RDF's medicines has been reduced from August 2024 onwards because the packaging changed reversely from 100 tablets to 1000 tablets per pot. This decreased the monthy cost of the 1st prescription from 20,542 riels in 2024 to 17,841 riels for Diabetics care in 2025.

តារាងទី 16៖ % តាមឆ្នាំនៃការប្រើប្រាស់សេវាពិគ្រោះជំងឺ របស់អ្នកជំងឺទឹកនោមផ្អែមថ្មី Yearly% of new DM patients accessing the medical consultation

ឆ្នាំ Year	ចំនួនវេជ្ជបញ្ជាទី១ nr of 1st prescription	ភាគរយវេជ្ជបញ្ជាទី១ % of 1st prescription	សរុបចំនួនវេជ្ជបញ្ជា total prescriptions
2012	2,069	20%	10,408
2013	4,335	47%	9,271
2014	2,645	21%	12,789
2015	2,050	15%	13,793
2016	3,235	15%	20,927
2017	2,883	13%	21,679
2018	2,899	12%	23,274
2019	3,651	12%	30,026
2020	4,248	12%	36,746
2021	3,717	11%	32,324
2022	5,858	13%	45,012
2023	5,756	10%	56,747
2024	4,156	7%	55,633
2025	3,531	6%	55,033

តារាងទី 17៖ ការប្រៀបធៀបតម្លៃថ្នាំតាមវេជ្ជបញ្ជាសម្រាប់អ្នកជំងឺទឹកនោមផ្អែម និងអ្នកជំងឺលើសសម្ពាធឈាមក្នុងឆ្នាំ២០២៥ Comparing cost of medication in prescription between DMs and HBPs in 2025

តម្លៃថ្នាំតាមវេជ្ជបញ្ជាគួរត្រូវចំណាយដោយអ្នកជំងឺ **Cost of Prescribed Medication should be paid by Patients**		
អ្នកជំងឺទឹកនោមផ្អែម DM patients	គួរចំណាយក្នុង១ថ្ងៃជារៀល KHR/day	875 ៛
អ្នកជំងឺទឹកនោមផ្អែម DM patients	គួរចំណាយក្នុងមួយខែជារៀល KHR/Month	26,255 ៛
អ្នកជំងឺទឹកនោមផ្អែម DM patients	គួរចំណាយក្នុងមួយខែជាដុល្លារ USD/Month	$6.56
អ្នកជំងឺលើសសម្ពាធឈាម HBP patients	គួរចំណាយក្នុង១ថ្ងៃជារៀល KHR/day	481៛
អ្នកជំងឺលើសសម្ពាធឈាម HBP patients	គួរចំណាយក្នុងមួយខែជារៀល KHR/Month	14,442 ៛
អ្នកជំងឺលើសសម្ពាធឈាម HBP patients	គួរចំណាយក្នុងមួយខែជាដុល្លារ USD/Month	$3.61

ឱសថបង្វិលទុន និង ការអនុវត្តតាមវេជ្ជបញ្ជា REVOLVING DRUG FUND AND ADHERENCE TO PRESCRIPTION

ឱសថបង្វិលទុន៖ ជាធម្មតាកំឡុងត្រីមាសទី៤នៃឆ្នាំ យើងបានធ្វើកម្មវិធីប្រគល់ប្រាក់លើកទឹកចិត្ត ជូនដៃគូសុខាភិបាលសាធារណៈ ដែលបានចែកចាយឱសថសម្រាប់សមាជិករបស់បណ្តាញមិត្តអប់រំមិត្ត ដោយផ្អែកលើបរិមាណទឹកប្រាក់ជាក់ស្តែងដែលឱសថស្ថាននីមួយៗ បានចែកចាយឱ្យសមាជិក និងការពេញចិត្តរបស់អ្នកជំងឺ (កម្រងសំនួរស្តង់ដារដើម្បីស្រង់មតិលើការប្រើសេវាឱសថបង្វិលទុន) និងការអនុវត្តតាមវេជ្ជបញ្ជារបស់អ្នកជំងឺក្នុងរយៈពេល ១២ខែចុងក្រោយ។ ដើម្បីគណនាប្រាក់លើកទឹកចិត្តបាន ទិន្នន័យទាំងអស់ ត្រូវបានយកចេញពីប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់យើង ដែលមានឈ្មោះថា PMS (Patients Management System) ។ របៀបនៃការគណនាបែបនេះ ត្រូវបានអនុវត្តន៍នូវគ្រប់ស្រុកប្រតិបត្តិទាំងអស់ ហើយវាក៏មានការទទួលស្គាល់ផងដែរ។

កម្មវិធីឱសថបង្វិលទុន បានចាប់ផ្តើមដំណើរការតាំងពីឆ្នាំ២០០៥ មកម្លេះ ប៉ុន្តែប្រព័ន្ធផ្តល់ប្រាក់លើកទឹកចិត្តទើបតែចាប់ផ្តើមមាននៅឆ្នាំ២០១២តែប៉ុណ្ណោះ គឺនៅពេលដែលអង្គការ ម.ព.ជ. បានទទួលការអនុញ្ញាតិពីក្រសួងសុខភិបាលអោយពង្រីកសេវារបស់ខ្លួនក្នុងសេវាសាធារណៈ ហើយវាកាន់តែប្រសើរឡើងៗ។ សូចនាករទាំងអស់ បានបង្ហាញពីនិន្នាការកើនឡើងនៅគ្រប់ស្រុកប្រតិបត្តិទាំងអស់ វាក៏បង្ហាញឱ្យឃើញផងដែរនូវនិរន្តរភាពនៃផ្នែកហិរញ្ញវត្ថុ។ អ្នកជំងឺភាគច្រើនដែលមិនទាន់ប្រើប្រាស់អាំងស៊ុយលីន បានរួមចំណែកបដិភាគពីមុខឱសថដទៃ (cross-subsidize) លើការចំណាយសម្រាប់ដំណើរការផ្គត់ផ្គង់អាំងស៊ុយលីនដល់អ្នកជំងឺ ១៧០២ នាក់ នៅក្នុងឆ្នាំ២០២៥។ យើងកំពុងតែផ្គត់ផ្គង់អាំងស៊ុយលីន និងស៊ីរ៉ាំងអាំងស៊ុយលីន។ ការចែកចាយអាំងស៊ុយលីនតែមួយមុខ គឺវាមិនមាននិរន្តរភាពនោះទេ ប៉ុន្តែដោយសារការបញ្ចូលប្រភេទឱសថអាំងស៊ុយលីន ក្នុងបញ្ជីផ្គត់ផ្គង់ឱសថផ្សេងៗទៀត ទើបធ្វើឱ្យដំណើរការកញ្ចប់ឱសថទឹកនោមផ្អែមជារួម គឺអាចដំណើរការបានប្រកបដោយនិរន្តរភាព។ បដិភាគពីមុខ ឱសថដទៃ (cross-subsidize) គួរតែត្រូវកែសម្រួល ដើម្បីឱ្យអ្នកជំងឺទឹកនោមផ្អែមប្រភេទ២ ដែលនឹងត្រូវប្តូរមកប្រើប្រាស់អាំងស៊ុយលីននៅពេលក្រោយ ទទួលបានប្រយោជន៍ពីប្រព័ន្ធផ្គត់ផ្គង់ឱសថដែលពួកគេបានផ្តល់ហិរញ្ញប្បទានច្រើនឆ្នាំហើយ។

Revolving Drug Fund: As usual, during Quarter 4th, we handed out the Revolving Drug Fund Pharmacy income sharing to our counterparts in the public health operational districts which are cooperating to dispense our RDF medicines to our membered patients. The income sharing is based on the volumes sold in each health facility. The result of the survey on satisfaction (annual standard surveys held to get feedback from users) and the adherence to prescribed treatment over the past 12 months is calculated from the data in our database. The progress in all ODs is over many years is really striking.

This RDF has been running since 2005, but the “income sharing system” only since 2012 when we received MoH gave permission to expand into the public services, and it is getting better and better: all indicators show upward trends in all operational districts, and it is financially sustainable. The great majority of non-insulin using patients are cross subsidizing the insulin distribution logistics, keeping 1702 insulin users continuously supplied with insulin and insulin syringes in 2025. The insulin distribution by itself would not be financially sustainable, but because it is embedded into a more comprehensive drug distribution system it benefits from its infrastructure. The cross-subsidy is justified because many type 2 diabetes patients will themselves become insulin users later and will then benefit from a logistics system that they have financed for many years.

បរិមាណនៃការប្រើឱសថនៃមូលនិធិបង្វិលទុន៖ ឆ្នាំ២០២៥ មានអ្នកជំងឺចំនួន ២០.៤៨២នាក់ បានប្រើប្រាស់ឱសថនៃមូលនិធិបង្វិលទុនស្មើនឹង ១១១.៣៣៤បង្កាន់ដៃ បានកត់ត្រា។ ទំហំភាគទាន មានតម្លៃជាង៣.៣៣១លានរៀល ក្នុងនោះមានទឹកប្រាក់ប្រមាណជិត ៣៥០លានរៀលជាពន្ធលើតម្លៃបន្ថែម(VAT១០%) ដែលអង្គការបានកាត់ទុកសម្រាប់បង់ពន្ធ។ បើយើងប្រៀបធៀបការចំណាយប្រចាំខែជាមធ្យមតាមរយៈ វេជ្ជបញ្ជារបស់អ្នកជំងឺចំនួន ១៤៣៩២នាក់ (វេជ្ជបញ្ជាចុងក្រោយមុនឆ្នាំ២០២០ មិនត្រូវបានរាប់បញ្ចូលឡើយ) យើងឃើញថា អ្នកជំងឺម្នាក់បានចំណាយថវិកាក្នុងតម្លៃជាមធ្យមប្រហែល៧,៦ខែ ក្នុងរយៈពេល១២ខែនៃឆ្នាំ ២០២៥។ អ្នកខ្លះ បង់ភាគទាន សម្រាប់ប្រើកន្លះខែ និងអ្នកផ្សេងទៀតបង់សម្រាប់ ២ខែ ឬឡើងដល់ ៣ខែ។ អ្នកជំងឺ អាចសន្សំថ្លៃចំណាយធ្វើដំណើរ និងពេលវេលា ប្រសិនបើពួកគេមិនមកប្រើសេវាញឹកញាប់។ "ប្រព័ន្ធបង់សម្រាប់ប្រើកញ្ចប់សេវាផ្អែក លើការកំណត់ហិរញ្ញប្បទានរបស់មន្ទីរពេទ្យ" ដែលតម្រូវឱ្យ អ្នកជំងឺធ្វើដំណើរញឹកញាប់ នៅតែជាឧបសគ្គសម្រាប់ការទៅ ទទួលសេវាក្នុងចំណោមអ្នកជំងឺរ៉ៃពុំមិនឆ្លង ដែលត្រូវការ ព្យាបាលជាប់បន្តពេញមួយជីវិត។ ដូចនេះហើយ ការគណនាការអនុវត្តតាមវេជ្ជបញ្ជា គឺជាការសំខាន់។ តម្លៃថ្នាំប្រចាំថ្ងៃសម្រាប់ពេញឆ្នាំ អាស្រ័យលើថាតើអ្នកជំងឺទៅប្រើសេវាថ្នាំរបស់គាត់ប៉ុន្មានដង។ នេះគឺមានការរីកចម្រើន ពួកយើងអាចរកឃើញក្នុងតារាងនូវឆ្នាំដំបូង ប្រជាជនមិនបានបង់សេវាថ្នាំគ្រប់គ្រាន់ទេ។ អ្នកជំងឺលើសសម្ពាធឈាមនៅទៅទទួលសេវាថ្នាំ មិនទាន់គ្រប់គ្រាន់ដដែល។

Frequency of RDF Consumption: In 2025, 20,482 patients did spend 111,334 times. It cost them around 3,331 million riels including almost 350 million riels VAT (10%) that we had to charge and withhold to pay to the Tax Department. If we compare to the average expense per patient per month based on the value of medicine prescribed by their doctors in the same year (last prescriptions before 2020 were excluded), it tells the average worth of spending 7.6 months per patient in the year 2025. Some patients contributed for half a month and others contributed for 2 months or even 3 months. Patients can save transportation cost and time if they come less often. In principle, there is financial conflict of interest between the current Hospital "user fee system" and the interest of the patient to economize the frequency of travel because the chronic patients need the medication for the rest of their life. That is why the "adherence" indicator is important. The cost of the routine medication on annual basis depends on how often the patient goes to get his/her medicine. This has been improving, as we can see in the table as in the early years people did not use sufficient medication. Hypertension patients are still not using enough.

តារាងទី 18. តម្លៃនៃការប្រើសេវាឱសថនៃមូលនិធិឱសថបង្វិលទុន ជាមធ្យមប្រចាំឆ្នាំសម្រាប់អ្នកជំងឺម្នាក់ ***Annual average worth of using RDF medicines per patient***

ប្រភេទជំងឺ	ចំនួនករណី Nr of Case	តម្លៃចំណាយប្រចាំខែតាមរយៈវេជ្ជបញ្ជា Amount of should spent per month	តម្លៃចំណាយប្រចាំឆ្នាំលើឱសថ Amount of consumption/year	តម្លៃមធ្យមនៃការប្រើប្រចាំឆ្នាំ២០២៥ គិតជាខែ/អ្នកជំងឺម្នាក់ Annual Frequency of consumption/patient in 2025
ជំងឺទឹកនោមផ្អែម Patients with D&DH	12,598	30,046 ៛	2,979,452,590 ៛	7.9
ជំងឺលើសសម្ពាធឈាម Patient with HBP only	1,794	15,903 ៛	211,835,835 ៛	7.4
សរុប	**14,392**		**3,191,288,425 ៛**	7.6

ការអនុវត្តតាមវេជ្ជបញ្ជាក្នុងការប្រើថ្នាំ របស់អ្នកជំងឺទឹកនោមផ្អែម និងអ្នកជំងឺលើសសម្ពាធឈាមរបស់បណ្តាញមិត្តអប់រំមិត្ត ត្រូវបានពិនិត្យមើលជាទៀងទាត់ និងរៀងរាល់ឆ្នាំ ដើម្បីស្វែងយល់អំពីបម្រែបម្រួលនៃឥរិយាបថប្រើថ្នាំ កំណើននៃការប្រើសេវាឱសថ និងជាមធ្យោបាយប្រមើលមើលសម្រាប់ផែនការផ្គត់ផ្គង់ នាឆ្នាំបន្ទាប់ផងដែរ។

Trends in annual adherence to prescribed routine medication by diabetics and hypertentives are being monitored by MoPoTsyo through its database in order to understand changing attitude towards medication, increase in utilisation of pharmacy service and to plan for future consumption.

តារាងទី 19៖ ការចំណាយមធ្យមប្រចាំឆ្នាំលើឱសថ *Average Annual expenditure on routine medication of patient*

Amounts spent in riels by type of individually registered Patient for their medicaton at the contracted pharmacies					
Year	D	DH	H	Unknown	Average
2008	21,451	21,171	6,500	-	16,374
2009	66,186	48,434	9,245	-	41,288
2010	77,128	65,215	17,313	19,175	59,610
2011	111,944	113,620	7,138	81,250	104,651
2012	101,299	124,248	22,659	56,333	101,513
2013	127,109	163,246	64,877	-	118,411
2014	248,760	299,520	138,960	395,280	360,840
2015	109,153	135,549	54,596	76,300	125,199
2016	121,413	144,097	61,911	-	109,140
2017	134,834	160,923	70,556	-	122,104
2018	147,975	181,565	85,149	-	138,230
2019	129,594	208,552	84,474	-	140,873
2020	127,169	217,282	85,230	-	143,227
2021	154,496	179,402	87,964	-	140,620
2022	169,278	196,109	96,658	-	154,015
2023	225,770	253,017	126,467	-	201,751
2024	202,166	224,707	106,747	-	198,771
2025	212,992	231,321	111,376	-	207,477

តាមជួរឈរនៃតារាងខាងលើ "តម្លៃមធ្យម" បង្ហាញអំពីការបង់សេវាជាមធ្យម ដែលអ្នកជំងឺបានបង់ភាគទានសេវាក្នុងរយៈពេល១ឆ្នាំពេញ សម្រាប់ឱសថដែលពួកគេបានទទួលទៅប្រើ។ ដោយឡែក សមាជិកដែលបានចុះឈ្មោះតែមិនបានបង់ភាគទានសេវាថ្នាំ គឺមិនបានគិតបញ្ចូលនៅក្នុងការគណនានេះឡើយ។ តាំងឆ្នាំ២០២៤ តម្លៃមធ្យមបានធ្លាក់ចុះវិញ ដោយសារតែការបញ្ចុះភាគទានសេវាឱសថនាថ្ងៃទី ០១ សីហា ២០២៤ ប៉ុន្តែតម្លៃមធ្យមនេះ វាបានកើនឡើងវិញបន្តិចនៅក្នុងឆ្នាំ២០២៥។ ការផ្លាស់ប្តូរពីកំប៉ុង១០០គ្រាប់ ទៅកំប៉ុង១០០០គ្រាប់វិញ បានធ្វើឱ្យថ្លៃដើមទាបជាមុន ជាហេតុដែលធ្វើឱ្យយើងអាចទម្លាក់ថ្លៃភាគទានសេវាឱសថវិញបាន។

The above column “average” shows what the average registered chronic patient spent in total during the whole year for all his/her medicines. Patients who are registered but did not spend on any medicine during the year are not taken into account. The average trend is relatively declined for all type of diseases due to the deduction of the price for membership since 01 August 2024 onward; however, this average expenses have slightly raised in 2025. The changing from 100 tablets per bottle to 1000 tablets per bottle has affect the cost much lower; thus we could reduce the price of most of the tablets.

ចាប់តាំងពីចាប់ផ្តើមកម្មវិធីមក ភាគទានថ្នាំនៃមូលនិធិឱសថបង្វិលទុនរបស់អង្គការ ម.ព.ជ. បានប្រែប្រួល២លើករួចមកហើយ។

The prices of Revolving Drug Fund have twice changed since the starting time.

ដើម្បីគណនាការអនុវត្តតាមវេជ្ជបញ្ជា យើងត្រូវមើលទៅលើថ្ងៃពិគ្រោះជំងឺ បន្ទាប់មកត្រូវធ្វើការគណនាចំនួនថ្ងៃគិតរហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥។ យើងយកចំនួនថ្ងៃនេះទៅគុណនឹងថ្លៃថ្នាំបច្ចុប្បន្នប្រចាំថ្ងៃរបស់អ្នកជំងឺម្នាក់ៗ។ យើងធ្វើបែបនេះគ្រប់អ្នកជំងឺទាំងអស់ហើយបូកបញ្ចូលគ្នា។

To calculate adherence, we look at the date of the medical consultation and then calculate the number of days until 31 December 2025. We do this for all patients with a prescription and sum up for the total for all cases together.

យើងយកទំហំថវិកា ដែលអ្នកជំងឺចំណាយជាក់ស្តែងផ្អែកតាមថ្លៃថ្នាំបច្ចុប្បន្ន ចែកនឹងទំហំដែលអ្នកជំងឺគួរចំណាយក្នុងមួយឆ្នាំ តាមរយៈវេជ្ជបញ្ជាពួកគេក្នុងឆ្នាំ២០២៥។ យើងបានបញ្ចូលបង្កាន់ដៃបង់ភាគទាន ដែលមិនអាចបញ្ចូលក្នុងប្រព័ន្ធទិន្នន័យ ទៅក្នុងការគណនាផងដែរ។ យើងប្រើតម្លៃថ្មីដែលបានកែប្រែក្នុងខែសីហា ២០២៤ ដើម្បីធ្វើការគណនារកទំហំថវិកាដែលពួកគេគួរតែចាយក្នុងឆ្នាំ២០២៥។

We divide what patients have bought by what they should have bought according to their prescriptions in 2025. We also included dispensing receipts were not in entered in the database. We applied new price from August 2024 for the whole years of the amoung they should spent in the year of 2025.

យើងធ្វើការវិភាគដាច់ដោយឡែក ក្នុងចំណោមសមាជិកបណ្តាញមិត្តអប់រំមិត្តតាមប្រភេទនៃជំងឺ គឺអ្នកជំងឺទឹកនោមផ្អែម និងអ្នកជំងឺលើសសម្ពាធឈាមដែលគ្មានទឹកនោមផ្អែម។ ប្រភេទជំងឺនេះ យើងបែងចែកផ្អែកតាមមុខថ្នាំជាក់ស្តែងក្នុងបង្កាន់ដៃនិងក្នុងវេជ្ជបញ្ជាចុងក្រោយ។ តារាងខាងក្រោម បង្ហាញអំពីការអនុវត្តតាមវេជ្ជបញ្ជារបស់អ្នកជំងឺទឹកនោមផ្អែម នៅក្នុងឆ្នាំ២០២៥ ដែលមានវេជ្ជបញ្ជាចុងក្រោយមិនលើសពី៥ឆ្នាំ។ យើងឃើញថា អ្នកជំងឺទាំងអស់គួរតែចំណាយលើថ្នាំអស់ប្រមាណ 4,105,989,866រៀល ក្នុងឆ្នាំ ២០២៥។ ប៉ុន្តែជាក់ស្តែងអ្នកជំងឺបានចំណាយលើថ្នាំត្រឹមតែ 2,998,372,415រៀល ប៉ុណ្ណោះ។បើប្រៀបធៀបទិន្នន័យក្នុងឆ្នាំ ២០២៤ យើងសង្កេតឃើញថា អត្រានៃការអនុវត្តតាមវេជ្ជបញ្ជារបស់អ្នកជំងឺទឹកនោមផ្អែម បានប្រែប្រួលពី ៦៥% ទៅដល់ ៧៣% នៅក្នុងឆ្នាំ២០២៥។ អាចមានមូលហេតុផ្សេងៗដែលប៉ះពាល់ដល់អត្រានៃការអនុវត្តតាមវេជ្ជបញ្ជា ដូចជារយៈពេលវែងនៃវេជ្ជបញ្ជាចុងក្រោយ មរណភាព បង្កាន់ដៃមិនបានកត់ត្រាគ្រប់ចំនួន និងការកែប្រែតម្លៃនៃឱសថជាដើម។

We analysed separately for patients with diabetes and the patient with non-diabetic hypertensives. The types of the patients separated based on the actual medicines prescribed and the tablets in their receipts. The table below shows adherence of diabetic patients in 2025 among those diabetic whose their last prescription no long than 5 years. We see that all patients with diabetes should spend 4,105,989,866 riels ($1,026,497.47) of medicine in 2025. But in reality, the patients only spent 2,998,372,415 riels ($749,593.10). These figures resulted the adherence rate among patients with diabetes has increased from 65% in 2024 to 73% in 2025. There were various reasons such as the long life of last prescriptions, patients had died, lost of receipts, and the sale price changed.

តារាងទី 20៖ ការអនុវត្តតាមវេជ្ជបញ្ជានៃអ្នកទឹកនោមផ្អែមឆ្នាំ២០២៥ Adherence to prescription of DM patients in 2025

Year 2025	DM should spend	4,105,989,866 ៛
	If 1 USD = 4000 KHR	$1,026,497.47
	DM did spend	2,998,372,415 ៛
	If 1 USD = 4000 KHR	$749,593.10
	Adherence to Medications	73.0%

ដោយឡែកអ្នកជំងឺលើសសម្ពាធឈាម ដែលបាននឹងកំពុងប្រើសេវាឱសថបង្ខិលទុន ក៏ត្រូវបានវិភាគមើលអំពីការអនុវត្តន៍វេជ្ជបញ្ជារបស់ពួកគេផងដែរ។ តារាងខាងក្រោមនេះបង្ហាញអំពី ការអនុវត្តតាមវេជ្ជបញ្ជារបស់សមាជិកជាអ្នកជំងឺលើសសម្ពាធឈាមជាមួយអត្រា៧១% នៅក្នុងឆ្នាំ២០២៥។ ប្រៀបធៀបនឹងតួរលេខក្នុងឆ្នាំកន្លងទៅ យើងឃើញថា អត្រានៃការអនុវត្តការប្រើថ្នាំរបស់អ្នកជំងឺលើសសម្ពាធឈាម បានកើនឡើងពី ៦២%នៅឆ្នាំ២០២៤។ ចំនួនអ្នកជំងឺលើសសម្ពាធឈាមដែលបន្តប្រើប្រាស់សេវាក្នុងឆ្នាំ២០២៥ បានបន្តធ្លាក់ចុះគួរឱ្យកត់សម្គាល់ដូចបានបង្ហាញខាងដើមៗស្រាប់។

The adherence by hypertensive who are using RDF service has also been analysed. The table below showed the adherence of the patients with HBP was 71% in 2025. Compared with the rate in last year, we see that the rate at which HBP patients paid for medicine has increased from 62% in 2024. As showed in previous chapter, the number of patients with HBP has decreased notably in 2025.

តារាងទី21៖ ការអនុវត្តតាមវេជ្ជបញ្ជានៃជំងឺលើសសម្ពាធឈាមឆ្នាំ២០២៥ Adherence to prescription of HBP patients in 2025

Year 2025	HBP should spend	301,180,326 ៛
	If 1 USD = 4000 KHR	$75,295.08
	HBP did spend	215,020,735 ៛
	If 1 USD = 4000 KHR	$53,755.18
	Adherence to Medications	71.4%

ការចែកចាយ និងផ្គត់ផ្គង់ឱសថដល់ឱសថស្ថាន RDF DRUG DISPENSES AND SUPPLIES TO THE PHARMACIES

នៅក្នុងឆ្នាំ២០២៥ អង្គការ ម.ព.ជ. បានបន្តចុះកិច្ចសន្យាជាមួយឱសថស្ថានឯកជនចំនួន ១ទីតាំង និងឱសថស្ថានរដ្ឋចំនួន៣៧ទីតាំង គិតរួមទាំងមន្ទីរពេទ្យបង្អែកឆ្លងដែលបានបញ្ចប់កិច្ចសន្យាត្រឹមខែឧសភា ២០២៥។ យើងមិនមានរៀបចំកម្មវិធីមូលនិធិឱសថសម្រាប់ទីតាំងថ្មីឡើយ។ យើងក៏បានធ្វើការផ្គត់ផ្គង់ឱសថ (ដោយរួមបញ្ចូលអាំងស៊ុយលីន)ទៅកាន់ឱសថស្ថានដៃគូទាំងនោះ។ ដូចនេះ ពួកគេអាចចែកចាយឱសថទៅឱ្យអ្នកជំងឺ ដែលជាសមាជិករបស់អង្គការ ម.ព.ជ. បានយ៉ាងគ្រប់គ្រាន់។ ចំណែកការបង្វិលទុនមកវិញនៅក្នុងឆ្នាំ២០២៥ បានបង្ហាញនូវសញ្ញាកាន់តែល្អប្រសើរ។

Per 31-12-2025, MoPoTsyo has contracts with 1 private pharmacy and 37 public pharmacies, this including the contract with RH Chhlong which was ended by May 2025. During the year, there was no new location contracted. We supplied medicines (including insulin) to our contracted pharmacies, so they can dispense it to patients who are MoPoTsyo's members. Our turn-over in 2025 hardly decreased compared with 2024.

តារាងទី 22៖ ការចែកចាយនិងទំហំទឹកប្រាក់មូលនិធិនៅតាមឱសថស្ថាន Dispenses and Amount of Fund to pharmacies

RDF Volume Purchased by contracted pharmacies and Paid to MoPoTsyo and Outstanding Credit													
		Baseline 100	-66%	-58%	-49%	-40%	-29%	-26%	-20%	33%	-13%	-15%	
		2007-2015	2016	2017	2018	2019	2020	2021	2022	2023	2024	2025	Grand Total
Sold to pharmacy	Riel	4,566,808,899	1,572,157,290	1,926,529,434	2,348,328,017	2,762,788,000	3,260,847,820	3,375,757,333	3,641,565,815	6,088,182,455	3,963,093,251	3,887,377,103	
	US$	1,141,702	393,039	481,632	587,082	690,697	815,212	843,939	910,391	1,522,046	990,773	971,844	9,348,359
Pharmacy Paid to MoPoTsyo	Riel	3,799,009,846	1,622,126,060	1,932,958,800	2,294,199,619	2,594,388,281	3,117,246,220	3,480,698,463	4,069,483,319	5,392,970,579	4,542,315,265	4,178,377,667	
	US$	949,752	405,532	483,240	573,550	648,597	779,312	870,175	1,017,371	1,348,243	1,135,579	1,044,594	9,255,944
Patients Paid to Pharmacies	Riel	4,007,495,810	1,318,299,780	1,628,288,530	2,062,697,835	2,337,572,500	3,040,800,451	3,063,373,500	3,778,632,825	5,479,275,309	4,336,785,433	4,249,540,760	
	US$	1,001,874	329,575	407,072	515,674	584,393	760,200	765,843	944,658	1,369,819	1,084,196	1,062,385	8,825,691
										Out Standing Credit			$ 92,415
Do pharmacies pay on time…level of outstanding credit													
		2007-2015	2016	2017	2018	2019	2020	2021	2022	2023	2024	2025	Total
paid by pharmacies		83%	103%	100%	98%	94%	96%	103%	112%	89%	115%	107%	
credit to pharmacies		17%	-3%	0%	2%	6%	4%	-3%	-12%	11%	-15%	-7%	1%
patients bought		88%	84%	85%	88%	85%	93%	91%	104%	90%	109%	109%	

រូបភាពទី22៖ ការផ្គត់ផ្គង់ថ្នាំទៅឲ្យឱសថស្ថាន និងភាគទានត្រូវបង់ត្រឡប់ RDF's drugs supply & Revolved Fund



រូបភាពខាងលើនេះ បង្ហាញអំពីចំនួនទឹកប្រាក់គិតជាដុល្លារនៃថ្លៃថ្នាំដែលបានផ្គត់ផ្គង់ទៅឱ្យឱសថស្ថានដៃគូ ទឹកប្រាក់បង់ដោយឱសថស្ថានដៃគូ និងចំនួនទឹកប្រាក់ដែលអ្នកជំងឺបានចំណាយលើថ្នាំនៅឱសថស្ថានដៃគូ។ ឆ្នាំ២០២៥ ការផ្គត់ផ្គង់ថ្នាំទៅឱ្យឱសថស្ថានដៃគូ និងការចំណាយលើថ្នាំរបស់អ្នកជំងឺដែលជាសមាជិកបណ្តាញមិត្តអប់រំមិត្ត បានបន្តធ្លាក់ចុះ ដោយសារមិនមានការពង្រីកទីតាំងថ្មីផង និងការបញ្ចប់កិច្ចសន្យានៅតាមស្រុកប្រតិបត្តិខ្លះ ដូចជាឆ្លង និងកំពង់ត្រឡាចជាដើម។

The figure above shows the values in USD of medicines which were supplied to contracted pharmacies, total amount paid by contracted pharmacies, and total amounts which patients contributed for medicines. In 2025, the supply to contracted pharmacies and the expenditure on medicines by registered patients decreased surprisingly little: no new pharmacies were added while contracts were discontinued in some areas for instant Chhlong and Kampong Tralach ODs.

យ៉ាងណាមិញ ការបង់ប្រាក់ត្រលប់របស់ឱសថស្ថានដៃគូទៅឱ្យអង្គការម.ព.ជ. បានបន្តបង្ហាញនូវសញ្ញាល្អប្រសើរជាមួយនឹងអាត្រា១០៧% ធៀបនឹងទំហំទឹកប្រាក់ផ្គត់ផ្គង់ក្នុងឆ្នាំ២០២៥។ អង្គការ ម.ព.ជ បន្តពង្រឹងនូវយុទ្ធសាស្ត្រលើកទឹកចិត្តឱ្យឱសថស្ថានដៃគូ បង់ប្រាក់ត្រលប់ឱ្យបានលឿន។

The 2025 payments by contracted pharmacies to MoPoTsyo showed improvement rate with 107% compared to the supply value in 2025. MoPoTsyo continues to strengthen the collection of revolving fund from the pharmacies.

តារាងទី 23៖ តម្លៃថ្នាំមូលនិធិទុនឱសថបង្វិលក្នុងឆ្នាំ២០២៥ The prices of revolving drug fund in 2025

Total Quantity Supplied to All Partner Pharmacies 2025													
No.	Items Description	Dosage	Cost of Goods Sold (COGS)		Total Quantity Supplied		Private pharmacy			Public Pharmacy		
			UNIT COST (KHR)	TOTAL COST (KHR)	Quantity (Tab/Vial/Piece)	Amount (KHR)	Quantity (Tab/Vial/Piece)	Avg Price (KHR)	Amount (KHR)	Quantity (Tab/Vial/Piece)	Avg Price (KHR)	Amount (KHR)
1	GLIBENCLAMIDE	5mg	18.89	95,528,718	5,057,287	294,086,384	732,113	38,511,852.67	45,508,224	4,325,174	61.21	264,763,732
2	METFORMINE	500mg	37.31	344,923,401	9,245,000	1,041,485,961	670,813	67,115,350.00	74,816,270	8,574,187	125.92	1,079,625,542
3	HYDROCHLOROTHIAZIDE	25mg	29.55	16,990,465	574,917	25,923,499	38,220	1,530,620.00	1,645,081	536,697	48.65	26,111,827
4	FUROSEMIDE	40mg	43.67	25,209,089	577,204	25,104,322	207,934	8,321,000.00	9,226,070	369,270	51.66	19,074,927
5	ATENOLOL	50mg	25.56	28,298,024	1,107,128	49,424,953	152,450	6,034,837.50	12,793,026	954,678	70.76	67,551,715
6	ENALAPRIL	10mg	60.77	63,270,048	1,041,181	116,613,349	116,245	11,509,030.70	15,941,866	924,936	141.25	130,647,004
7	AMITRIPTYLINE	25mg	20.36	21,645,729	1,063,298	47,768,542	102,450	4,098,000.00	6,060,842	960,848	64.78	62,245,360
8	AMLODIPINE	5/10mg	20.97	72,753,418	3,469,075	233,445,873	340,604	20,146,720.36	23,568,086	3,128,471	67.82	212,187,823
9	SIMVASTATINE	20mg	57.73	115,067,414	1,993,128	448,212,636	175,507	35,121,911.40	37,033,350	1,817,621	188.39	342,412,925
10	THIAMINE	50mg	41.19	158,462,854	3,847,064	292,983,189	568,570	39,653,957.50	41,090,273	3,278,494	71.64	234,864,721
11	MULTIVITAMINE	-	21.99	27,474,091	1,249,454	56,363,722	124,060	5,214,564.20	4,936,293	1,125,394	45.01	50,650,108
12	LOSARTAN	50mg	101.08	180,890,458	1,789,530	565,431,187	203,960	60,934,524.80	60,580,573	1,585,570	313.42	496,952,353
13	ASPIRIN	75mg	65.46	26,281,579	401,502	36,203,859	62,971	5,428,005.96	4,504,334	338,531	80.37	27,206,375
14	Gliclazide	80mg	81.47	70,372,637	863,800	155,391,184	117,032	19,613,825.76	22,635,108	746,768	200.31	149,582,582
15	INSULIN ACTRAPID (vial/10ml	10ml/Vial	11,072	1,826,936	165	4,491,181	103	2,631,181	1,634,909	62	21,290	1,320,000
16	INSULIN MIX 30/70 (vial/10ml)	10ml/Vial	13,618	181,895,218	13,357	390,909,927	2,240	57,399,927	53,900,904	11,117	25,469	283,140,000
17	INSULIN NPH (vial/10ml)	10ml/Vial	14,940	48,195,903	3,226	93,902,347	646	16,502,347	14,816,362	2,580	28,012	72,270,000
18	INSULIN SYRINGE (Paid)	Piece	196.77	5,256,317	26,713	9,634,989	3,100	1,048,358.00	99,909	23,613	495.27	11,694,776
19	INSULIN SYRINGE (Free)	Piece	196.77	49,432,559	251,220	-	44,835	-	-	206,385	-	-
Total Tablets				1,247,167,925	32,279,568	3,388,438,658	3,612,929		360,339,397	28,666,639		3,163,876,994
Total Insulin				231,918,057	16,748	489,303,456	2,989		70,352,175	13,759		356,730,000
Total syringes				54,688,876	277,933	9,634,989	47,935		99,909	229,998		11,694,776
TOTAL Amount in KHR				**1,533,774,858**		**3,887,377,103**			**430,791,481**			**3,532,301,770**

តារាងខាងលើនេះ បង្ហាញលម្អិតអំពីតម្លៃថ្នាំរបស់មូលនិធិឱសថបង្វិលទុនរបស់អង្គការ ម.ព.ជ. នៅក្នុងឆ្នាំ២០២៥ ជាតម្លៃថ្មីដែលអនុវត្តតាំងពីខែសីហា ២០២៤ រហូតមក។ យោងតាមតារាងនេះ យើងអាចដឹងអំពីបរិមាណនិងតម្លៃដែលអង្គការម.ព.ជ.បានបង់ទៅឱ្យអ្នកផ្គត់ផ្គង់ តម្លៃដែលអង្គការម.ព.ជ. គិតប្រាក់ពីឱសថស្ថានដៃគូ និងតម្លៃដែលឱសថស្ថានដៃគូគិតពីអ្នកជំងឺ។

The table above shows details about medicine price of RDF in 2025 based on the new prices in force from 01 August 2024 onward. According to the table we can know quantity and price MoPoTsyo paid to suppliers, price MoPoTsyo charged to contracted pharmacies, and price contracted pharmacies charged to patients.

តារាងខាងក្រោម បង្ហាញអំពីចំនួនករណីប្រើប្រាស់ឱសថតាមប្រភេទជំងឺ។ អក្សរ D តំណាងឱ្យសមាជិកដែលមានតែជំងឺទឹកនោមផ្អែមមួយមុខ អក្សរ DH តំណាងឱ្យសមាជិកដែលមានជំងឺទឹកនោមផ្អែមផង និងលើសសម្ពាធឈាមផង និងចុងក្រោយគឺអក្សរ H តំណាងឱ្យសមាជិកដែលមានតែជំងឺលើសសម្ពាធឈាម។ តារាងនេះ បានបង្ហាញអំពីគួរលេខ និងភាគរយនៃការប្រែប្រួលអ្នកប្រើថ្នាំតាមប្រភេទជំងឺ ក្នុងចំណោមសមាជិកមិត្តអប់រំមិត្ត។

The table below shows numbers of cases who paid for medicines. The letter D represents members with only diabetes. The letters DH represent members with diabetes and also hypertension, and lastly letter H represents members with only Hypertension. These showed a change in number and percentage of user according to medication type among PE network member.

តារាងទី 24៖ ចំនួនករណីបានចំណាយលើថ្នាំតាមប្រភេទជំងឺតាមឱសថស្ថានដៃគូទាំងអស់ក្នុងឆ្នាំនីមួយៗ *Nr of cases by type of patients spending for their medicines at the contracted pharmacies by year*

Nr of types of Individually registered Patients buying their medication (>0 times) at the contracted pharmacies					
Year	**D**	**DH**	**H**	**Unknown**	**Total**
2008	74	152	1	-	227
2009	240	484	11	-	735
2010	606	999	313	10	1,928
2011	965	1,752	941	4	3,662
2012	1,750	2,638	1,627	3	6,018
2013	2,542	3,369	2,055	-	7,966
2014	3,422	4,141	2,544	-	10,107
2015	3,830	4,177	2,478	1	10,486
2016	4,433	4,333	2,515	-	11,281
2017	5,126	4,737	2,478	-	12,341
2018	5,856	5,085	2,327	-	13,268
2019	6,386	6,445	2,608	-	15,439
2020	8,768	7,161	3,124	-	19,053
2021	8,232	8,559	2,911	-	19,702
2022	10,487	8,639	3,199	-	22,325
2023	11,089	9,996	3,531	-	24,616
2024	9,817	9,079	2,921	-	21,817
2025	9,042	8,750	2,690	-	20,482
% of each typ of individually registered Patient buying their medication at the contracted pharmacies					
Year	**D**	**DH**	**H**	**Unknown**	**Total**
2008	33%	67%	0.4%	0.00%	100%
2009	33%	66%	1%	0.00%	100%
2010	31%	52%	16%	0.52%	100%
2011	26%	48%	26%	0.11%	100%
2012	29%	44%	27%	0.05%	100%
2013	32%	42%	26%	0.00%	100%
2014	34%	41%	25%	0.00%	100%
2015	37%	40%	24%	0.01%	100%
2016	39%	38%	22%	0.00%	100%
2017	42%	38%	20%	0.00%	100%
2018	44%	38%	18%	0.00%	100%
2019	41%	42%	17%	0.00%	100%
2020	46%	38%	16%	0.00%	100%
2021	42%	43%	15%	0.00%	100%
2022	47%	39%	14%	0%	100%
2023	45%	41%	14%	0%	100%
2024	45%	42%	13%	0%	100%
2025	44%	43%	13%	0%	100%

ភ្ជាប់ជាមួយគ្នានេះដែរ ខាងក្រោមគឺតារាងបង្ហាញអំពីប្រេកង់នៃការចំណាយលើថ្នាំ ដែលអ្នកជំងឺជាសមាជិកត្រូវលេបជាប្រចាំ តាមរយៈវេជ្ជបញ្ជាដែលចេញដោយវេជ្ជបណ្ឌិតជំនាញ ក្នុងចំនោមករណីដែលបានចំណាយលើថ្នាំក្នុងឆ្នាំ ២០២៥។ ប្រេកង់នេះ ត្រូវបានកត់ត្រាតាមរយៈការគ្រង់គ្រងការចែកចាយតាមប្រព័ន្ធកុំព្យូទ័រ ដែលធ្វើឱ្យទិន្នន័យកាន់តែអាចជឿជាក់បាន។ ក្នុងឆ្នាំ២០២៥ ប្រេកង់ឬចំនួនដងនៃការចំណាយលើថ្នាំ គឺមានការថយចុះគ្រប់ប្រភេទជំងឺ។

The table below shows the frequency of contributions for their medicine by members based on prescriptions prescribed by doctors among the cases who have been contributing in 2025. This frequency has been recorded through computer system which makes data more reliable. In 2025, the frequencies or number of dispensing times decreased for all types of diseases.

Nr of times by type of patient buying their medication at the contracted pharmacies					
Year	**D**	**DH**	**H**	**Unknown**	**Total**
2008	131	235	1	-	367
2009	885	1,507	11	-	2,403
2010	2,439	3,730	573	11	6,753
2011	5,586	9,982	2,947	16	18,531
2012	9,456	16,517	5,825	9	31,807
2013	13,249	19,594	7,746	-	40,589
2014	16,803	21,908	9,291	-	48,002
2015	18,367	21,051	9,420	5	48,843
2016	22,367	21,988	9,607	-	53,962
2017	26,875	25,164	10,081	-	62,120
2018	31,898	28,393	9,976	-	70,267
2019	32,972	35,417	10,537	-	78,926
2020	40,190	46,159	12,890	-	99,239
2021	41,492	45,123	12,163	-	98,778
2022	54,805	45,369	13,057	-	113,231
2023	60,634	55,743	14,617	-	130,994
2024	52,228	49,670	12,243	-	114,141
2025	50,128	49,615	11,591	-	111,334
Type of patient buying medication at the contracted pharmacies					
Year	**D**	**DH**	**H**	**Unknown**	**Total**
2008	36%	64%	0%	0%	100%
2009	37%	63%	0%	0%	100%
2010	36%	55%	8%	0%	100%
2011	30%	54%	16%	0%	100%
2012	30%	52%	18%	0%	100%
2013	33%	48%	19%	0%	100%
2014	35%	46%	19%	0%	100%
2015	38%	43%	19%	0%	100%
2016	41%	41%	18%	0%	100%
2017	43%	41%	16%	0%	100%
2018	45%	40%	14%	0%	100%
2019	42%	45%	13%	0%	100%
2020	40%	47%	13%	0%	100%
2021	42%	45%	12%	0%	100%
2022	48%	40%	12%	0%	100%
2023	54%	50%	13%	0%	100%
2024	47%	45%	11%	0%	100%
2025	45%	45%	10%	0%	100%

តារាងខាងក្រោមនេះ បង្ហាញអំពីទំហំនៃការចំណាយសម្រាប់ថ្នាំរបស់សមាជិក ដោយបែងចែកទៅតាមប្រភេទជំងឺ នៅតាមឱសថស្ថានដៃគូរបស់បណ្តាញមិត្តអប់រំមិត្ត សម្រាប់រយៈពេលពេញមួយឆ្នាំ។ យើងឃើញថា ក្នុងឆ្នាំ២០២៥នេះ ការចំណាយរបស់អ្នកជំងឺគឺបានថយចុះ ទាំងអ្នកជំងឺទឹកនោមផ្អែម និងអ្នកជំងឺលើសសម្ពាធឈាម។

The table below shows the amount in riel of spending for medicine during the whole year through contracted pharmacies of PE network separated by type of diseases. In 2025, the amount paid for medicine was decreased for both patients with diabetes and patient with non-diabetes hypertension.

តារាងទី 25៖ ទំហំទឹកប្រាក់(រៀល) និង%នៃបង់ភាគទានលើថ្នាំតាមឱសថស្ថានដៃគូទាំងអស់ក្នុងឆ្នាំនីមួយៗ Amount spent in riels and % of contribution at the contracted pharmacies by year

Amount Spent in riel by type of patients for their medcation at contracted pharmacies					
Year	D	DH	H	Unknown	Total
2008	1,587,400	3,218,050	6,500	0	4,811,950
2009	15,884,750	23,441,850	101,700	0	39,428,300
2010	46,739,630	65,049,500	5,418,950	191,750	117,399,830
2011	108,025,620	199,061,920	6,717,050	325,000	314,129,590
2012	177,273,730	327,767,280	36,865,950	167,000	542,073,960
2013	266,819,270	432,059,455	85,225,170	0	784,103,895
2014	361,484,645	546,470,980	119,754,440	0	1,027,710,065
2015	417,837,130	565,916,710	135,071,640	76,300	1,118,901,780
2016	538,222,360	624,370,650	155,706,770	0	1,318,299,780
2017	691,156,905	762,293,720	174,837,905	0	1,628,288,530
2018	866,544,065	923,256,300	198,142,460	0	1,987,942,825
2019	914,159,090	1,202,091,740	221,321,670	0	2,337,572,500
2020	1,115,021,410	1,555,953,950	266,259,550	0	2,937,234,910
2021	1,271,812,877	1,535,498,592	256,062,030	0	3,063,373,500
2022	1,775,216,845	1,694,189,177	309,226,803	0	3,778,632,825
2023	2,503,567,726	2,529,153,739	446,553,844	0	5,479,275,309
2024	1,984,889,437	2,056,964,235	314,129,566	0	4,355,983,238
2025	1,944,797,385	2,024,062,320	302,785,780	0	4,271,645,485
% by type of patient spent on their medication at the contracted pharmacies					
Year	D	DH	H	Unknown	Total
2008	33%	67%	0%	0%	100%
2009	40%	59%	0%	0%	100%
2010	40%	55%	5%	0%	100%
2011	34%	63%	2%	0%	100%
2012	33%	60%	7%	0%	100%
2013	34%	55%	11%	0%	100%
2014	35%	53%	12%	0%	100%
2015	37%	51%	12%	0%	100%
2016	41%	47%	12%	0%	100%
2017	42%	47%	11%	0%	100%
2018	44%	46%	10%	0%	100%
2019	39%	51%	9%	0%	100%
2020	38%	53%	9%	0%	100%
2021	42%	50%	8%	0%	100%
2022	47%	45%	8%	0%	100%
2023	46%	46%	8%	0%	100%
2024	46%	47%	7%	0%	100%
2025	46%	47%	7%	0%	100%

តារាងខាងក្រោម បង្ហាញពីភាពខុសគ្នារវាង ការផ្គត់ផ្គង់អាំងស៊ុយលីនទៅឱសថស្ថានដៃគូ និងបរិមាណឱសថស្ថានដៃគូមានចែកចាយទៅឱ្យសមាជិក តាមរយៈបង្កាន់ដៃបង់ប្រាក់ក្នុងប្រព័ន្ធទិន្នន័យរបស់អង្គការ ម.ព.ជ.។ តាមទីតាំងនីមួយៗ មានភាពខុសគ្នាតិចឬច្រើន ពាក់ព័ន្ធផងដែរពីការសល់ស្តុកចុងឆ្នាំចាស់ ដែលត្រូវបន្តចែកចាយនៅដើមឆ្នាំថ្មី។ នាដំណាច់ឆ្នាំ ២០២៥ ម.ព.ជ. ក៏បានធ្វើការរាប់ស្តុកនៅគ្រប់ឱសថស្ថានដៃគូផងដែរ។ មានបង្កាន់ដៃតិចតួចដែលបានបញ្ជូនមកអង្គការ តែយើងមិនបានបញ្ចូលក្នុងប្រព័ន្ធ ដោយសារមិនមានបញ្ជាក់កូដ ម.ព.ជ. របស់អ្នកជំងឺ វាអាចប៉ះពាល់ដល់របាយការណ៍ចែកចាយឱសថបង្វិលទុនផងដែរ។ ប៉ុន្តែបញ្ហានេះ គឺត្រូវបានលើកលែង។ មានសមាជិកចំនួន ១៧០២នាក់ កំពុងប្រើអាំងស៊ុយលីនក្នុងឆ្នាំ ២០២៥។

The table below shows the variation between our supply of insulin to the pharmacies and the receipts entered in our database. At the start of the year, the pharmacies still have left over from the previous year. In 2025, MoPoTsyo just counted the remaining stock of medicine at the end of the year from all partnered pharmacies.

There were a few receipts that we could not enter into our database because of lack information of patient ID code. It affects to RDF's medicine report but that problem is exceptional. 1,702 members were using insulin in 2025.

តារាងទី 26៖ ការប្រើប្រាស់អាំងស៊ុយលីន(ម.ល) Quantity in usage of insulin (ml)

The Comparison of Supply to Pharmacy and Dispensing the Insulin (ml) to the patients in the pharmacy					
Nr	Pharmacy	Year 2025			
		Supply to PH	Dispense	Missing	% of missing
1	មន្ទីរពេទ្យបង្អែក បាវាយណ៍-សន្ទុក	2508	2508	-	0%
2	មណ្ឌលសុខភាព គ្រើល	725	751	(26)	-4%
3	មន្ទីរពេទ្យបង្អែក ស្ទោង	200	215	(15)	-8%
4	មណ្ឌលសុខភាព ដូង	0	0	-	-
5	មណ្ឌលសុខភាព ជុំក្រវ៉ាន់	74	72	2	3%
6	មន្ទីរពេទ្យបង្អែក គងពិសី	653	623	30	5%
7	មណ្ឌសុខភាព រំពាមានជ័យ	520	499	21	4%
8	មណ្ឌលសុខភាព វាលអង្គពពេល	273	238	35	13%
9	មន្ទីរពេទ្យបង្អែក ឧដុង្គ	553	482	71	13%
10	មន្ទីរពេទ្យបង្អែក ត្រពាំងក្រឡឹង	275	252		0%
11	មន្ទីរពេទ្យបង្អែក អង្គរជ័យ	966	879	87	9%
12	មណ្ឌលសុខភាព ចំប៉ី	250	268	(18)	-7%
13	មន្ទីរពេទ្យបង្អែក ពោធិ៍ចិនតុង	1511	1491	20	1%
14	មណ្ឌលសុខភាព សាមគ្គី	96	60	36	38%
15	ប៉ុស្ត៍សុខភាព កន្ទោក	164	133	31	19%
16	មន្ទីរពេទ្យបង្អែក មិត្តភាពកម្ពុជាចិនសែនសុខ	816	827	(11)	-1%
17	មន្ទីរពេទ្យបង្អែក សម្តេចឪសម្តេចម៉ែ	-1	10	(11)	1100%
18	មន្ទីរពេទ្យបង្អែក ចំការលើ	278	273	5	2%
19	មន្ទីរពេទ្យបង្អែក កងមាស	920	872	48	5%
20	មន្ទីរពេទ្យបង្អែក ស្វាយចេក	573	583	(10)	-2%
21	មណ្ឌលសុខភាព ថ្មពូក	150	146	4	3%
22	មន្ទីរពេទ្យបង្អែក រមាសហែក	495	518	(23)	-5%
23	មន្ទីរពេទ្យបង្អែក ជីភូ	30	34	(4)	-13%
24	មណ្ឌលសុខភាព មេសចូក	34	1	33	97%
25	មន្ទីរពេទ្យបង្អែក សាមគ្គីរំដួល	37	41	(4)	-11%
26	មន្ទីរពេទ្យបង្អែក ស្វាយទាប	110	77	33	30%
27	មន្ទីរពេទ្យបង្អែក ស្វាយជ្រំ	75	68	7	9%
28	មណ្ឌលសុខភាព រការក្នុង	100	97	3	3%
29	មន្ទីរពេទ្យបង្អែក អង្គរការ	0		-	-
30	មន្ទីរពេទ្យបង្អែក ព្រៃកប្បាស	40	34	6	15%
31	មន្ទីរពេទ្យបង្អែក កោះអណ្តែត	405	203	202	50%
32	មណ្ឌលសុខភាព បារិត	20	17	3	15%
33	មន្ទីរពេទ្យបង្អែក ខ្សាច់កណ្តាល	534	335	199	37%
34	មន្ទីរពេទ្យបង្អែក ឆ្លូង	188	90	98	52%
35	មន្ទីរពេទ្យបង្អែក ក្រូចឆ្មារ	92	45	47	51%
36	មន្ទីរពេទ្យបង្អែក ជើងព្រៃ	12	6	6	50%
37	ឱសថស្ថានដៃគូ បរិបូណ៌	3	13	(10)	-333%
38	ឱសថស្ថានដៃគូ និរោធន៍	2949	1539	1,410	48%
Total		**16,628**	**14,300**	**2,328**	14%

លទ្ធផលHbA1c៖ HbA1c គឺជាតេស្តឈាមដ៏សំខាន់មួយសម្រាប់បង្ហាញពីកម្រិតជាមធ្យមនៃជាតិស្ករក្នុងឈាមរយៈពេល ៣ខែកន្លងមក។ វា ជាការវាស់ភាគរយនៃអេម៉ូក្លូប៊ីនក្នុងកោសិកាឈាមក្រហមដែលមានជាប់ដោយគ្លុយកូស។ ជាទូទៅ មនុស្សដែលមានកម្រិត HbA1c ធំជាងឬស្មើ ៦,៥% ត្រូវបានចាត់ទុកថាជាអ្នកជំងឺទឹកនោមផ្អែម។ ដោយឡែកសម្រាប់អ្នកជំងឺទឹកនោមផ្អែម(ភាគច្រើនវ័យចាស់)ដែលអាចចាត់ទុកថា គ្រប់គ្រងកម្រិតជាតិស្ករក្នុងឈាមបានល្អគួរតែលទ្ធផល HbA1c ឱ្យនៅក្រោម ៧,៥%។ ក្នុងឆ្នាំ២០២៤ យើងបានធ្វើការប្រៀបធៀនលទ្ធផលតេស្ត HbA1c ក្នុងចំណោមអ្នកជំងឺទឹកនោមផ្អែមចំនួន ៤ ០៣១នាក់។ ចំណែកឆ្នាំ២០២៥នេះ យើងបន្តធ្វើការប្រៀបធៀបលទ្ធផលតេស្តHbA1c ក្នុងចំណោមអ្នកជំងឺទឹកនោមផ្អែមចំនួន ២៤២៦ នាក់ ដែលកំពុងបន្តទទួលផលពីកម្មវិធីបណ្តាញមិត្តអប់រំមិត្ត។ លទ្ធផលតេស្ត HbA1c ក្នុងឆ្នាំ២០២៥របស់ពួកគេ ត្រូវបានប្រៀបធៀបនឹងលទ្ធផលតេស្តលើកទី១ ដែលបានធ្វើកាលពី១ឆ្នាំកន្លងទៀតយ៉ាងឆាប់។ ជាលទ្ធផលបង្ហាញថា ភាគរយនៃ HbA1c តូចជាង ៧,៥% បានប្រែប្រួលពី៣៦% នៅពេលធ្វើតេស្តលើកទី១ ទៅដល់ ៤៥% ពេលធ្វើតេស្ត ចុងក្រោយក្នុងឆ្នាំ២០២៥។

HbA1c Results: HbA1c is a blood test that reflects average blood sugar levels over the past 3 months. It measures the percentage of hemoglobin in red blood cells that has glucose attached to it. The HbA1c equals or is greater than 6.5% is defined as diabetes. For the (mostly elderly) patients with diabetes should keep HbA1c lower than 7.5% to be good enough control of their diabetes. Last year, we started to observe the comparision of the first HbA1c result tested at time of registration with PE network and the latest result tested among 4,031 diabetes patients. Again, this year we compared the first HbA1c and the 2025's. It shows improvement in percentage of patients with good control (HbA1c<7.5%) from 36% to 45%.

រូបភាពទី23៖ ប្រៀបធៀបលទ្ធផល HbA1c តេស្តលើកទី១និងលើកចុងក្រោយរបស់អ្នកជំងឺទឹកនោមផ្អែមក្នុងឆ្នាំ២០២៥Comparing HbA1c at first and at last amoung registered DM in 2025



មួយវិញទៀត យើងក៏បានធ្វើការសិក្សាលើលទ្ធផលកម្រិតជាតិស្ករមុនហូប (Fasting blood glucose) តាមរយៈតេស្តមន្ទីរពិសោធន៍វេជ្ជសាស្ត្រនៃអ្នកជំងឺទឹកនោមផ្អែមចំនួន ៣១៩១នាក់ ដោយធ្វើការប្រៀបធៀបការធ្វើតេស្តលើកទី១ បន្ទាប់ពីចុះឈ្មោះជាមួយកម្មវិធីបណ្តាញមិត្តអប់រំ ទៅនិងលទ្ធផលធ្វើតេស្តលើកចុងក្រោយក្នុងឆ្នាំ២០២៥នេះ។ ជាលទ្ធផលបង្ហាញថា ភាគរយនៃអ្នកជំងឺដែលមានជាតិស្ករមុនហូបក្រោម១២៧mg/dl បានប្រែប្រួលកើនឡើងពី ៤៥%នៅគ្រាដំបូង ទៅដល់៥១%នៅពេលធ្វើតេស្តលើកចុងក្រោយក្នុងឆ្នាំ២០២៥។

On the other hand, we also studied the fasting blood glucose through the laboratory testing. We compared the FBG test results between the first and last time among 3191 patients who are using lab-test in 2025. The result showed that the percentage of patients with FBG<127mg/dl 45% at the first test compares to 51% at the lastest test in 2025.

រូបភាពទី24៖ ប្រៀបធៀបលទ្ធផលFBGតេស្តលើកទី១និងលើកចុងក្រោយរបស់អ្នកជំងឺទឹកនោមផ្អែមក្នុងឆ្នាំ២០២៥ Comparing fasting blood glucose at first and at last among registered DM in 2025



ការគ្រប់គ្រងកូឡេស្តេរ៉ូល៖ តាមរយៈលទ្ធផលតេស្តមន្ទីរពិសោធន៍វេជ្ជសាស្ត្រឆ្នាំ២០២៥ អាចឱ្យយើងធ្វើការប្រៀបធៀបបានពីការប្រែប្រួលនៃការគ្រប់គ្រងកូឡេស្តេរ៉ូល ជាមួយលទ្ធផលតេស្តលើកទី១ក្នុងចំណោមសមាជិក៣៦៣៥នាក់។ យើងកំណត់យកកម្រិតតួតាល់កូឡេស្តេរ៉ូល 200mg/dl ចាត់ទុកថា អ្នកជំងឺអាចគ្រប់គ្រងកូឡេស្តេរ៉ូលបានល្អ។ តាមរយៈការវិភាគបង្ហាញថា ៣៩% ក្នុងចំណោមពួកគេ មានកម្រិតតួតាល់កូឡេស្តេរ៉ូលក្រោម 200mg/dl នៅពេលធ្វើតេស្តលើកដំបូង។ ក្នុងចំណោមពួកគេដដែល លទ្ធផលតេស្តតួតាល់កូឡេត្រ៉ូលក្រោម 200mg/dl បានកើនឡើងដល់៦៩% នៅពេលធ្វើតេស្តលើកចុងក្រោយក្នុងឆ្នាំ ២០២៥នេះ។

Controlling Total Cholesterol: from the lab tests in 2025 among the registered patients, we could see the outcome of controlling their total cholesterol. We observed the results of lab test over period of time at least 365 days from the first result to the latest results. The graph below showed the improvement in percentage of patients with total cholesterol <200mg/dl of 39% from the first lab test compared to 69% from the latest lab test in 2025.

រូបភាពទី25៖ ប្រៀបធៀបលទ្ធផលកូឡេត្រ៉ូលពេលតេស្តលើកទី១និងលើកចុងក្រោយរបស់អ្នកជំងឺជាសមាជិកក្នុងឆ្នាំ២០២៥ Comparing total cholesterol at first and at last amoung registered patients in 2025



ការគ្រប់គ្រងសម្ពាធឈាម៖ តាមរយៈលទ្ធផលនៃការវាស់សម្ពាធឈាមក្នុងចំណោមសមាជិកប្រមាណ៤២៤៦នាក់ ដែលជាអ្នកជំងឺលើសសម្ពាធឈាម និងអ្នកជំងឺទឹកនោមផ្អែមលើសសម្ពាធឈាម នៅពេលពួកគេបានទៅជួបជាមួយគ្រូពេទ្យដើម្បីធ្វើរោគវិនិច្ឆ័យបញ្ជាក់ឬតាមដានឡើងវិញ យើងអាចធ្វើការប្រៀបធៀបលទ្ធផលសម្ពាធឈាម នៅពេលជួបពេទ្យលើកចុងក្រោយក្នុងឆ្នាំ២០២៥ ទៅនិងលទ្ធផលជួបពេទ្យលើកទី១(ដើមគ្រា)។ ក្នុងតារាងខាងក្រោមបង្ហាញថា លទ្ធផលសម្ពាធឈាមស៊ីស្តូលីក (<140mmHg) បានប្រែប្រួលពី៥៥%នៅដើមគ្រា ទៅដល់ ៧១%នៅពេលវាស់លើកចុងក្រោយ។ លទ្ធផលសម្ពាធឈាមឌីយ៉ាស្តូលីក (<90mmHg)បានប្រែប្រួលពី៦១% ទៅ ៧៨%។ បើយើងធ្វើការប្រៀបធៀប លើលទ្ធផលនៃការគ្រប់គ្រងសម្ពាធឈាមបានល្អ ដោយកំណត់យកស៊ីស្តូលីក <140mmHg និងឌីយ៉ាស្តូលីក <90mmHg នោះយើងឃើញថា ក្នុងចំណោមអ្នកជំងឺ ៤២៤៦នាក់ខាងលើនេះ ៤២%អាចគ្រប់គ្រងសម្ពាធឈាមបានល្អនៅគ្រាដើម ហើយភាគរយនេះបានកើនឡើងដល់ ៦២% នៅពេលវាស់លើកចុងក្រោយក្នុងឆ្នាំ២០២៥។

Hypertension: from the results of blood pressure measurement at first consultation appointment versus the results from the latest consultation appointment among 4246 registered patient with hypertension and/or patients with diabetic hypertension. The comparison showed, in the graphs below, that the patients with systolic <140mmHg is 55% at first measurement rose to 71% at the latest systolic measurement in 2025. Doing the same way, the result of patients with diastolic <90mmHg is 61% at first measurement changed to 78% at latest diastolic measurement. On the other way, if we compare the percentage of patients with undercontrolled of both systolic (<140mmHg) and diastolic (<90mmHg) from the first consultaiton to the lastest consultation among the patients mentioned earlier; the result showed improvement from 42% to 62%.

រូបភាពទី26៖ ប្រៀបធៀបលទ្ធផលគ្រប់គ្រងស៊ីស្តូលីកនិងឌីយ៉ាស្តូលីកវាស់លើកទី១ និងលទ្ធផលចុងក្រោយក្នុងឆ្នាំ២០២៥. ***% of Systolic and Diastolic undercontrol among registered patient with HBP from the first vs. the latest result in 2025***



រូបភាពទី27៖ ប្រៀបធៀបលទ្ធផលគ្រប់គ្រងសម្ពាធឈាមរបស់សមាជិកលើសសម្ពាធឈាមវាស់លើកទី១ និងលទ្ធផលចុងក្រោយក្នុងឆ្នាំ ២០២៥ . ***% of BP undercontrol among registered patient with HBP from the first vs. the latest result in 2025***



ជារៀងរាល់ឆ្នាំ អង្គការ ម.ព.ជ. តាមរយៈមិត្តអប់រំមិត្ត បានធ្វើការសម្ភាសន៍វាយតម្លៃភាពពេញចិត្តកម្មវិធី ពីអ្នកជំងឺ ដែលបានចុះឈ្មោះនិងកំពុងប្រើប្រាស់សេវា ដោយចំពោះលើសេវាឱសថនៃមូលនិធិបង្វិលទុន។ នៅក្នុងឆ្នាំ២០២៥នេះ អ្នកជំងឺប្រមាណ៣០៥៩ករណី បានផ្តល់ចម្លើយសម្រាប់កម្រងសំណួរអង្កេតស្តង់ដា១០សំណួរ។ សំណួរនីមួយៗគឺជាប្រភេទសំណួរមានចម្លើយពហុជ្រើសរើស។ ចម្លើយត្រូវបានកម្រិតពីលេខ១ ដល់លេខ៤ ដែលកំណត់លេខ១ជាចម្លើយវិជ្ជមាន លេខ២ជាចម្លើយពាក់កណ្តាលវិជ្ជមាន លេខ៣ជាចម្លើយអវិជ្ជមាន និងលេខ៤ជាចម្លើយវិជ្ជមានបំផុត។ តាមរយៈការវិភាគបានបង្ហាញថា អ្នកជំងឺដែលបានផ្តល់ចម្លើយមានប្រមាណ ៨៣,៣% ជ្រើសយកទី១ និង១៤,២%ជ្រើសយកលេខ២ ចំណែក២,១%និង០,៤% ជ្រើសយកលេខ៣និងលេខ៤រៀងគ្នា។ នេះ បង្ហាញថា អ្នកជំងឺភាគច្រើនលើសសុប គឺមានការពេញចិត្តជាមួយសេវាឱសថនៃមូលនិធិបង្វិលទុនដែលពួកគេកំពុងប្រើប្រាស់។

Every year, MoPoTsyo did a satisfaction survey through interviewing the randomly selected patients as beneficairies of RDF medicine. In 2025, the survey interviewed 3059 patients. They provided the answers to a structured questionnaire with 10 questions. Each question consisted of 4 ranking prepared anwers which 1st answer is positively satisfied, 2nd anwer is more or less satisfied, 3rd answer is unsatisfied, and 4th answer is really unsatisfied. The result showed that 1st=83.3%, 2nd=14.2%, 3rd=2.1%, and 4th=0.4%. This result implied that the majority of the patients were satisfied with the RDF medicine service operating in their nearby public health facilities

រូបភាពទី28៖ លទ្ធផលវាយតម្លៃការពេញចិត្តលើសេវាឱសថបង្វិលទុនក្នុងឆ្នាំ២០២៥ ***Result of Satisfaction Survey for RDF in 2025***



ក្នុងចំណោមសំណួរទាំង១០ មានសំណួរចុងក្រោយបានសួរត្រង់ថាតើ អ្នកជំងឺពេញចិត្តនឹងសេវាឱសថនៃមូលនិធិបង្វិលទុនរបស់ ម.ព.ជ. ឬទេ។ ជាលទ្ធផលបង្ហាញថា ក្នុងចំណោមអ្នកជំងឺដែលបានឆ្លើយតបទាំង៣០៥៩នាក់ មាន ៩០,៧% បានជ្រើសយកចម្លើយ"ពេញចិត្ត" ចំណែក៨,៩% ទៀតបានជ្រើសរើសចម្លើយ"មិនសូវពេញចិត្តតែអាចទទួលយកបាន"។ ក្នុងចំណោមអ្នកឆ្លើយទាំងអស់ គឺមាន០,៣% ជ្រើសយកចម្លើយថា "សេវានេះមិនអាចទទួលយក" និងមានត្រឹមតែ០,១% ប៉ុណ្ណោះដែលជ្រើសយកចម្លើយ "មិនពេញចិត្តសោះ"។

Specifically the question number 10 asks directly whether the patient is satisfied with the service of RDF medicines. The result from the survey for this queston shows that among 3,059 sampled patients, 90.7% is " satisfied", 8.9% is "not satisfied but find it acceptable", only 0.3% responded that "the service is not acceptable", and 0.1% is " totally unsatisfied" .



ពន្យារការវិវត្តជំងឺតម្រងនោមរ៉ាំរ៉ៃ SLOWING DOWN PROGRESSION OF CHRONIC KIDNEY DISEASE (CKD)

អ្នកជំងឺទឹកនោមផ្អែមឬអ្នកជំងឺលើសសម្ពាធឈាមគឺងាយនឹងវិវត្តទៅមានបញ្ហាជំងឺតម្រងនោមរ៉ាំរ៉ៃ Chronic Kidney Disease (CKD)។ ប្រសិនបើអ្នកជំងឺ អាចគ្រប់គ្រងសម្ពាធឈាមនិងកម្រិតជាតិស្ករក្នុងឈាមបានល្អ ការវិវត្តនៃបញ្ហាCKD ទៅជាជំងឺតម្រងនោមដំណាក់កាលចុងក្រោយ End-Stage Kidney Disease (ESKD) អាចត្រូវបានបន្ថយល្បឿន។ ពន្យារការវិវត្តESKD គឺជាគោលបំណងសំខាន់មួយក្នុង **ការបង្ការកម្រិត២** (Secondary Prevention) ដែលជាការបង្ការទប់ស្កាត់ផលវិបាក ចំពោះអ្នកជំងឺដែលរស់នៅជាមួយជំងឺទឹកនោមផ្អែមឬជំងឺលើសសម្ពាធឈាមស្រាប់ហើយ។

ការសិក្សាមួយដែលធ្វើឡើងនៅប្រទេសសិង្ហបុរី បានរកឃើញថា ៣៩.៣% នៃអ្នកជំងឺទឹកនោមផ្អែមប្រភេទ២ បានវិវត្តទៅមានបញ្ហា CKD ក្នុងរយៈពេលព្យាបាលបន្តជាមធ្យម ២.៨ឆ្នាំ។ ការសិក្សាផ្សេងទៀតធ្វើឡើងនៅប្រទេសចិនបានបង្ហាញថា ជំងឺទឹកនោមផ្អែមគឺជាមូលហេតុចម្បងនៃការវិវត្តនៃជំងឺ CKD (៤០.៥%ក្នុងរបាយការណ៍មួយ) និងជាមូលហេតុសំខាន់នៃជំងឺតម្រងនោមដំណាក់កាលចុងក្រោយ (ESKD)។ ទូទាំងពិភពលោក ការប៉ាន់ស្មានបង្ហាញថាប្រហែល២០% ទៅ៥០%នៃអ្នកជំងឺទឹកនោមផ្អែមប្រភេទ២ នឹងវិវត្តទៅជាជំងឺតម្រងនោមទឹកនោមផ្អែម(DKD)។ អត្រានៃការព្យាបាលដោយការជំនួសតម្រងនោម(KRT) ក៏ត្រូវបានព្យាករណ៍ថានឹងកើនឡើងគួរឱ្យកត់សម្គាល់ផងដែរ។ ដូច្នេះ ប្រៀបធៀបជាមួយការសិក្សាខាងលើ។ តើអ្នកជំងឺជាសមាជិកម.ព.ជ. មានលទ្ធផលនៃការវិវត្តិនេះយ៉ាងដូចម្តេច?

People with Diabetes and/or Hypertension are more likely to develop Chronic Kidney Disease. With good blood pressure control and blood glucose control the progression of CKD to End-Stage Kidney Disease can be slowed down. It is an important objective in “Secondary Prevention”, the prevention of complications in patients who have diagnosed with diabetes or hypertension already.

A study conducted in Singapore (referenced further below) found that 39.3% of patients with type 2 diabetes experienced CKD progression over a mean follow-up period of 2.8 years. Other studies from China indicate that diabetes is a leading cause of CKD progression (40.5% in one report) and a significant cause of End-Stage Kidney Disease (ESKD). Globally, estimates suggest that approximately 20-50% of patients with Type 2 Diabetes Mellitus (T2DM) will ultimately develop Diabetic Kidney Disease (DKD). The incidence of kidney replacement therapy (KRT) is also projected to increase significantly. So how do MoPoTsyo patients compare?

ក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ ភស្តុតាងកាន់តែច្រើនឡើងបានគាំទ្រការប្រើប្រាស់ uACR (urine-Albumin to Creatinine Ratio) ដោយប្រើបន្ទះតេស្ត dipstick ដើម្បីវាស់សមាមាត្រអាល់ប៊ុយមីនក្នុងទឹកនោមនិងគ្រេអាទី-នីនក្នុងទឹកនោម។ បន្ទះតេស្តតេស្តទឹកនោមដែលមានតម្លៃទាបនេះមានប្រយោជន៍ខ្លាំងណាស់ ក្នុងការកំណត់ស្ថានភាពជំងឺនៅកម្រិតបឋម និងចាត់ចំណាត់ថ្នាក់ជំងឺតម្រងនោមរ៉ាំរ៉ៃ CKD នៅទូទាំងពិភពលោក។ អង្គការ ម.ព.ជ. បានណែនាំការធ្វើតេស្ត uACRនេះ តាំងពីឆ្នាំ២០១៤។ យោងតាមការណែនាំធ្វើតេស្តនេះសម្រាប់ដំណាក់កាលដំបូង ដែលផ្តល់ជូនសមាជិក ម.ព.ជ. និងដោយការរួមបញ្ចូលវាជាមួយនឹងលទ្ធផលតេស្ត serum-creatinine (sCr) សម្រាប់ការគណនា eGFR (estimated Glomerular Filtration Rate)។ ការរួមបញ្ចូលទាំងលទ្ធផលតាមតេស្តទឹកនោមនិងតាមឈាម ទៅក្នុងនីតិវិធីនៃការយកសំណាកសម្រាប់តេស្តមន្ទីរពិសោធន៍ រួមចំណែកធ្វើឱ្យមានទម្រង់លទ្ធផលតេស្តមន្ទីរពិសោធន៍ស្តង់ដារ ដែលបានកត់ត្រានៅក្នុងប្រព័ន្ធមូលដ្ឋានទិន្នន័យ។ លទ្ធផលនេះ បានជួយឱ្យវេជ្ជបណ្ឌិត ធ្វើរោគវិនិច្ឆ័យនិងគ្រប់គ្រងការវិវត្តនៃជំងឺតាមពេលវេលា ទៅតាមដំណាក់កាលនិងប្រភេទផ្សេងៗគ្នានៃជំងឺCKD។ យ៉ាងហោចណាស់ ចំពោះអ្នកជំងឺដែលនៅតែប្រើប្រាស់សេវាថែទាំព្យាបាលគាំទ្រដោយកម្មវិធីបណ្តាញមិត្តអប់រំមិត្ត។

Over the past decade more and more evidence has emerged which supports the use of (uACR) dipstick to measure in spot urine sample the ratio of urine-Albumin and urine-Creatinin. This low-cost urine dipstick is very useful in primary care settings all over the world to screen and help classify (CKD) Chronic Kidney Disease. MoPoTsyo introduced it in 2014. Thanks to early introduction of the test offered to MoPoTsyo's members and by combining it with serum-creatinin test result (sCr) for the calculation of eGFR (estimated Glomerular Filtration Rate). The inclusion of both (urine + blood) into the sampling practices in the laboratory service contribute to the standard lab profiles recorded in the database. This helps the Doctor to diagnose and control the evolution over time of the patients through the different stages and categories of CKD, at least of the patients who are still using the services.

ប្រភេទuACR ត្រូវបានចាត់ចំណាត់ថ្នាក់ជា៣កម្រិតពីកម្រិតធម្មតាទៅកម្រិតធ្ងន់ធ្ងរ៖

A1: uACR តិចជាង ៣០ មីលីក្រាម/ក្រាម
A2: uACR ពី ៣០ - ៣០០ មីលីក្រាម/ក្រាម
A3: uACR ច្រើនជាង ៣០០ មីលីក្រាម/ក្រាម

The uACR uses 3 categories from normal to worse :

A1 is uACR less than 30mg/g
A2 is uACR from 30 - 300mg/g
A3 is uACR More than 300mg/g

ប្រភេទនៃ uACR ត្រូវបានរួមផ្សំជាមួយដំណាក់កាលeGFRទាំង៦ នៅក្នុងទម្រង់លទ្ធផលមន្ទីរពិសោធន៍ ដើម្បីចាត់ថ្នាក់ជំងឺ CKD ទៅជាត្រឹមតែ៤ប្រភេទហានិភ័យ ដែលបង្ហាញដោយពណ៌។

The uACR categories are then combined with the 6 stages of eGFR result in the lab profile to classify the CKD into only 4 risk categories indicated by colors.

យើងបានសិក្សាលើអ្នកជំងឺចំនួន ៧ ០៥៦នាក់ ដែលបានប្រើប្រាស់តេស្តមន្ទីរពិសោធន៍វេជ្ជសាស្ត្ររបស់ ម.ព.ជ. ក្នុងឆ្នាំ២០២៤ ប៉ុន្តែអ្នកជំងឺទាំងនេះ មានប្រវត្តិលទ្ធផលតេស្តមន្ទីរពិសោធន៍ច្រើនជាង១ ដើម្បីប្រៀបធៀបគ្នា។ ជាបឋម យើងពិនិត្យមើលលើការប្រែប្រួលនៃ uACR បន្ទាប់មកមើលលើការប្រែប្រួលនៃ eGFR (សេរ៉ូមឈាម) ហើយបន្ទាប់មកមើលការប្រែប្រួលរួមគ្នាទាំងពីរនេះ ដើម្បីបកស្រាយការប្រែប្រួលតាមចំណាត់ថ្នាក់នៅក្នុងតារាង CKD។

We looked at 7056 patients who had used the MoPoTsyo's laboratory service in 2024 but had more than 1 lab profile in the past to compare it with. We look first at the uACR (from urine) changes, then at the eGFR (from blood-serum) changes and then at the combined changes of these 2 to interpret the changes in the CKD chart.



លទ្ធផលនៃការសិក្សា លើស្ថានភាពនៃការវិវត្តបញ្ហាគម្រងនោមក្នុងចំណោមអ្នកជំងឺបានចុះឈ្មោះ ក្នុងបណ្តាញមិត្តអប់រំមិត្តចំនួន ៧ ០៥៦នាក់ ត្រូវបានបង្ហាញក្នុងតារាងខាងក្រោម។ ចំណាត់ថ្នាក់នៃ uACR របស់ពួកគេគឺ មិនបានផ្លាស់ប្តូរចំពោះអ្នកជំងឺភាគច្រើននោះទេ។ អ្នកជំងឺ ១ ០៥២នាក់ (១៥%) បានប្រែប្រួលប្រសើរឡើង ប៉ុន្តែអ្នកជំងឺ ១ ៣៣៧ នាក់ (១៩%)នៃអ្នកជំងឺទាំងនេះ បានវិវត្តនៅកាន់ដំណាក់កាលអាក្រក់ជាងក្នុងរយៈពេលជាមធ្យម៣.៣ឆ្នាំ។ ជារួម ពួកគេទាំងអស់នេះ បានបន្តតាមដាននិងប្រើប្រាស់សេវាថែទាំកម្រិតបឋមដែលគាំទ្រដោយកម្មវិធីបណ្តាញមិត្តអប់រំមិត្ត ក្នុងរយៈពេលជាមធ្យមគឺ ប្រហែល៣ឆ្នាំ។

The results of the study on 7056 patients who had used the MoPoTsyo's laboratory service in 2024 but had more than 1 time as shown in the table below. The uACR category did not change in majority of patients. There were 1,052 patients (15%) even improved, but 1,337 patients (19%) of these patients worsened over a period of 3.3 years on average during a period of about 3 years that they were in follow up using the services facilitated by the peer educator network.

តារាងទី ₂₇៖ លទ្ធផលនៃការសិក្សាការវិវត្តនៃលទ្ធផលuACRក្នុងចំណោមអ្នកជំងឺជាសមាជិក៧០៥៦នាក់ Results of the study among 7056 patients with uACR category:

Row Labels	A_category_change	Average of Time_span_days	Years
Improved	1,052	991	**2.7**
No Change	4,667	1,000	**2.7**
Worsened	1,337	1,220	**3.3**
Grand Total	**7,056**	**1,040**	

នៅពេលយើងពិនិត្យមើលលទ្ធផល eGFR ដែលបានពីការសិក្សាចំពោះអ្នកជំងឺ ៧ ០៥៦នាក់ គឺមានដូចខាងក្រោម៖

-គ្មានការផ្លាស់ប្តូរ: អ្នកជំងឺ ៤ ២១៤ នាក់ (៦០%)
-កាន់តែអាក្រក់: អ្នកជំងឺ ២ ២៥៩ នាក់ (៣២%)
-ប្រសើរឡើង: អ្នកជំងឺ ៥៨៣ នាក់ (៨%)

ចំណែក ការរួមបញ្ចូលគ្នានៃលទ្ធផល uACR និង eGFR ដើម្បីពិនិត្យមើលការវិវត្តនៃហានិភ័យ CKD បង្ហាញថា៖

អ្នកជំងឺដែលបានវិវត្តចេញពី ក្រុមហានិភ័យពណ៌បៃតង លឿង ឬទឹកក្រូច ទៅជាក្រុមហានិភ័យពណ៌ក្រហម មានចំនួន ១ ២១៦នាក់ (១៧%) ដែលបានចាប់ផ្តើមជាមួយនឹងប្រភេទហានិភ័យមិនមែនពណ៌ក្រហម (បៃតង លឿង ឬទឹកក្រូច)នៅពេលធ្វើតេស្តមន្ទីរពិសោធន៍លើកទី១ បានប្តូរទៅក្នុងក្រុមហានិភ័យពណ៌ក្រហម តាមរយៈលទ្ធផលតេស្តមន្ទីរពិសោធន៍ចុងក្រោយរបស់ពួកគេក្នុងឆ្នាំ២០២៤។ គួរឱ្យសោកស្តាយ ប៉ុន្តែនេះគឺជាអ្វីដែលប្រព័ន្ធថែទាំសុខភាព គួរព្យាយាមជៀសវាង។

ចំនួនអ្នកជំងឺដែលនៅតែស្ថិតក្នុងប្រភេទពណ៌ក្រហម ពីការធ្វើតេស្តមន្ទីរពិសោធន៍ដំបូងគេ ហើយបានបន្តនៅក្នុងប្រភេទពណ៌ក្រហមដដែល មានចំនួន ៦៧៨នាក់ (១០%)។ អ្នកជំងឺទាំងនេះ បានស្ថិតនៅក្នុងក្រុមប្រភេទហានិភ័យពណ៌ក្រហមរយៈពេលជាមធ្យម ៨៤៣ថ្ងៃ (ប្រហែល ២.៣ ឆ្នាំ)។

សង្ខេបនៃការប្រែប្រួលហានិភ័យCKD +/- ៣ឆ្នាំ៖

- **កាន់តែអាក្រក់: អ្នកជំងឺ ២ ៥២៩ នាក់ (៣៦%)**
- **ប្រសើរឡើង: អ្នកជំងឺ ១ ០៥៦ នាក់ (១៥%)**
- **គ្មានការផ្លាស់ប្តូរ: អ្នកជំងឺ ៣ ៤៧១ នាក់ (៤៩%)**

នេះបង្ហាញថា ១/៣នៃអ្នកជំងឺ គឺបានវិវត្តកាន់តែអាក្រក់ទៅៗ ក្នុងក្របខណ្ឌនៃហានិភ័យ CKD ក្នុងរយៈពេល ៣ឆ្នាំនៃការប្រើប្រាស់សេវាថែទាំព្យាបាល គាំទ្រដោយកម្មវិធីបណ្តាញមិត្តអប់រំមិត្ត ខណៈដែល ២/៣ទៀត គឺស្ថិតក្នុងលក្ខខណ្ឌអាចគ្រប់គ្រងបាន។ ការសិក្សានេះ បានបង្ហាញពីការលំបាកក្នុងការបន្ថយល្បឿននៃការវិវត្តនៃជំងឺCKD តាមពេលវេលា។ ប៉ុន្តែបើប្រៀបធៀបជាមួយប្រព័ន្ធសុខភាពប្រទេសដទៃ លទ្ធផលនេះគឺជាលទ្ធផលល្អ ទោះបីជាវាល្អជាងបន្តិចនូវអ្វីដែលបានរកឃើញនៅសិង្ហបុរី (៣៩% កាន់តែអាក្រក់រយៈពេល២.៨ឆ្នាំ) និងល្អប្រសើរជាងអ្វីដែលត្រូវបានបោះពុម្ពផ្សាយ អំពីបញ្ហាប្រឈមនេះនៅក្នុងប្រទេសចិន។

When we look at the eGFR the progression observed of the 7056 patients is as follows:

No Change: 4,214 patients (60%)

Worsened: 2,259 patients (32%)

Improved: 583 patients (8%)

Combining results of uACR and eGFR into CKD RISK Progression shows that:

Number of patients who changed from a risk category indicated by a non-red color into a risk category with red-color; Unfortunately, there are 1,216 (17%) of patients who started with a risk category that was not red (Green, Yellow, or Orange) and transitioned to a red risk category by their final lab test. This is what a good medical care system should try to avoid.

Number of patients who remained in red color: 678 (10%) patients were already in a red risk category from their initial lab test and remained in a red risk category until their final lab test. On average, these patients remained in the red risk category for 843 days (about 2.3 years) .

Summary CKD Risk Color Change over +/- 3 years:

- **Worsened: 2,529 patients (36%)**
- **Improved: 1,056 patients (15%)**
- **No Change: 3,471 patients (49%)**

It shows that 1/3 of patients worsen in terms of CKD risk over 3 years using the services while 2/3 were controlled. It shows how challenging it is to slow down progression of CKD over time. Compared with other countries' health systems this is good result, even a slightly better outcome than what was found in Singapore (39% worsening over 2.8 years) and much better than what is being published about this challenge in China.

ការតាមដានលទ្ធផលសុខភាពនេះ គឺដោយមានការរួមបញ្ចូលលទ្ធផលពីការវិភាគទឹកនោម និងការវិភាគសំណាកឈាម និងការប្រៀបធៀបវាតាមពេលវេលា។ ការតាមដាននេះគឺមានបញ្ហាប្រឈម ប៉ុន្តែវាអាចធ្វើទៅបាន នៅពេលដែលកម្ពុជា ចាប់ផ្តើមប្រើប្រាស់កំណត់ត្រាវេជ្ជសាស្ត្រអេឡិចត្រូនិច (Electronic Medical Record) របស់ខ្លួន។

យើងមិនទាន់បានវិភាគថាតើ មន្ទីរពេទ្យណាខ្លះ និងវេជ្ជបណ្ឌិតណាខ្លះ ដែលអនុវត្តបានល្អប្រសើរក្នុងការការពារអ្នកជំងឺ ពីការវិវត្តកាន់តែអាក្រក់ទៅៗក្នុងក្របខណ្ឌនៃជំងឺ CKD នោះទេ ប៉ុន្តែនោះក៏នឹងក្លាយជាឱកាសសម្រាប់រដ្ឋាភិបាលក្នុងការតាមដាន ថាតើខ្លួនទទួលបានតម្លៃតបស្នង សម្រាប់ថវិកាដែលបានចំណាយលើ «**ការបង្ការកម្រិត២**» សម្រាប់ប្រជាជនកម្ពុជាដែរឬទេ។

Keeping an eye on this health outcome, by combining the results from urine analysis and bloodserum stample and comparing them over time, is by itself a challenge but it becomes possible once Cambodia starts to use its Electronic Medical Record.

We did not yet analyse which Hospitals and which Doctors were better at keeping patients from worsening in terms of CKD, but that is also going to be an opportunity for government to monitor if it gets value for money spent on Secondary Prevention for the Cambodian population.

ឯកសារយោង References :

- *For the global trend see article "Projecting the Population Level Burden of CKD Progression According to Urine Albumin-to-Creatinine Ratio Categories" in Kidney International Reports (2024) 9, 3464–3476 by Luca De Nicola.*

Singapore Study

- *Medical costs associated with chronic kidney disease progression in an Asian population with type 2 diabetes mellitus*
  - *Source: PubMed*
  - *URL: https://pubmed.ncbi.nlm.nih.gov/30141833/*

Chinese Studies

- *The Prevalence, Progress and Risk Factor Control of Chronic Kidney Disease in Chinese Adults With Type 2 Diabetes Mellitus in Primary Care*
  - *Source: PubMed Central*
  - *URL: https://pmc.ncbi.nlm.nih.gov/articles/PMC9226338/*
- *Aetiology of chronic kidney disease and risk factors for disease progression in Chinese subjects: A single-centre retrospective study in Beijing*
  - *Source: PubMed*
  - *URL: https://pubmed.ncbi.nlm.nih.gov/32180286/*
- *Chronic Kidney Disease and Associated Cardiovascular Risk Factors in Chinese with Type 2 Diabetes*
  - *Source: Diabetes & Metabolism Journal*
  - *URL: https://www.e-dmj.org/journal/view.php?doi=10.4093/dmj.2012.36.6.433*
- *Prevalence and Risk Factors of Chronic Kidney Disease in Patients With Type 2 Diabetes in China: Cross-Sectional Study*
  - *Source: PubMed*
  - *URL: https://pubmed.ncbi.nlm.nih.gov/39213031/*
- *Diabetes and chronic kidney disease in Chinese adults: a population-based cohort study*
  - *Source: Diabetes Research and Clinical Practice (DRC)*
  - *URL: https://drc.bmj.com/content/12/1/e003721*

ផ្នែកក្នុងអង្គភាព INTERNAL ORGANIZATION

រូបភាពទី29៖ រចនាសម្ព័ន្ធអង្គភាព របស់អង្គការ ម.ព.ជ. Organizational chart



មណ្ឌលព័ត៌មានជំងឺ (ម.ព.ជ.) គឺជាអង្គការក្រៅរាជរដ្ឋាភិបាលក្នុងស្រុកមួយ។ សកម្មភាពរបស់អង្គការគឺ មិនស្វែងរកប្រាក់ចំណេញឡើយ។ ម.ព.ជ. បានចុះបញ្ជីនៅក្រសួងមហាផ្ទៃនាថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៥។ សមាជិកក្រុមប្រឹក្សាភិបាលមិនទទួលប្រាក់ខែ ឬលាភសក្ការៈណាមួយ សម្រាប់តួនាទីរបស់ពួកគេជាអ្នកអភិបាល និងតាមដានលើសកម្មភាពរបស់អង្គការឡើយ។ ប្រធានក្រុមប្រឹក្សាភិបាលបានផ្ទេរភារកិច្ចគ្រប់គ្រង និងដឹកនាំសកម្មភាពរបស់អង្គការទៅឱ្យអនុប្រធានដែលជានាយកប្រតិបត្តិអង្គការ រៀងរាល់២ឆ្នាំម្តង។

ឆ្នាំ២០២៥ មានបុគ្គលិកទទួលប្រាក់ខែចំនួន ៤០នាក់។ នាយកប្រតិបត្តិអង្គការ គ្រប់គ្រងដឹកនាំផ្នែកទាំង៤របស់អង្គការរួមមាន៖ រដ្ឋបាលនិងហិរញ្ញវត្ថុ ផ្នែកមូលនិធិឱសថបង្វិលទុន ផ្នែកកម្មវិធីបណ្តាញមិត្តអប់រំមិត្ត និងផ្នែកគ្រប់គ្រងទិន្នន័យនិងប្រព័ន្ធព័ត៌មានវិទ្យា ដូចរូបខាងលើ។ នៅតាមសហគមន៍ អង្គការ ម.ព.ជ. មានអ្នកជំងឺស្ម័គ្រចិត្តចំនួន ១៩២នាក់ មានតួនាទីជាមិត្តអប់រំមិត្តដែលទទួលបានប្រាក់លើកទឹកចិត្តប្រចាំខែ និងប្រាក់ឧបត្ថម្ភលើសកម្មភាពរបស់ពួកគេ។

MoPoTsyo is a Cambodian not for profit and non governmental organization. It officially registered in Ministry of Interoir on 29 July 2005. The Board members are not remunerated or reimbursed for their work as supervisors. The Board Director has delegated the management of the NGO to the Vice Director of the Board (CEO of NGO) for the period of two years. This delegation is so far being renewed every two years.

In 2025, there were 40 employees are salaried. The CEO manages 4 departments: Finance & Administration, Revolving Drug Fund, Program Department, and IT Department as shown above. At Operational Districts, MoPoTsyo has 192 volunteer peer educators received reimbursements of their costs for their activities.

ទិន្នន័យរបស់បណ្តាញមិត្តអប់រំមិត្តនីមួយៗ DETAILED STATISTICS PER PEER NETWORK

តំបន់ក្រីក្រនៅភ្នំពេញ THE URBAN POOR AREAS

បណ្តាញមិត្តអប់រំមិត្ត PE NETWORKS

កំណើនសមាជិកភាព៖ គិតត្រឹមឆ្នាំ២០២៥ មានអ្នកជំងឺចុះឈ្មោះជាមួយមិត្តអប់រំមិត្តក្នុងទីក្រុងចំនួន ១១៤៨៨នាក់ ជាអ្នកមានជំងឺទឹកនោមផ្អែម និង១៤៨៨នាក់ ជាអ្នកមានជំងឺលើសសម្ពាធឈាមគ្មានទឹកនោមផ្អែម។ វាបានកើនឡើងជាបន្តបន្ទាប់នៅទីក្រុងភ្នំពេញ។ ក្នុងចំនោមសមាជិកចុះឈ្មោះទាំងអស់ មាន ៧៤៥នាក់មានអក្សរកូដ PX ដែលមានន័យថា ពួកគេមិនមែនប្រជាជនរស់នៅតំបន់ក្រីក្រ តែជាអ្នកជំងឺដែលមកពីក្រៅតំបន់។

Membership Growth: at the end of 2025, there are 11,488 people with Diabetes and other 1,488 people with hypertension registered with PEs in Phnom Penh; it has gradually increased every year. Among them, there are 745 patients with code PX, which means they are not resident of the slum areas.

រូបភាពទី30៖ចំនួនសមាជិកទឹកនោមផ្អែមថ្មីដែលបានចុះឈ្មោះក្នុងបណ្តាញមិត្តអប់រំមិត្តតាមតំបន់ក្នុងទីក្រុង Accumulative DM patients registered in PE network in urban program



រូបភាពទី31៖ចំនួនសមាជិកលើសសម្ពាធឈាមដែលបានចុះឈ្មោះក្នុងបណ្តាញមិត្តអប់រំមិត្តតាមតំបន់ក្នុងទីក្រុង Accumulative HBP patients registered in PE network in urban program



ចំនួនសមាជិកបានកើនឡើងជារៀងរាល់ឆ្នាំ នៅគ្រប់តំបន់មានមិត្តអប់រំមិត្តតាមសហគមន៍ និងមណ្ឌលសុខភាពគ្របដណ្តប់ដែលមានមិត្តអប់រំមិត្តនៅរាជធានីភ្នំពេញ។ ចុងក្រោយបំផុតនៃការពង្រីកបណ្តាញគឺឆ្នាំ២០២៣ អង្គការ ម.ព.ជ. បានចុះអនុស្សារណៈនៃកិច្ចព្រមព្រៀងរៀបចំបណ្តាញមិត្តអប់រំមិត្តជាមួយការិយាល័យសុខាភិបាល មេគង្គ។ នៅក្នុងឆ្នាំ២០២៥នេះ យើងរក្សាបានមិត្តអប់រំមិត្តនៅចំនួន១៣នាក់ដដែល។

The total number of registered members has been increasing every year in all community areas and health center areas with peer educator. The latest expansion was in 2023, MoPoTsyo had signed an agreement with Mekong Operational District. During 2025, MoPoTsyo had kept all 13 urban peers active.

រូបភាពទី32៖ សមាជិកតាមដានធៀបនឹងចុះឈ្មោះ Trends of urban cohort in follow-up compared to registration



យើងចាប់ផ្តើម កត់ត្រាទិន្នន័យតាមដានអ្នកជំងឺក្នុងប្រព័ន្ធទិន្នន័យចាប់ពីឆ្នាំ២០១០ ដើម្បីស្វែងយល់អំពីចំនួនអ្នកជំងឺដែលបានចុះឈ្មោះ ហើយបាននឹងកំពុងនៅតាមដានបន្តជាមួយបណ្តាញមិត្តអប់រំមិត្ត នៅក្នុងក្រុងភ្នំពេញ។ ជាទូទៅប្រជាជននៅតាមតំបន់សហគមន៍ក្នុងទីក្រុង គឺមានការផ្លាស់ប្តូរលំនៅ ឬប្រែប្រួលខ្លាំង បើធៀបជាមួយប្រជាជននៅតាមជនបទ។ វាជាហេតុដែលចំនួនអ្នកជំងឺដែលបានចុះឈ្មោះហើយ តែមិនតាមដានបន្តជាមួយកម្មវិធីក៏ច្រើនដែរ។ នៅដំណាច់ឆ្នាំ២០២៥ បានបង្ហាញថា ក្នុងចំណោមអ្នកចុះឈ្មោះសរុបចំនួន ១២ ៨៤៨នាក់ មានអ្នកនៅតាមដានជាមួយមិត្តអប់រំមិត្តធ្លាក់ចុះខ្លាំងគឺ នៅត្រឹមតែ ៥១៣២ នាក់ប៉ុណ្ណោះ។

MoPoTsyo started to enter the follow up data of the members in database since 2010 to track the number of registered patients being followed-up by the PEs in urban coverage areas. Generally, compared to patients from rural areas, the patients living in the slums were dynamic: they moved in and out constantly; it may be a reason that many patients registered but didn't do follow-up with the program regularly. By the end of 2025, there were only 5,132 of 12,848 patients in follow-up with the program.

រូបភាពទី33៖ បំរែបំរួលនៃការតាមដានរបស់អ្នកទឹកនោមផ្អែមធៀបនឹងចំនួនចុះឈ្មោះ តាមឆ្នាំនីមួយៗ Trends of urban cohort of patients with DM in follow-up comparing to registration



អ្នកជំងឺទឹកនោមផ្អែមចំនួន៤៦៣៧នាក់ ក្នុងចំណោមអ្នកជំងឺ១១៤៨៨នាក់ដែលមានឈ្មោះក្នុងប្រព័ន្ធទិន្នន័យ កំពុងតាមដានបន្ត ជាមួយមិត្តអប់រំមិត្តក្នុងទីក្រុងភ្នំពេញ។ តាមរយៈតារាងខាងលើបង្ហាញថា ចំនួនតាមដានបានធ្លាក់ចុះជាងឆ្នាំ២០២៥ កន្លងទៅ ទោះបីជាមានសមាជិកថ្មីបន្តចុះឈ្មោះបន្ថែមក៏ដោយ។

There were 4,637 out of 11,488 registered DM patients who continued going for using any service of PEs in urban areas. The graph above shows that the number of active member decreased even though there were hundreds of new registered members were included.

ការប្រើប្រាស់សេវា USE OF SERVICES

សេវាមន្ទីរពិសោធន៍ LABORATORY SERVICE

ចំនួននៃការប្រើសេវាដោយសមាជិក ជាអ្នកជំងឺលើសសម្ពាធឈាមមិនមានការប្រែប្រួលទេ ខណៈដែលចំនួននៃការប្រើប្រាស់សេវាជាអ្នកជំងឺទឹកនោមផ្អែមមានការកើនឡើង ដែលជំរុញអោយចំនួនសរុបនៃការប្រើប្រាស់សេវាមានការកើនឡើងប្រហែល៦% នៅឆ្នាំ២០២៥។ កូវីដ-១៩ បានជម្រុញឱ្យយើងសម្រេចបញ្ចប់ការប្រមូលសំណាកឈាម និងទឹកនោម នៅទីតាំងការិយាល័យ កណ្តាលនៅក្នុងឆ្នាំ ២០២១ ដោយផ្ទេរការប្រមូលសំណាកនេះ ទៅធ្វើតាមមណ្ឌលសុខភាព និងមន្ទីរពេទ្យរដ្ឋដែលជាដៃគូហើយយើងបានបន្តធ្វើរបៀបនេះ រហូតដល់ឆ្នាំ២០២៥នេះ។

ក្នុងឆ្នាំ២០២៥ លទ្ធផលមន្ទីរពិសោធន៍សរុបចំនួន ៦.០៩៦ដង ធ្វើដោយសមាជិក ៣.២៧៤នាក់ មានក្នុងមូលដ្ឋានទិន្នន័យរបស់យើង។ ក្នុងនោះជំងឺទឹកនោមផ្អែមចំនួន ៥.៦៤៨ដង (៣.០២២នាក់) និងជំងឺលើសសម្ពាធឈាមគ្មានទឹកនោមផ្អែមមានត្រឹមចំនួន ៤៤៨ដង (២៥២នាក់)។

ក្នុងស្រុកប្រតិបត្តិពោធិ៍សែនជ័យ ការប្រមូលវត្ថុវិភាគមាននៅមណ្ឌលសុខភាពសាមគ្គី ១ដងក្នុងមួយខែ មណ្ឌលសុខភាពកន្ទោក ១ដងក្នុងមួយខែ ចំណែកនៅមណ្ឌលសុខភាពដំណាក់ត្រយឹង ចំនួន ២ដងក្នុងមួយខែ និងនៅមន្ទីរពេទ្យបង្អែកពោធិ៍ចិនតុង រៀងរាល់ថ្ងៃពុធ និងសុក្រ។ ក្នុងស្រុកប្រតិបត្តិសែនសុខ គឺធ្វើនៅរាល់ថ្ងៃចន្ទ ក្នុងមន្ទីរពេទ្យបង្អែកមិត្តភាពកម្ពុជា-ចិន សែនសុខ។

បណ្តាញមិត្តអប់រំមិត្ត បានពង្រីកទៅកាន់ស្រុកប្រតិបត្តិមេគង្គនៅក្នុងខែធ្នូ ឆ្នាំ២០២៣ ហើយជាស្រុកប្រតិបត្តិចុងក្រោយដែលបណ្តាញមិត្តអប់រំមិត្តបានពង្រីកទៅដល់ គិតមកដល់បច្ចុប្បន្ននេះ។ ទាំងសេវាមន្ទីរពិសោធន៍ សេវាពិគ្រោះជំងឺ និងសេវាមូលនិធិឱសថបង្វិលទុន ត្រូវបានរៀបចំឡើងនៅមន្ទីរពេទ្យបង្អែកសម្តេចឪ សម្តេចម៉ែ។ ការបូមឈាមធ្វើតេស្តមន្ទីរពិសោធន៍គឺធ្វើឡើងម្តងក្នុងមួយខែ។

The number of lab profiles made by Hypertensive patients has slightly increased while the total number of lab profiles has decreased. There was the total decrease of about 8% in 2024. Due to Covid-19 high spread in community in 2021, we decided to stop collecting blood and urine samples at our head quarters and transferred it entirely to the health centers and hospitals we are working with. This model of sample collection has continued in 2025.

In 2025, a total number of 6,096 lab profiles belonging to 3,274 urban members are in our database. The total lab profiles of 5,648 profiles were from 3,022 people with diabetes, and 448 profiles were from 252 people with non-diabetic hypertension.

In Por Senchey OD, sample collections take place once a month at Samaky and Kantok Health Centers and twice a month at Domnak Troyeung Health Center. And on Wednesdays and Friday at Pochentong Referral Hospital. In Sen Sok OD, it does on every Monday at Sen Sok Cambodia-China Friendship Referral Hospital.

Peer educator network expanded to Mekong OD in December 2023. Services including sample collection for lab test, consultation and Revolving Drug Fund are available at Samdech Euv Samdech Me Referral Hospital. Sample collection activities are scheduled to take place once a month.

តារាងទី 28៖ ការប្រើសេវាមន្ទីរពិសោធន៍ដោយសមាជិកនៅទីក្រុង Use of laboratory service by urban PE network

ទំហំនៃការប្រើសេវាមន្ទីរពិសោធន៍តាមប្រភេទជំងឺប្រចាំឆ្នាំ			
Yearly Use of Lab Service			
នៅតំបន់ក្នុងទីក្រុងតាមឆ្នាំនីមួយៗ	*ទំហំនៃការប្រើសេវា*	*ទឹកនោមផ្អែម*	*អ្នកលើសសម្គាជឈាមគ្មានទឹកនោមផ្អែម*
2008-2009	24	24	0
2010	457	444	13
2011	441	423	18
2012	1063	1005	58
2013	1377	1284	93
2014	1833	1722	111
2015	1985	1849	136
2016	1967	1846	121
2017	2520	2368	152
2018	3550	3324	226
2019	3511	3232	279
2020	4874	4487	387
2021	3148	2942	206
2022	4965	4521	444
2023	6253	5837	416
2024	5745	5297	448
2025	**6096**	**5648**	**448**

សេវាពិគ្រោះជំងឺ Consultation Service

រយៈពេល ១២ខែក្នុងឆ្នាំ២០២៥ មានករណីពិគ្រោះជំងឺសរុបរួមគ្នាចំនួន៧៣៨២ដង ពីមន្ទីពេទ្យបង្អែកពោធ៍ចិនតុង មន្ទីរពេទ្យបង្អែកមិត្តភាពកម្ពុជាចិន-សែនសុខ មណ្ឌលសុខភាពសាមគ្គី មណ្ឌលសុខភាពកន្ទោក និងពីមន្ទីរពេទ្យបង្អែកសម្តេចឪ-សម្តេចម៉ែ។ ការពិគ្រោះធ្វើឡើងដោយវេជ្ជបណ្ឌិតមូលដ្ឋាន ដែលបានទទួលការបណ្តុះបណ្តាលបន្ថែម។ មានអ្នកជំងឺប្រើសេវាចំនួន ២៨៩១នាក់ ក្នុងការណាត់ជួបចំនួន២២៩វេន។ ប្រសិនបើយើងគិតចំនួនពិគ្រោះជាមធ្យមក្នុងចំណោមទីតាំងពិគ្រោះទាំង៥នៅទីក្រុង នោះយើងទទួលបានអ្នកជំងឺ៣២ករណីក្នុងមួយវេនពិគ្រោះ។ ចំនួននេះគឺបានធ្លាក់ចុះពីចំនួន ៣៦នាក់ក្នុងមួយវេននៅឆ្នាំ២០២៤។

During 12 months in 2025, There were totally 7,382 consultations from the Pochentong RH, Anlong Kangan HC, Samaki HC, Kantaok HC, and lastly from the RH Samdech Ov Samdech Mae together. These consultations were provided by the local medical trained doctors. There were totally 2,891 individually registered patients used 229 sessions. In average, there were 32 consultations per session in 2025, This number is lower than in 2024 which consisted of 36 patients per session.

រូបភាពទី34៖ ការប្រើប្រាស់សេវាពិគ្រោះ របស់សមាជិក នៅតាមតំបន់ទីក្រុង Registered members used medical consultation at Public Health Facilities in Urban



ចំនួនជាមធ្យមនៃវេជ្ជបញ្ជាទីមួយ ប្រចាំខែក្នុងតំបន់ទីក្រុងនៅឆ្នាំ២០២៥ គឺប្រមាណ ៥៩ករណី។ ករណីនេះ រួមមានទាំងអ្នកជំងឺក្រៅតំបន់បន្តចុះឈ្មោះជាសមាជិកបណ្តាញ ទោះបីជា អ្នកជំងឺទាំងនោះមិនរស់នៅអចិន្ត្រៃយ៍ក្នុងសហគមន៍ ឬមណ្ឌលសុខភាពដែលមានមិត្តអប់រំមិត្តក៏ដោយ ប៉ុន្តែជាអ្នកដែលចង់បានសេវា។

The average number of monthly “first prescriptions” in the urban area in 2025 was 59 cases. Still, there were some people with diabetes to become member although they do not live inside the areas covered by peer educators but who want to use the services.

រូបភាពទី35៖ ការវិភាគនៃវេជ្ជបញ្ជាទីមួយជាមធ្យមប្រចាំខែតាមឆ្នាំនីមួយៗ Monthly AVG first prescriptions



តាមរូបភាពខាងលើនេះ អាចបញ្ជាក់ថា ចំនួនមធ្យមអ្នកជំងឺថ្មីទទួលសេវាពិគ្រោះប្រចាំខែសម្រាប់កម្មវិធីក្នុងទីក្រុង បានបន្តធ្លាក់ចុះគួរឱ្យកត់សម្គាល់នៅក្នុងឆ្នាំ២០២៥នេះ។

The above graph shows that the the average of monthly number of first prescriptions has decreased continuously in 2025.

ឱសថបង្វិលទុន និងការអនុវត្តតាមវេជ្ជបញ្ជា PHARMACY RDF AND ADHERENCE TO PRESCRIPTION

នៅតំបន់ក្នុងទីក្រុង យើងបាននឹងកំពុងដាក់ឱ្យដំណើរការសេវាឱសថបង្វិលទុននៅឱសថស្ថានចំនួន ៦កន្លែង។ ហើយ ៥ទីតាំងស្ថិតក្នុងសេវាសាធារណៈគឺ ស្ថិតក្នុងមន្ទីរពេទ្យបង្អែកមិត្តភាពកម្ពុជាចិនសែនសុខ មណ្ឌលសុខភាពសាមគ្គី មណ្ឌលសុខភាពកន្ទោក មន្ទីរពេទ្យបង្អែកពោធ៍ចិនតុង និងមន្ទីរពេទ្យបង្អែកសម្តេចឪ-សម្តេចម៉ែ ដែលបានបង្កើតឡើងតាំងពីចុងឆ្នាំ ២០២៣។ ចំពោះអ្នកចែកចាយឱសថ គឺជាបុគ្គលិកមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែកជាអ្នកផ្តល់សេវា ស្របតាមកិច្ចព្រមព្រៀងរវាង ម.ព.ជ. និងមូលដ្ឋានសុខាភិបាលនីមួយៗ។ ចំណែក ១ទីតាំងទៀត គឺជាដៃគូឱសថ ស្ថានឯកជន។

In urban areas, there are 6 pharmacies that are dispensing revolving drug fund medicines for our registered members. 5 out of 6 are public pharmacies located in Sen Sok Cambodia-China Friendship RH, Kantaok Health Post, Samaki HC, Por Chentong RH and Samdach Ov Samdach Mea RH that set up at the end of years 2023. Health staffs responded for dispensing medicine according to the contract between the health facilities and MoPoTsyo. Another partner is a private parmacy.

តារាងទី 29៖ ទំហំនៃការប្រើសេវាឱសថបង្វិលទុន តាមតំបន់ក្នុងទីក្រុង RDF use in urban slums

ល.រ No.	ឈ្មោះឱសថស្ថានដៃគូ Name of Partner Phamacy	តម្លៃផ្គត់ផ្គង់ដល់ឱសថស្ថានដៃគូនៅឆ្នាំ២០២៥ Value of Supply to Partner Phamacy(s) in 2025	ចំនួនទឹកប្រាក់ក្នុងវិក្កយបត្របានបញ្ចូលនៅក្នុងមូលដ្ឋានទិន្នន័យ Amount from returned invoices for entry in data base	ចំនួនវិក្កយបត្រក្នុងមូលដ្ឋានទិន្នន័យ Number of Invoices in Database	ចំនួនទឹកប្រាក់ជាមធ្យមក្នុងមួយវិក្កយបត្រ Average Per Invoice	ចំនួនទឹកប្រាក់នៅតែមិនទាន់បញ្ចូល Amount with no invoices in databse	ចំនួនប៉ាន់ស្មាននៃវិក្កយបត្រដែលបាត់ Estimated Number of Missing Invoices	ភាគរយនៃអ្នកជម្ងឺដែលគ្មានវិក្កយបត្រ Percentage of Patients Without Invoices
1	ឱសថស្ថានដៃគូរ និរោធន៍	392,132,916	491,642,890	11,269	43,628	(99,509,974)	(2,281)	-25.38%
2	មន្ទីរពេទ្យបង្អែកមិត្តភាពកម្ពុជា-ចិនសែនសុខ	141,897,737	156,315,580	3,451	45,296	(14,417,843)	(318)	-10.16%
3	មន្ទីរពេទ្យបង្អែក ពោធិ៍ចិនតុង	235,696,504	260,562,730	5,826	44,724	(24,866,226)	(556)	-10.55%
4	មណ្ឌលសុខភាព សាមគ្គី	31,186,344	34,290,030	976	35,133	(3,103,686)	(88)	-9.95%
5	មណ្ឌលសុខភាព កន្ទោក	54,283,590	59,837,400	2,238	26,737	(5,553,810)	(208)	-10.23%
6	មន្ទីរពេទ្យបង្អែកសម្តេចឪ សម្តេចម៉ែ	17,538,898	20,624,170	683	30,196	(3,085,272)	(102)	-17.59%

តារាងខាងលើនេះ គឺជាទំហំនៃការផ្គត់ផ្គង់ឱសថទៅកាន់ឱសថស្ថានដៃគូទាំងប្រាំមួយ ស្ថិតនៅទីក្រុងភ្នំពេញ។ ក្នុងឆ្នាំ២០២៥ យើងសង្កេតឃើញថា តម្លៃថ្នាំផ្គត់ផ្គង់ទៅឱសថស្ថានដៃគូ គឺទាបជាង បើធៀបជាមួយនឹងតម្លៃក្នុងបង្កាន់ដៃបង់ភាគទានរបស់អ្នកជំងឺ។ នេះបញ្ជាក់ពីភាពល្អប្រសើរនៃការគ្រប់គ្រងវិក្កយបត្រតាមរយៈការចែកចាយឱសថតាមប្រព័ន្ធAutosystem ។

The table above shows the volumes of medicine supplied to the 6 contracted pharmacies in urban areas. In 2025, the volume of RDF supply from MoPoTsyo has decreased. However, the comparison of the value of supplied was more of less the same to the value of medicines dispensed for all locations.

ចំពោះការអនុវត្តតាមវេជ្ជបញ្ជាក្នុងការប្រើឱសថ បានបង្ហាញនូវអត្រា ៧២% សម្រាប់អ្នកជំងឺទឹកនោមផ្អែម និង ៦៨%សម្រាប់អ្នកជំងឺលើសសម្ពាធឈាម។ ក្នុងឆ្នាំ២០២៥ គុណភាពនៃទិន្នន័យវិក្កយបត្រ និងវេជ្ជបញ្ជាមានភាពល្អប្រសើរ ដោយសារចំនួនវិក្កយបត្របាត់ត្រូវបានកាត់បន្ថយ ខណៈដែលសុក្រិតភាពនៃវិក្កយបត្រមានភាពល្អប្រសើរ។ ហេតុនេះ ភាពល្អៀងក្នុងការគណនាការអនុវត្តតាមវេជ្ជបញ្ជា (bias in calculation the adherence)គឺមានកម្រិតទាបជាង។

The adherence to prescriptions shows 72% amon g patients with diabetes, and 68% among patients with non-diabetes hypertension. In 2025, the data of invoices was good because most of times the dispensors used autosystem. This caused the number of lost receipts to become reduced while accuracy of invoices became better. As result, the calucation bias of the adherece became smaller.

តារាងទី 30៖ ការអនុវត្តតាមវេជ្ជបញ្ជាអ្នកជំងឺទឹកនោមផ្អែមតាមតំបន់ទីក្រុង Medication Adherence by DM members in slums

Adherence at Phnom Penh

% adherence by DM	The DM patients should have spent if 100% adherent	Year	Riels spent by Diabetics on medication	Riels average per actual buying DM	Nr of Actual DM Buyers	Nr of times they bought
72%	1,312,777,189	**2025**	945,540,965	281,914	3,354	21,917

% adherence by HBP	The HBP patients should have spent if 100% adherent	Year	Riels spent by HBP on medication	Riels average per actual buying HBP	Nr of Actual HBP Buyers	Nr of times they bought
68%	50,633,770	**2025**	34,679,985	145,105	239	1,256

Nr. of buyer by sex	**Female**	**52%**	**1,883**
	Male	**48%**	**1,710**
	Total	**100%**	**3,593**

ខាងក្រោមនេះ ជាតារាងបង្ហាញនូវប្រាក់លើកទឹកចិត្ត សម្រាប់ការចែកចាយឱសថបង្វិលទុននៅតាមមូលដ្ឋានសុខាភិបាលសាធារណៈទាំងអស់ក្នុងរាជធានីភ្នំពេញនៅឆ្នាំ២០២៥។ សម្រាប់ឆ្នាំនេះ ចំនួនថេរវេលានៃការបែងចែកប្រាក់លើកទឹកចិត្តនៅមណ្ឌលសុខភាពកន្ទោក គឺវែងជាងគេ ដោយមូលហេតុថា មណ្ឌលសុខភាពនេះ បានបញ្ចប់កិច្ចព្រមព្រៀងនៃការចែកចាយឱសថមូលនិធិបង្វិលទុន ត្រឹមថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៥ តែម្តង។

The following tables show the rewards for 2025 for all public pharmacies in Phnom Penh who partnered with RDF. This is the period of the rewards for Kantoak health center was longer than the others because the partner decided to end the contract of dispensing RDF by 25 October 2025; however, the heath center could order some RDF medicines in case there was a gap of CMS's medicines supply.

តារាងទី 31៖ ការផ្តល់ប្រាក់រង្វាន់ដល់អ្នកចូលរួមចែកចាយថ្នាំតាមតំបន់ក្នុងទីក្រុង *Rewards for public health facility pharmacies in urban*

គណនាប្រាក់លើកទឹកចិត្តសំរាប់ការចែកចាយថ្នាំក្នុងស្រុកប្រតិបត្តិរោងៈសែនជ័យ

គិតចាប់ពី ថ្ងៃទី០១ ខែ កក្កដា ឆ្នាំ២០២៤ ដល់ ថ្ងៃទី ៣១ ខែ សីហា ២០២៥ សំរាប់មន្ទីរពេទ្យបង្អែក រោងៈចិនតុង

		ឆ្នាំទី១	ឆ្នាំទី2	ឆ្នាំទី3	ឆ្នាំទី4	ឆ្នាំទី5	ឆ្នាំទី6	ឆ្នាំទី7	ឆ្នាំទី8	ឆ្នាំទី9	
		01-07-2016 to 30-06-2017	01-07-2017 to 30-06-2018	01-07-2018 to 01-06-2019	01-07-2019 to 30-06-2020	01-07-2020 to 30-06-2021	01-07-2021 to 30-06-2022	01-07-2022 to 30-06-2023	01-07-2023 to 30-06-2024	01-07-2024 to 31-12-2024	01-01-2025 to 31-08-2025
	A	B									
ល.រ	**សូចនាករ**										
១	ចំនួនទឹកប្រាក់សរុបដែលអ្នកជំងឺគួរតែបង់សម្រាប់សេវាឱសថនៅក្នុងស្រុកប្រតិបត្តិ រោងៈសែនជ័យ Value of the amount that patients should pay for the medicine in OD Posenchey	574,086,271 ៛	672,233,951 ៛	859,510,286 ៛	946,089,224 ៛	1,056,219,706 ៛	1,040,477,049 ៛	1,395,917,613 ៛	1,226,052,743 ៛	Not Calculated	789,256,569 ៛
២	ចំនួនទឹកប្រាក់សរុបដែលអ្នកជំងឺបានបង់សម្រាប់សេវាឱសថនៅក្នុងស្រុកប្រតិបត្តិ រោងៈសែនជ័យ Value of the amount that patients paid for the medicine in OD Posenchey	390,237,000 ៛	487,144,465 ៛	605,216,680 ៛	742,963,270 ៛	826,475,450 ៛	871,660,330 ៛	1,233,186,926 ៛	781,982,573 ៛	Not Calculated	566,339,117 ៛
៣	ចំនួនអ្នកជម្ងឺដែលបានមកទទួលសេវាឱសថនៅមន្ទីរពេទ្យបង្អែក រោងៈចិនតុង Number of cases who come to use medical sevice in Pochentong RH	486 នាក់	1170 នាក់	1269 នាក់	1393 នាក់	1295 នាក់	731 នាក់	1353 នាក់	1308 នាក់	1138 នាក់	1172 នាក់
៤	ចំនួនអ្នកជម្ងឺដែលប្រើប្រាស់អាំងស៊ុយលីន នៅភ្នំពេញ Number of cases use Insulin in Phnom Penh	245 នាក់	269 នាក់	332 នាក់	411 នាក់	420 នាក់	431 នាក់	555 នាក់	485 នាក់	390 នាក់	305 នាក់
៥	ចំនួនអ្នកជម្ងឺដែលប្រើប្រាស់អាំងស៊ុយលីន នៅមន្ទីរពេទ្យបង្អែករោងៈចិនតុង Number of cases use Insulin in Pochentong RH	61 នាក់	123 នាក់	163 នាក់	196 នាក់	194 នាក់	100 នាក់	187 នាក់	160 នាក់	144 នាក់	120នាក់
៦	ចំនួនទឹកប្រាក់សរុបដែលអ្នកជំងឺបានបង់សំរាប់សេវាឱសថនៅឱសថស្ថានមន្ទីរពេទ្យបង្អែក រោងៈចិនតុង Value of the amount that patients paid for the medicine in Pochentong RH	104,418,650 ៛	167,426,905 ៛	236,135,610 ៛	270,160,200 ៛	221,742,180 ៛	102,606,900 ៛	258,930,444 ៛	358,354,409 ៛	118,688,286 ៛	335,359,450 ៛
៧	ចំនួនទឹកប្រាក់សរុបដែល ម.ព.ជ. ផ្គត់ផ្គង់ទៅមន្ទីរពេទ្យបង្អែក រោងៈចិនតុង Value of supply to Pochentong RH	117,358,000 ៛	186,732,500 ៛	236,946,000 ៛	274,088,500 ៛	193,667,100 ៛	104,159,400 ៛	291,114,091 ៛	350,048,435 ៛	120,189,799 ៛	329,798,851 ៛
៨	សរុបចំនួនឱសថចាក់អាំងស៊ុយគិតជាដបដែលអង្គការ ម.ព.ជ. ផ្គត់ផ្គង់ទៅមន្ទីរពេទ្យបង្អែក រោងៈចិនតុង Total of quantity of insulin as of Vial/10ml that MoPoTsyo supply to RH Pochentong								1,146 ដប	660ដប	1048 ដប
៩	សរុបចំនួនឱសថគ្រាប់ដែលអង្គការ ម.ព.ជ. ផ្គត់ផ្គង់ទៅមន្ទីរពេទ្យបង្អែកមន្ទីរពេទ្យបង្អែក រោងៈចិនតុង Total quantity of tablets that MoPoTsyo supplies to RH Pochentong								1,482,786 គ្រាប់	889,600គ្រាប់	1,179,590 គ្រាប់
១០	ប្រាក់លើកទឹកចិត្តអតិបរមា (=B៦*15%) Maximum reward	15,662,798 ៛	25,114,036 ៛	35,420,342 ៛	40,524,030 ៛	33,261,327 ៛	15,391,035 ៛	38,839,567 ៛	38,753,161 ៛	17,803,243 ៛	50,303,917 ៛
១១	ចំនួនភាគរយដែលអ្នកជម្ងឺបានទិញថ្នាំតាមវេជ្ជបញ្ជា (=B៧/B៩) Adherence %	68%	72%	70%	79%	78%	84%	88%	64%	63.78%	71.76%
១២	លទ្ធផលវាយតំលៃលើការិយាបថអ្នកចែកចាយថ្នាំ Satisfaction result	87%	89%	86%	93%	90%	93%	90%	90%	90.20%	90.84%
១៣	ចំនួនភាគរយនៃប្រាក់លើកទឹកចិត្តដែលត្រូវបែងចែកដល់ឱសថស្ថាន (=(B៩៩+B៩២)/2) Average reward	77%	81%	78%	86%	84%	88%	89%	77%	76.99%	81.30%
១៤	ប្រាក់លើកទឹកចិត្តសរុបដែលត្រូវបែងចែកដល់ឱសថស្ថានមន្ទីរពេទ្យបង្អែក រោងៈចិនតុង(=B៩០*B៩៣) Available reward for Pochentong RH	12,132,820 ៛	20,275,378 ៛	27,754,340 ៛	34,657,557 ៛	27,992,473 ៛	13,605,295 ៛	34,613,263 ៛	29,836,197 ៛	13,707,717 ៛	40,896,084 ៛
15a	ប្រាក់លើកទឹកចិត្តសរុបដែលត្រូវបែងចែកដល់ឱសថស្ថានមន្ទីរពេទ្យបង្អែក រោងៈចិនតុង ក្រោយដកពន្ធកាត់ទុក ១៥% (=១៥*៨៥%) Available reward for Pochentong RH extracted WHT15%							29,421,274 ៛	25,360,767 ៛	11,651,559 ៛	34,761,672 ៛
15b	ប្រាក់លើកទឹកចិត្តសរុបដែលត្រូវបែងចែកដល់ឱសថស្ថានមន្ទីរពេទ្យបង្អែក រោងៈចិនតុង **០១ ខែ កក្កដា ឆ្នាំ២០២៤ ដល់ ថ្ងៃទី ៣១ ខែ សីហា ២០២៥** ក្រោយដកពន្ធកាត់ទុក១៥% Total Available Reward from 01/07/2024 to 30/06/2025 after 15% WHT Deduction									46,413,231 ៛	
	ការចែងចែកប្រាក់លើកទឹកចិត្តដល់អ្នកពាក់ព័ន្ធសំរាប់ការចែកចាយថ្នាំក្នុងមន្ទីរពេទ្យបង្អែក រោងៈចិនតុង										
១៦	មន្ទីរសុខាភិបាលរាជធានីភ្នំពេញ for PHD (=B៩៥*1%)	121,328 ៛	202,754 ៛	277,543 ៛	346,576 ៛	279,925 ៛	136,053 ៛	294,213 ៛	253,608 ៛	464,132 ៛	
១៧	ស្រុកប្រតិបត្តិ for OD (=B៩៥*4%)	485,313 ៛	811,015 ៛	1,110,174 ៛	1,386,302 ៛	1,119,699 ៛	544,212 ៛	1,176,851 ៛	1,014,431 ៛	1,856,529 ៛	
១៨	វេជ្ជបណ្ឌិតពិគ្រោះជំងឺ for the Doctor (=B៩៥*30%)	1,819,923 ៛	6,082,613 ៛	8,326,302 ៛	10,397,267 ៛	8,397,742 ៛	4,081,589 ៛	8,826,382 ៛	7,608,230 ៛	13,923,969 ៛	
១៩	ប្រាក់លើកទឹកសំរាប់មន្ទីរពេទ្យ Incentive for the Hospital (=B៩៥*15%)	2,426,564 ៛	3,041,307 ៛	4,163,151 ៛	5,198,634 ៛	4,198,871 ៛	2,040,794 ៛	4,413,191 ៛	3,804,115 ៛	6,961,985 ៛	
២០	អ្នកចែកចាយថ្នាំនិងអ្នកចូលរួមចែកចាយថ្នាំ for the Pharmacists (=B៩៥*50%)	7,279,692 ៛	10,137,689 ៛	13,877,170 ៛	17,328,779 ៛	13,996,237 ៛	6,802,648 ៛	14,710,637 ៛	12,680,384 ៛	23,206,615 ៛	

គណនាប្រាក់លើកទឹកចិត្តសំរាប់ការចែកចាយថ្នាំភ្នុចស្រុកប្រតិបត្តិពោធិ៍សែនជ័យ
គិតចាប់ពី ថ្ងៃទី០១ ខែ កក្កដា ឆ្នាំ២០២៤ ដល់ ថ្ងៃទី ៣១ ខែ សីហា ២០២៥
សំរាប់មណ្ឌលសុខភាព សាមគ្គី

		ឆ្នាំទី១	ឆ្នាំទី២	ឆ្នាំទី៣	ឆ្នាំទី៤	ឆ្នាំទី៥	ឆ្នាំទី៦	
		01-07-2019 to 30-06-2020	01-07-2020 to -30-06-2021	01-07-2021 to -30-06-2022	01-07-2022 to -30-06-2023	01-07-2023 to -30-06-2024	**01-07-2024 to 31-12-2024**	**01-01-2025 to 31-08-2025**
	A				B			
លរ	**សូចនាករ**							
១	ចំនួនទឹកប្រាក់សរុបដែលអ្នកជំងឺគួរតែបង់សម្រាប់សេវាឱសថនៅក្នុងស្រុកប្រតិបត្តិ ពោធិ៍សែនជ័យ Value of the amount that patients should pay for the medicine in OD Posenchey	946,089,224 ៛	1,056,219,706 ៛	1,040,477,049 ៛	1,395,917,613 ៛	1,226,052,743 ៛	Not Calculated	789,256,569 ៛
២	ចំនួនទឹកប្រាក់សរុបដែលអ្នកជំងឺបានបង់សម្រាប់សេវាឱសថនៅក្នុងស្រុកប្រតិបត្តិ ពោធិ៍សែនជ័យ Value of the amount that patients paid for the medicine in OD Posenchey	742,963,270 ៛	826,475,450 ៛	871,660,330 ៛	1,233,186,926 ៛	781,982,573 ៛	Not Calculated	566,339,117 ៛
៣	ចំនួនអ្នកជម្ងឺដែលបានមកទទួលសេវាឱសថនៅមណ្ឌលសុខភាព សាមគ្គី Number of cases who come to use medical sevice in Pochentong RH	339 នាក់	269 នាក់	209 នាក់	297 នាក់	251 នាក់	151 នាក់	141នាក់
៤	ចំនួនអ្នកជម្ងឺដែលប្រើប្រាស់អាំងស៊ុយលីន នៅភ្នំពេញ Number of cases use Insulin in Phnom Penh	411 នាក់	420 នាក់	431 នាក់	555 នាក់	485 នាក់	390 នាក់	305 នាក់
៥	ចំនួនអ្នកជម្ងឺដែលប្រើប្រាស់អាំងស៊ុយលីន នៅមណ្ឌលសុខភាព សាមគ្គី Number of cases use Insulin in Samaki HC	17 នាក់	21 នាក់	10 នាក់	17 នាក់	19 នាក់	5 នាក់	5នាក់
៦	ចំនួនទឹកប្រាក់សរុបដែលអ្នកជំងឺបានបង់សំរាប់សេវាឱសថនៅមណ្ឌលសុខភាព សាមគ្គី Value of the amount that patients paid for the medicine in Samaki HC	36,379,420 ៛	39,419,230 ៛	19,249,450 ៛	49,815,422 ៛	45,388,473 ៛	15,630,659 ៛	19,232,200 ៛
៧	ចំនួនទឹកប្រាក់សរុបដែល ម.ព.ជ. ផ្គត់ផ្គង់ទៅមណ្ឌលសុខភាព សាមគ្គី Value of supply to Samaki HC	43,004,500 ៛	38,886,000 ៛	19,173,000 ៛	51,675,735 ៛	45,155,616 ៛	13,625,521 ៛	19,250,547 ៛
៨	សរុបចំនួនឱសថចាក់អាំងស៊ុយគិតជាដបដែលអង្គការ ម.ព.ជ. ផ្គត់ផ្គង់ទៅមណ្ឌលសុខភាព សាមគ្គី Total of quantity of insulin as of Vial/10ml that MoPoTsyo supply to HC Samaki					110 ដប	20 ដប	56 ដប
៩	សរុបចំនួនឱសថគ្រាប់ដែលអង្គការ ម.ព.ជ. ផ្គត់ផ្គង់ទៅមន្ទីរពេទ្យបង្អែកមណ្ឌលសុខភាព សាមគ្គី Total quantity of tablets that MoPoTsyo supplies to HC Samaki					293,948 គ្រាប់	130,170 គ្រាប់	180892 គ្រាប់
១០	ប្រាក់លើកទឹកចិត្តអតិបរមា (=B៦*15%) Maximum reward	5,456,913 ៛	5,912,885 ៛	2,887,418 ៛	7,472,313 ៛	6,808,271 ៛	2,344,599 ៛	2,884,830 ៛
១១	ចំនួនភាគរយដែលអ្នកជម្ងឺបានទិញថ្នាំតាមវេជ្ជបញ្ជា (=B២/B៩) Adherence %	78.53%	78.25%	83.78%	88.34%	63.78%	63.78%	71.76%
១២	លទ្ធផលវាយតំលៃលើវិធានចែកចាយថ្នាំ Satisfaction result	98.92%	81.86%	86.69%	87.74%	85.52%	85.52%	86.97%
១៣	ចំនួនភាគរយនៃប្រាក់លើកទឹកចិត្តដែលត្រូវបែងចែកដល់ឱសថស្ថាន (=(B១១+B១២)/2)) Average reward	88.72%	80.05%	85.23%	88.04%	74.65%	74.65%	79.36%
១៤	ប្រាក់លើកទឹកចិត្តសរុបដែលត្រូវបែងចែកដល់ឱសថស្ថានមណ្ឌលសុខភាព សាមគ្គី(=B១០*B១៣) Available reward for Samaki HC	4,841,577 ៛	4,733,514 ៛	2,461,019 ៛	6,578,596 ៛	5,082,322 ៛	1,750,243 ៛	2,289,488 ៛
15a	ប្រាក់លើកទឹកចិត្តសរុបដែលត្រូវបែងចែកដល់ឱសថស្ថានមណ្ឌលសុខភាព សាមគ្គី ក្រោយដកពន្ធកាត់ទុក ១៥% (=១៤*៨៥%) Available reward for Samaki HC extracted WHT15%				5,591,806 ៛	4,319,974 ៛	1,487,707 ៛	1,946,065 ៛
15b	ប្រាក់លើកទឹកចិត្តសរុបដែលត្រូវបែងចែកដល់ឱសថស្ថានមណ្ឌលសុខភាព សាមគ្គី **០១ ខែ កក្កដា ឆ្នាំ២០២៤ ដល់ ថ្ងៃទី ៣១ ខែ សីហា ២០២៥** ក្រោយដកពន្ធកាត់ទុក១៥% Total Available Reward from 01/07/2024 to 30/06/2025 after 15% WHT Deduction						3,433,771 ៛	

ការចែងចែករប្រាក់លើកទឹកចិត្តជូនអ្នកពាក់ព័ន្ធសំរាប់ការចែកចាយថ្នាំភ្នុច
មណ្ឌលសុខភាព សាមគ្គី

១៦	មន្ទីរសុខាភិបាលរាជធានីភ្នំពេញ for PHD (=B៩៥*1%)	48,416 ៛	47,335 ៛	24,610 ៛	55,918 ៛	43,200 ៛	34,338 ៛
១៧	ស្រុកប្រតិបត្តិ for OD (=B៩៥*4%)	193,663 ៛	189,341 ៛	98,441 ៛	223,672 ៛	172,799 ៛	137,351 ៛
១៨	វេជ្ជបណ្ឌិតពិគ្រោះជំងឺ for the Doctor (=B៩៥*15%)	726,237 ៛	710,027 ៛	369,153 ៛	838,771 ៛	647,996 ៛	515,066 ៛
១៩	ប្រាក់លើកទឹកសំរាប់មន្ទីរពេទ្យ Incentive for the Hospital (=B៩៥*20%)	968,315 ៛	946,703 ៛	492,204 ៛	1,118,361 ៛	863,995 ៛	686,754 ៛
២០	អ្នកចែកចាយថ្នាំនិងអ្នកចូលរួមចែកចាយថ្នាំ for the Pharmacists (=B៩៥*60%)	2,904,946 ៛	2,840,108 ៛	1,476,611 ៛	3,355,084 ៛	2,591,984 ៛	2,060,263 ៛

គណនាប្រាក់លើកទឹកចិត្តសំរាប់ការបែកចាយថ្នាំក្នុងស្រុកប្រតិបត្តិពោធិ៍សែនជ័យ
គិតចាប់ពី ថ្ងៃទី០១ ខែ កក្កដា ឆ្នាំ២០២៤ ដល់ ថ្ងៃទី ២៥ ខែ តុលា ២០២៥
សំរាប់មណ្ឌលសុខភាពកន្ទោក

		ឆ្នាំទី១	ឆ្នាំទី២	ឆ្នាំទី៣	ឆ្នាំទី៤	ឆ្នាំទី៥	
		01-07-2020 to 16-07-2021	01-07-2021 to 30-06-2022	01-07-2022 to 30-06-2023	01-07-2023 to 30-06-2024	**01-07-2024 to 31-12-2024**	**01-01-2025 to 25-10-2025**
	A	B					
លរ	**សូចនាករ**						
១	ចំនួនទឹកប្រាក់សរុបដែលអ្នកជំងឺគួរតែបង់សម្រាប់សេវាឱសថនៅក្នុងស្រុកប្រតិបត្តិ ពោធិ៍សែនជ័យ Value of the amount that patients should pay for the medicine in OD Posenchey	1,056,219,706 ៛	1,040,477,049 ៛	1,395,917,613 ៛	1,226,052,743 ៛	Not Calculated	789,256,569 ៛
២	ចំនួនទឹកប្រាក់សរុបដែលអ្នកជំងឺបានបង់សម្រាប់សេវាឱសថនៅក្នុងស្រុកប្រតិបត្តិ ពោធិ៍សែនជ័យ Value of the amount that patients paid for the medicine in OD Posenchey	826,475,450 ៛	871,660,330 ៛	1,233,186,926 ៛	781,982,573 ៛	Not Calculated	566,339,117 ៛
៣	ចំនួនអ្នកជម្ងឺដែលបានមកទទួលសេវាឱសថនៅមណ្ឌលសុខភាព កន្ទោក Number of cases who come to use medical sevice in Kantoak HC	339 នាក់	308 នាក់	450 នាក់	597 នាក់	509 នាក់	553 នាក់
៤	ចំនួនអ្នកជម្ងឺដែលប្រើប្រាស់អាំងស៊ុយលីន នៅភ្នំពេញ Number of cases use Insulin in Phnom Penh	420 នាក់	431 នាក់	555 នាក់	485 នាក់	390 នាក់	305 នាក់
៥	ចំនួនអ្នកជម្ងឺដែលប្រើប្រាស់អាំងស៊ុយលីន នៅមណ្ឌលសុខភាព កន្ទោក Number of cases use Insulin in Kantoak HC	12 នាក់	3 នាក់	13 នាក់	20 នាក់	17 នាក់	14 នាក់
៦	ចំនួនទឹកប្រាក់សរុបដែលអ្នកជំងឺបានបង់សំរាប់សេវាឱសថនៅមណ្ឌលសុខភាព កន្ទោក Value of the amount that patients paid for the medicine in Kantoak HC	49,793,330 ៛	58,579,490 ៛	102,939,526 ៛	71,703,600 ៛	36,905,018 ៛	57,603,050 ៛
៧	ចំនួនទឹកប្រាក់សរុបដែល ម.ព.ជ. ផ្គត់ផ្គង់ទៅមណ្ឌលសុខភាព កន្ទោក Value of supply to Kantoak HC	51,300,100 ៛	88,694,000 ៛	116,280,220 ៛	74,952,712 ៛	37,283,573 ៛	49,310,540 ៛
៨	សរុបចំនួនឱសថចាក់អាំងស៊ុយគិតជាដបដែលអង្គការ ម.ព.ជ. ផ្គត់ផ្គង់ទៅមណ្ឌលសុខភាពកន្ទោក Total of quantity of insulin as of Vial/10ml that MoPoTsyo supply to HC Kantoak				110 ដប	75 ដប	100 ដប
៩	សរុបចំនួនឱសថគ្រាប់ដែលអង្គការ ម.ព.ជ. ផ្គត់ផ្គង់ទៅមន្ទីរពេទ្យបង្អែកមណ្ឌលសុខភាព កន្ទោក Total quantity of tablets that MoPoTsyo supplies to HC Kantoak				540,564 គ្រាប់	356,766 គ្រាប់	489,288 គ្រាប់
១០	ប្រាក់លើកទឹកចិត្តអតិបរមា (=B៦*15%) Maximum reward	7,469,000 ៛	8,786,924 ៛	15,440,929 ៛	10,755,540 ៛	5,535,753 ៛	8,640,458 ៛
១១	ចំនួនភាគរយដែលអ្នកជម្ងឺបានទិញថ្នាំតាមវេជ្ជបញ្ជា (=B៧/B៩) Adherence %	78%	84%	88%	63.78%	63.78%	71.76%
១២	លទ្ធផលវាយតំលៃលើវិយាបថអ្នកចែកចាយថ្នាំ Satisfaction result	99%	94%	92%	94.21%	85.52%	97.02%
១៣	ចំនួនភាគរយនៃប្រាក់លើកទឹកចិត្តដែលត្រូវបែងចែកដល់ឱសថស្ថាន (=(B១១+B១២)/2)) Average reward	89%	89%	90%	79.00%	74.65%	84.39%
១៤	ប្រាក់លើកទឹកចិត្តសរុបដែលត្រូវបែងចែកដល់ឱសថស្ថានមណ្ឌលសុខភាព កន្ទោក(=B១០*B១៣) Available reward for Kantoak HC	6,632,787 ៛	7,810,040 ៛	13,947,650 ៛	8,496,394 ៛	4,373,245 ៛	7,291,510 ៛
15a	ប្រាក់លើកទឹកចិត្តសរុបដែលត្រូវបែងចែកដល់ឱសថស្ថានមណ្ឌលសុខភាព កន្ទោក ក្រោយដកពន្ធ Available reward for Kantoak HC extracted WHT15%			11,855,503 ៛	7,221,935 ៛	3,717,258 ៛	6,197,784 ៛
15b	ប្រាក់លើកទឹកចិត្តសរុបដែលត្រូវបែងចែកដល់ឱសថស្ថានមណ្ឌលសុខភាព កន្ទោក **០១ ខែ កក្កដា ឆ្នាំ២០២៤ ដល់ ថ្ងៃទី ៣១ ខែ សីហា ២០២៥** ក្រោយដកពន្ធកាត់ទុក១៥% Total Available Reward from 01/07/2024 to 30/06/2025 after 15% WHT Deduction					9,915,042 ៛	

ការបែងចែកប្រាក់លើកទឹកចិត្តដល់អ្នកពាក់ព័ន្ធសំរាប់ការបែកចាយថ្នាំក្នុងមណ្ឌលសុខភាព កន្ទោក

១៦	មន្ទីរសុខាភិបាលរាជធានីភ្នំពេញ for PHD (=B៩៥*1%)	66,328 ៛	78,100 ៛	118,555 ៛	72,219 ៛	99,150 ៛
១៧	ស្រុកប្រតិបត្តិ for OD (=B៩៥*4%)	265,311 ៛	312,402 ៛	474,220 ៛	288,877 ៛	396,602 ៛
១៨	វេជ្ជបណ្ឌិតពិគ្រោះជំងឺ for the Doctor (=B៩៥*២0%)	994,918 ៛	1,171,506 ៛	2,371,101 ៛	1,444,387 ៛	1,983,008 ៛
១៩	ប្រាក់លើកទឹកសំរាប់មណ្ឌលសុខភាព កន្ទោក Incentive for Health Center (=B៩៥*៣៥%)	1,326,557 ៛	1,562,008 ៛	4,149,426 ៛	2,527,677 ៛	3,470,265 ៛
២0	អ្នកចែកចាយថ្នាំនិងអ្នកចូលរួមចែកចាយថ្នាំ for the Pharmacists (=B៩៥*៤0%)	3,979,672 ៛	4,686,024 ៛	4,742,201 ៛	2,888,774 ៛	3,966,017 ៛

គណនាប្រាក់លើកទឹកចិត្តសំរាប់ការចែកចាយថ្នាំក្នុងស្រុកប្រតិបត្តិសែនសុខ
គិតចាប់ពីថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ២០២៤ ដល់ ថ្ងៃទី ៣១ ខែ សីហា ២០២៥
សំរាប់មន្ទីរពេទ្យបន្ទែក មិត្តភាពកម្ពុជា- ចិនសែនសុខ

		ឆ្នាំទី១	ឆ្នាំទី២	ឆ្នាំទី៣	ឆ្នាំទី៤	ឆ្នាំទី៥	
		01-01-2021 to 30-06-2021	01-07-2021 to 30-06-2022	01-07-2022 to 30-06-2023	01-07-2023 to 30-06-2024	01-07-2024 to 31-12-2024	01-01-2025 to 31-08-2025
	A	B					
លរ	សូចនាករ	ចំនួនជាប្រាក់រៀល					
១	ចំនួនទឹកប្រាក់សរុបដែលអ្នកជំងឺគួរតែបង់សម្រាប់សេវាឱសថនៅក្នុងស្រុកប្រតិបត្តិ សែនសុខ Value of the amount that patients should pay for the medicine in OD Sen Sok	1,056,219,706 ៛	1,040,477,049 ៛	1,395,917,613 ៛	1,226,052,743 ៛	Not Calculated	789,256,569 ៛
២	ចំនួនទឹកប្រាក់សរុបដែលអ្នកជំងឺបានបង់សម្រាប់សេវាឱសថនៅក្នុងស្រុកប្រតិបត្តិ សែនសុខ Value of the amount that patients paid for the medicine in OD Sen Sok	826,475,450 ៛	871,660,330 ៛	1,233,186,926 ៛	781,982,573 ៛	Not Calculated	566,339,117 ៛
៣	ចំនួនអ្នកជម្ងឺដែលបានមកទទួលសេវាឱសថនៅនៅមន្ទីរពេទ្យបង្អែកសែនសុខ Number of cases who come to use medical sevice in Sen Sok RH	339 នាក់	308 នាក់	450 នាក់	597 នាក់	474 នាក់	506នាក់
៤	ចំនួនអ្នកជម្ងឺដែលប្រើប្រាស់អាំងស៊ុយលីន នៅភ្នំពេញ Number of cases use Insulin in Phnom Penh	420 នាក់	431 នាក់	555 នាក់	485 នាក់	390 នាក់	305 នាក់
៥	ចំនួនអ្នកជម្ងឺដែលប្រើប្រាស់អាំងស៊ុយលីន នៅមន្ទីរពេទ្យបង្អែកសែនសុខ Number of cases use Insulin in Sen Sok RH	12 នាក់	3 នាក់	13 នាក់	20 នាក់	71 នាក់	59នាក់
៦	ចំនួនទឹកប្រាក់សរុបដែលអ្នកជំងឺបានបង់សំរាប់សេវាឱសថនៅមន្ទីរពេទ្យបង្អែកសែនសុខ Value of the amount that patients paid for the medicine in Sen Sok RH	49,793,330 ៛	58,579,490 ៛	102,939,526 ៛	71,703,600 ៛	68,081,009 ៛	84,745,591 ៛
៧	ចំនួនទឹកប្រាក់សរុបដែល ម.ព.ជ. ផ្គត់ផ្គង់ទៅមន្ទីរពេទ្យបង្អែកសែនសុខ Value of supply to Sen Sok RH	51,300,100 ៛	88,694,000 ៛	116,280,220 ៛	74,952,712 ៛	67,636,148 ៛	92,297,732 ៛
៨	សរុបចំនួនឱសថចាក់អាំងស៊ុយគិតជាដបដែលអង្គការ ម.ព.ជ. ផ្គត់ផ្គង់ទៅមន្ទីរពេទ្យបង្អែកសែនសុខ Total of quantity of insulin as of Vial/10ml that MoPoTsyo supply to Sen Sok RH				110 ដប	314 ដប	477 ដប
៩	សរុបចំនួនឱសថគ្រាប់ដែលអង្គការ ម.ព.ជ. ផ្គត់ផ្គង់ទៅមន្ទីរពេទ្យបង្អែកមន្ទីរពេទ្យបង្អែកសែនសុខ Total quantity of tablets that MoPoTsyo supplies to Sen Sok RH				540,564 គ្រាប់	403,150 គ្រាប់	579,389 គ្រាប់
១០	ប្រាក់លើកទឹកចិត្តអតិបរមា (=B៦*15%) Maximum reward	7,469,000 ៛	8,786,924 ៛	15,440,929 ៛	10,755,540 ៛	10,212,151 ៛	12,711,839 ៛
១១	ចំនួនភាគរយដែលអ្នកជម្ងឺបានទិញថ្នាំតាមវេជ្ជបញ្ជា (=B៧/B៩) Adherence %	78%	84%	88.34%	64%	63.78%	71.76%
១២	លទ្ធផលវាយតំលៃលើតំយោបថអ្នកចែកចាយថ្នាំ Satisfaction result	99%	94%	92.32%	94%	94.21%	97.58%
១៣	ចំនួនភាគរយនៃប្រាក់លើកទឹកចិត្តដែលត្រូវបែងចែកដល់ឱសថស្ថាន (=(B៩៩+B៩២)/2)) Average reward	89%	89%	90.33%	79%	79.00%	84.67%
១៤	ប្រាក់លើកទឹកចិត្តសរុបដែលត្រូវបែងចែកដល់ឱសថស្ថានមន្ទីរពេទ្យបង្អែកសែនសុខ(=B៩០*B៩៣) Available reward for Sen Sok RH	6,632,787 ៛	7,810,040 ៛	13,947,650 ៛	8,496,394 ៛	4,373,245 ៛	10,762,861 ៛
15a	ប្រាក់លើកទឹកចិត្តសរុបដែលត្រូវបែងចែកដល់ឱសថស្ថានមន្ទីរពេទ្យបង្អែកសែនសុខ Available reward for Kontok Health Post extracted WHT15%			11,855,503 ៛	7,221,935 ៛	3,717,258 ៛	9,148,432 ៛
15b	ប្រាក់លើកទឹកចិត្តសរុបដែលត្រូវបែងចែកដល់ឱសថស្ថានមន្ទីរពេទ្យបង្អែកសែនសុខ **០១ ខែ កក្កដា ឆ្នាំ២០២៤ ដល់ ថ្ងៃទី ៣១ ខែ សីហា ២០២៥** ក្រោយដកពន្ធ Total Available Reward from 01/07/2024 to 30/06/2025 after 15% WHT Deduction					12,865,690 ៛	

ការបែងចែកប្រាក់លើកទឹកចិត្តដល់អ្នកពាក់ព័ន្ធសំរាប់ការចែកចាយថ្នាំក្នុង
មន្ទីរពេទ្យបន្ទែក មិត្តភាពកម្ពុជា-ចិនសែនសុខ

១៦	មន្ទីរសុខាភិបាលរាជធានីភ្នំពេញ for MoH (=B៩៥*1%)	66,328 ៛	78,100	118,555	72,219 ៛	128,657 ៛
១៧	ស្រុកប្រតិបត្តិ សែនសុខ for Sen Sok OD (=B៩៥*4%)	265,311 ៛	312,402 ៛	474,220 ៛	288,877 ៛	514,628 ៛
១៨	វេជ្ជបណ្ឌិតពិគ្រោះជំងឺនៅមន្ទីរពេទ្យបង្អែក មិត្តភាពកម្ពុជា-ចិនសែនសុខ for the Consultation Doctor in Sen Sok Cambodia-China Friendship RH (=B៩៥*15%)	994,918 ៛	1,171,506 ៛	1,778,325 ៛	1,083,290 ៛	1,929,853 ៛
១៩	ប្រាក់លើកទឹកចិត្តសំរាប់មន្ទីរពេទ្យបង្អែក មិត្តភាពកម្ពុជា-ចិនសែនសុខ Sen Sok Cambodia-China Friendship RH (=B៩៥*20%)	1,326,557 ៛	1,562,008 ៛	2,371,101 ៛	1,444,387 ៛	2,573,138 ៛
២០	អ្នកចែកចាយថ្នាំនិងអ្នកចូលរួមចែកចាយថ្នាំនៅមន្ទីរពេទ្យបង្អែក មិត្តភាពកម្ពុជា-ចិនសែនសុខ for the Pharmacists in Sen Sok Cambodia-China Friendship RH (=B៩៥*60%) Mrs.Neth Roza	-	-	2,609,803 ៛	9,944,151 ៛	7,719,414 ៛

គណនាប្រាក់លើកទឹកចិត្តសំរាប់ការចែកចាយថ្នាំក្នុងស្រុកប្រតិបត្តិមេគន្ធ
គិតចាប់ពី ថ្ងៃទី០១ ខែ កក្កដា ឆ្នាំ២០២៤ ដល់ ថ្ងៃទី ៣១ ខែ សីហា ២០២៥
សំរាប់មន្ទីរពេទ្យបង្អែក សម្តេចឪសម្តេចម៉ែ

		ឆ្នាំទី១	ឆ្នាំទី២	
		01-11-2023 to 30-06-2024	01-07-2024 to 31-12-2024	01-01-2025 to 31-08-2025
	A		B	
ល.រ	សូចនាករ		ទឹកប្រាក់ជារៀល	
១	ចំនួនទឹកប្រាក់សរុបដែលអ្នកជំងឺគួរតែបង់សម្រាប់សេវាឱសថនៅក្នុងស្រុកប្រតិបត្តិទាំង៣	1,226,052,743 ៛	Not Calculated	789,256,569 ៛
	Value of the amount that patients should pay for the medicine in OD in Phnom Penh			
២	ចំនួនទឹកប្រាក់សរុបដែលអ្នកជំងឺបានបង់សម្រាប់សេវាឱសថនៅក្នុងស្រុកប្រតិបត្តិទាំង៣	781,982,573 ៛	Not Calculated	566,339,117 ៛
	Value of the amount that patients paid for the medicine in OD in Phnom Penh			
៣	ចំនួនអ្នកជម្ងឺដែលបានមកទទួលសេវាឱសថនៅមន្ទីរពេទ្យបង្អែក សម្តេចម៉ែ សម្តេចឪ	82 នាក់	98 នាក់	107 នាក់
	Number of cases who come to use medical sevice in Samdach Mea Samdach Ov RH			
៤	ចំនួនអ្នកជម្ងឺដែលប្រើប្រាស់អាំងស៊ុយលីន នៅភ្នំពេញ	485 នាក់	390 នាក់	305 នាក់
	Number of cases use Insulin in Phnom Penh			
៥	ចំនួនអ្នកជម្ងឺដែលប្រើប្រាស់អាំងស៊ុយលីន នៅមន្ទីរពេទ្យបង្អែក សម្តេចម៉ែ សម្តេចឪ	4 នាក់	4 នាក់	3 នាក់
	Number of cases use Insulin in Samdach Mea Samdach Ov RH			
៦	ចំនួនទឹកប្រាក់សរុបដែលអ្នកជំងឺបានបង់សំរាប់សេវាឱសថនៅមន្ទីរពេទ្យបង្អែក សម្តេចម៉ែ សម្តេចឪ	8,337,568 ៛	9,030,891 ៛	12,044,978 ៛
	Value of the amount that patients paid for the medicine inSamdach Mea Samdach Ov RH			
៧	ចំនួនទឹកប្រាក់សរុបដែល ម.ព.ជ. ផ្គត់ផ្គង់ទៅមន្ទីរពេទ្យបង្អែក សម្តេចម៉ែ សម្តេចឪ	14,132,683 ៛	8,202,807 ៛	10,879,812 ៛
	Value of supply toSamdach Mea Samdach Ov RH			
៨	សរុបចំនួនឱសថចាក់អាំងស៊ុយគិតជាដបដែលអង្គការ ម.ព.ជ. ផ្គត់ផ្គង់ទៅ មន្ទីរពេទ្យបង្អែក សម្តេចម៉ែ សម្តេចឪ	37 ដប	8 ដប	7 ដប
	Total of quantity of insulin as of Vial/10ml that MoPoTsyo supply to Samdach Mea Samdach Ov RH			
៩	សរុបចំនួនឱសថគ្រាប់ដែលអង្គការ ម.ព.ជ. ផ្គត់ផ្គង់ទៅមន្ទីរពេទ្យបង្អែក សម្តេចម៉ែ សម្តេចឪ	75,710 គ្រាប់	72,858 គ្រាប់	88,762 គ្រាប់
	Total quantity of tablets that MoPoTsyo supplies to Samdach Mea Samdach Ov RH			
១០	ប្រាក់លើកទឹកចិត្តអតិបរមា (=B៦*15%)	1,250,635 ៛	1,354,634 ៛	1,806,747 ៛
	Maximum reward			
១១	ចំនួនភាគរយដែលអ្នកជម្ងឺបានទិញថ្នាំតាមវេជ្ជបញ្ជា (=B២/B១)	63.78%	63.78%	71.76%
	Adherence %			
១២	លទ្ធផលវាយតំលៃលើឥរិយាបថអ្នកចែកចាយថ្នាំ	91.82%	91.82%	99.87%
	Satisfaction result			
១៣	ចំនួនភាគរយនៃប្រាក់លើកទឹកចិត្តដែលត្រូវបែងចែកដល់ឱសថស្ថាន (=(B១១+B១២)/2))	77.80%	77.80%	85.81%
	Average reward			
១៤	ប្រាក់លើកទឹកចិត្តសរុបដែលត្រូវបែងចែកដល់ឱសថស្ថានមន្ទីរពេទ្យបង្អែក សម្តេចម៉ែសម្តេចឪ(=B១០*B១៣)	973,001 ៛	1,053,912 ៛	1,550,424 ៛
	Available reward for Samdach Mea Samdach Ov RH			
15a	ប្រាក់លើកទឹកចិត្តសរុបដែលត្រូវបែងចែកដល់ឱសថស្ថានមន្ទីរពេទ្យបង្អែក សម្តេចម៉ែ សម្តេចឪ ក្រោយដកពន្ធកាត់ទុក ១៥% (=១៤*៨៥%)	827,051 ៛	895,825 ៛	1,317,860 ៛
	Available reward for Samdach Mea Samdach Ov RHextracted WHT15%			
15b	ប្រាក់លើកទឹកចិត្តសរុបដែលត្រូវបែងចែកដល់ឱសថស្ថានមន្ទីរពេទ្យបង្អែក សម្តេចម៉ែ សម្តេចឪ **០១ ខែ កក្កដា ឆ្នាំ២០២៤ ដល់ ថ្ងៃទី ៣១ ខែ សីហា ២០២៥** ក្រោយដកពន្ធកាត់ទុក១៥%		2,213,686 ៛	
	Total Available Reward from 01/07/2024 to 30/06/2025 after 15% WHT Deduction			

ការបែងចែកប្រាក់លើកទឹកចិត្តដល់អ្នកពាក់ព័ន្ធសំរាប់ការចែកចាយថ្នាំក្នុង មន្ទីរពេទ្យបង្អែក សម្តេចម៉ែ សម្តេចឪ

១៦	មន្ទីរសុខាភិបាលរាជធានីភ្នំពេញ for PHD (=B១៥*1%)	8,271 ៛	22,137 ៛
